00519394

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 05 / 2010
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លេខ/No: D97/16/10

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៩)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ប៉ែន ពេជ្រសាលី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 05 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**កាលបរិច្ឆេទ:** ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE
Fabienne TRUSSES-NAPROUS

**សហមេធាវីការពារក្តីជនត្រូវចោទ**
ផាត់ ពៅស៊ាង
Diana ELLIS

នី ច័ន្ទឌី
ឡោ ជុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
ស៊ិន សុវ៉ន
គង់ ហេង
សម សុគង់
សុខ សំអឿន
ជេត វណ្ណលី
ពេជ អង្គ

Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Silke STUDZINSKY
Pierre Olivier SUR
Mahdev MOHAN
NGUYEN Lyma
Marie GUIRAUD
Patrick BAUDOIN
Olivier BAHOUGNE
Julien RIVET
Emmanuel ALTIT
Maria Stefania CATALETA
Charlotte PLANTIN
Pascal AUBOIN
Jan Ernest RESSEK

អាង ឧត្តម
Michael G. KARNAVAS
ស សុវាន
Jacques VERGES

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE

# មាតិកា

I. ប្រវត្តិនីតិវិធី ........................................................................ 4

II. សេចក្ដីសង្ខេបបណ្ដឹងឧទ្ធរណ៍ ........................................................ 9

III ការទទួលយកបាននូវបណ្ដឹងឧទ្ធរណ៍ ................................................ 14

ក. តើដីកាដែលត្រូវបានជំទាស់ មានតម្លៃស្មើនឹង “ដីកា” ឬ “សេចក្ដីសម្រេច” ................ 15

ឬមានតម្លៃគ្រាន់តែជា “សេចក្ដីប្រកាស”? ...................................................... 15

ខ. តើដីកាដែលត្រូវបានជំទាស់ អាចប្ដឹងឧទ្ធរណ៍បានដែរឬទេ អនុលោមតាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង? ........................................................................ 16

គ. តើដីកាដែលត្រូវបានជំទាស់ អាចប្ដឹងឧទ្ធរណ៍តាមវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុងដែរឬទេ?...... 21

ឃ. តើអង្គហេតុ និងកាលៈទេសៈនៃបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន តម្រូវឲ្យអនុម័តនូវការបកស្រាយទូលំទូលាយចំពោះវិធាន៧៤(៣) ដើម្បីធានាថា ដំណើរការនីតិវិធីលើជនត្រូវចោទមានលក្ខណៈយុត្តិធម៌ដែរឬទេ? ........................................................................ 24

ង. តើការបដិសេធបណ្ដឹងឧទ្ធរណ៍នឹងជួយសន្សំសំចៃសេដ្ឋកិច្ចតុលាការដែរឬទេ? ប្រសិនបើអាច តើការសន្និដ្ឋាននេះអាចជាមូលដ្ឋានមានសុពលភាពដើម្បីសម្រេចអំពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្នឬទេ? ........................................................................ 28

IV. អង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍ ........................................................ 29

ក. តើទស្សនទាននៃ JCE ត្រូវបានទទួលស្គាល់ថាជាទម្រង់មួយនៃការទទួលខុសត្រូវតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនឆ្នាំ១៩៧៥ ដែរឬទេ? .............................................. 42

ខ. បញ្ហាថាតើ JCE I ត្រូវបានជជែកការពារបានត្រឹមត្រូវដែរឬទេ ................................ 85

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ...................................................... 85

គ. បញ្ហាថាតើ ទម្រង់ JCE អនុវត្តចំពោះបទល្មើសជាតិ ក៏ដូចជាចំពោះបទឧក្រិដ្ឋអន្តរជាតិដែរឬទេ? 96

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះ “ដីកាសម្រេច” អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានទទួលស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម” ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩” ដែលដាក់នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ (“បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ”) “បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម” ដែលបានដាក់នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ (“បណ្តឹងឧទ្ធរណ៍របស់ អៀង សារី”) “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការដាក់ឲ្យអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថា សហឧក្រិដ្ឋកម្មរួម” ដែលដាក់ដោយ ខៀវ សំផន នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០ (“បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន”) និង “សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចអនុវត្តបាននូវទម្រង់នៃការទទួលខុសត្រូវ” ដែលដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១០ (“បណ្តឹងឧទ្ធរណ៍របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី”)។

## I. ប្រវត្តិនីតិវិធី

១. បណ្តឹងឧទ្ធរណ៍ទាំងនេះ បានដាក់នៅក្នុងបរិបទទាក់ទងនឹងការស៊ើបអង្កេតដែលកំពុងបន្តលើ នួន ជា, អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន និងកាំង ហ្គេកអ៊ាវ ហៅ “ឌុច” ទាក់ទងនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់អ.វ.ត.ក”)។

២. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ មេធាវីការពារក្តី អៀង សារី បានដាក់ជូនសហចៅក្រមស៊ើបអង្កេត "ក.ស.ច.ស" នូវពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ("ពាក្យស្នើសុំរបស់លោក អៀង សារី") ដោយស្នើសុំ ក.ស.ច.ស ប្រកាសមិនអនុវត្តទម្រង់ JCE នៅចំពោះមុខ អ.វ.ត.ក[១] ដោយផ្អែកលើមូលដ្ឋានថា ១) ការអនុវត្តទម្រង់ JCE នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព ដោយសារតែ JCE មិនត្រូវបានទទួលស្គាល់ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិមុន ឬក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ឬ ក៏ក្នុងពេលបច្ចុប្បន្នផងដែរ[២]។ ២) JCE មិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬក៏ JCE មិនមែនជាផ្នែកនៃច្បាប់កម្ពុជា ឬត្រូវបានទទួលស្គាល់ដោយអនុសញ្ញាអន្តរជាតិដែលអាចអនុវត្តនៅចំពោះមុខ អ.វ.ត.ក[៣]។ បន្ទាប់ពីមានការស្នើសុំពី ក.ស.ច.ស មេធាវីការពារក្តី អៀង សារី បានដាក់សេចក្តីសង្កេតបន្ថែម នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨[៤]

---

[១] ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហឧក្រិដ្ឋកម្មរួម* (JCE) ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ D97 ("ពាក្យស្នើសុំរបស់ អៀង សារី")។ ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិស្នើសុំរបស់ អៀង សារី ស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ ឯកសារ D97/II ("ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា")។

[២] ពាក្យស្នើសុំរបស់ អៀង សារី កថាខណ្ឌ២៩។ សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តន៍ទ្រឹស្តី សហកម្មឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D97/7 ("សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី") ផ្នែកI (ក)។

[៣] ពាក្យស្នើសុំរបស់ អៀង សារី ទំព័រ១ ឯកសារ D97/5 ទំព័រ២។ សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ផ្នែកII (ខ-ច)។

[៤] សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី។ ក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី សង្ខេប សេចក្តីសង្កេតបន្ថែមរបស់ខ្លួនដូចខាងក្រោម។ ១. មិនអាចអនុវត្តនៅ អ.វ.ត.ក បានទេ ពីព្រោះវាត្រូវបានរារាំងដោយ*គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង*។ ២. JCE មិនមែនជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែល អ.វ.ត.ក មានយុត្តាធិការតាមអំណាចមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ។ ទម្រង់នេះមិនបានចែងច្បាស់លាស់នៅក្នុងមាត្រា២៩ ហើយក៏មិនបានបញ្ជាក់ន័យថា វាត្រូវបានចាត់ទុកជា "ទម្រង់នៃការប្រព្រឹត្ត" ដែរ។ ៣. JCE មិនត្រូវបានទទួលស្គាល់ដោយច្បាប់កម្ពុជា ដែលនៅជាធរមានចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ៤. JCE មិនត្រូវបានបង្កើតនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិទេ នាពេលថ្មីៗនេះ ហើយវាក៏មិនត្រូវបានទទួលស្គាល់ដោយច្បាប់ទំនៀមទំលាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរ។ ៥. JCE ជាទម្រង់

00519399



ខណៈដែលមេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់សេចក្តីសង្កេតបន្ថែម នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨[៥] ដោយយល់ស្របជាមួយនឹងអំណះអំណាងនានា ដែលបានលើកឡើងដោយមេធាវីការពារក្តី អៀង សារី នៅក្នុងសំណើសុំដើម និងសេចក្តីអង្កេតបន្ថែម[៦]។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីបានតវ៉ាថា អ.វ.ត.ក មានយុត្តាធិការអនុវត្តតែទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម ហើយ ក.ស.ព មិនបានសន្និដ្ឋានអំពី JCE ឱ្យបានគ្រប់គ្រាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[៧]។ នៅថ្ងៃជាមួយគ្នានោះ មេធាវីការពារក្តី នួន ជា បានដាក់សេចក្តីអង្កេតបន្ថែមរបស់ខ្លួន[៨] គាំទ្រជំហររបស់មេធាវីការពារក្តីដែលបានលើកឡើងខាងលើ។ មេធាវីការពារក្តី កាំង ហ្គេកអ៊ាវ បានបដិសេធចោលការស្នើរបស់ ក.ស.ច.ស ឲ្យដាក់សេចក្តីអង្កេតបន្ថែមកាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨[៩]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីសង្កេតបន្ថែមរបស់ខ្លួនផងដែរ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨[១០] ដោយសន្និដ្ឋានថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម មិនអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដោយសារតែទម្រង់នេះ មិនមានចងក្រងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងច្បាប់ អ.វ.ត.ក។ ហេតុដូចនេះ ទម្រង់នេះមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

ដែលមិនអាចប្រមើលមើលជាមុនបាន ហើយក៏មិនអាចស្វែងរកបានដែរចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរ។ ៦. ច្បាប់ទំនៀមទំលាប់អន្តរជាតិ មិនត្រូវបានអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជាទេ ហើយវាក៏មិនអាចអនុវត្តនៅ អ.វ.ត.ក បានដែរ។ សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ផ្នែកI។

[៥] សារណារបស់អ្នកស្រី អៀង ធីរិទ្ធ ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួម អនុលោមតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D97/3/2 (“សារណារបស់អ្នកស្រី អៀង ធីរិទ្ធ”)។

[៦] សារណារបស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ២៨។

[៧] សារណារបស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ២៩, ៣១។

[៨] សារណាស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D97/3/3 (“សារណារបស់លោក នួន ជា”)។

[៩] កំណត់សម្គាល់របស់មេធាវីការពារជនត្រូវចោទទៅលើការអនុវត្តន៍ទម្រង់នៃការទទួលខុសត្រូវក្រោមរូបភាពជាសហឧក្រិដ្ឋកម្មរួម (ត្រូវបានដាក់ដោយមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D97/3/1 កថាខណ្ឌ២។

[១០] សារណាតបរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D97/3/4 (“សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី”)។



PRE-TRIAL CHAMBER ECCC CETC

ឡើយក្នុងពេលវេលាពាក់ព័ន្ធ ពោលគឺចន្លោះពីឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ ការអនុវត្តទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក នឹងរំលោភបំពានលើគោលការណ៍ *គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង* និងគោលការណ៍ *គ្មានទោស ប្រសិនបើគ្មានច្បាប់ចែង* [១១] *(nullem crimen nulla poena sine lege)*។

៣. នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ [១២] តែប៉ុណ្ណោះ។

៤. នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ ក.ស.ច.ស បានលើកឡើងនូវសំអាងហេតុផ្នែកច្បាប់ចំពោះបណ្តឹងឧទ្ធរណ៍ ដូចតទៅ ៖

ក) ទោះបីជាមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ (“ច្បាប់ អ.វ.ត.ក”) មិនមានចែងច្បាស់លាស់អំពី JCE ក៏ប៉ុន្តែ JCE គឺជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការប្រព្រឹត្តិក្នុងសាលដីការបស់តុលាការ ICTY លើបណ្តឹងសាទុក្ខក្នុងរឿងក្តី *Tadić* [១៣]។ JCE មានបីទម្រង់ខុសៗគ្នា ដែល JCE ទាំងបីទម្រង់មាន*ធាតុផ្សំសត្យានុម័ត*ដូចគ្នា *(actus reus)* ប៉ុន្តែមាន*ធាតុផ្សំអត្តនោម័ត*ខុសគ្នា *(mens rea)* [១៤]។

---

[១១] សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៣៤។

[១២] សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីបង្គាប់ឲ្យដាក់ការឆ្លើយតប ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១០ ឯកសារ D97/14/11។

[១៣] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Duško Tadić* (IT-94-1-A) សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ (“សាលដីកាក្នុងរឿងក្តី *Tadić* ឬ *“រឿងក្តី Tadić”*)។

[១៤] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ១៣-១៧ ដែលយោងតាមរយៈនេះ *ធាតុផ្សំសត្យានុម័ត* រួមមាន មានអ្នកចូលរួមប្រព្រឹត្តច្រើន អត្ថិភាពនៃគោលបំណងរួម (ឬផែនការរួម) ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋកម្ម ដែលមានចែងក្នុងច្បាប់ ហើយជនត្រូវចោទត្រូវតែបានចូលរួមក្នុងផែនការរួម។ ទម្រង់ទីពីរនៃ JCE (លក្ខណៈជាប្រព័ន្ធ) គឺទាញចេញពីប្រភេទទីមួយ (ទម្រង់មូលដ្ឋាន) ដែលទម្រង់ទាំងពីរនេះទាមទារឲ្យមានភស្តុតាងបញ្ជាក់ពីការសហការរួមនៃការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ដែលបង្កើតជាផ្នែកនៃផែនការរួមរវាងជនត្រូវចោទ និងជនដទៃទៀត ដែលជាប់ទាក់ទងក្នុង JCE ផ្ទុយទៅវិញ ទម្រង់ទីបី នៃ JCE (ទម្រង់លាត

ខ) គោលការណ៍នីត្យានុកូលភាព ទាមទារឲ្យមានការវាយតម្លៃថាតើ JCE គឺជាច្បាប់ជាធរមាន នៅពេលដែលចោទប្រកាន់ចំពោះការប្រព្រឹត្តិបទល្មើសនោះដែរឬទេ[១៥]។ ការវាយតម្លៃ គឺថាតើការទទួលខុសត្រូវព្រហ្មទណ្ឌ អាចប្រមើលដឹងគ្រប់គ្រាន់ថាជាបទឧក្រិដ្ឋហើយ "ច្បាប់ដែលចែងអំពីការទទួលខុសត្រូវនេះ ត្រូវបានដឹងនៅពេលនោះដែរឬទេ[១៦]។ ការវាយតម្លៃត្រូវបានបំពេញ នៅពេលដែលអំពើដែលចោទប្រកាន់នោះ ត្រូវបានកំណត់ថាជាបទល្មើស ផ្អែកតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ [...]"[១៧]។

គ) "ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយ អ.វ.ត.ក គឺជាការសន្និដ្ឋានដែលទាញចេញអំពីហេតុដែលថា អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការអន្តរជាតិ ដែលអនុវត្តច្បាប់អន្តរជាតិ"[១៨]។

ឃ) "ដោយពិចារណាអំពីចរិតលក្ខណៈអន្តរជាតិរបស់ អ.វ.ត.ក នេះ" និងដោយបានពិចារណាឃើញថា "យុត្តិសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃអំពី JCE ត្រូវបានតាក់តែងឡើងមុនពេលនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរនៅមុខ អ.វ.ត.ក ដូចនេះវាមានមូលដ្ឋានផ្អែកតាមច្បាប់អន្តរជាតិដើម្បីអនុវត្ត JCE" ចំពោះមុខ អ.វ.ត.ក[១៩]។ និង

---

សន្និង) ជនជាប់ចោទក៏ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រៅផែនការរួមដែលជាផលវិបាកជាធម្មជាតិ និងអាចមើលឃើញមុននៃផែនការរួមនោះ ប្រសិនបើជនជាប់ចោទអាចមើលឃើញជាមុននៃផែនការរួមនោះ និងបានទទួលយកដោយចេតនានូវហានិភ័យនេះ។

[១៥] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ១៨។

[១៦] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ១៩ ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត* (IT-05-98) សេចក្តីសម្រេចលើញត្តិរបស់ Dragolijob Ojdanić ជំទាស់ទៅនឹងយុត្តាធិការ -- សហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ("សេចក្តីសម្រេច JCE ក្នុងរឿងក្តី Ojdanić) កថាខណ្ឌ៣៧។

[១៧] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ២០។

[១៨] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ២១។

[១៩] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ២១ (ការទាញហេតុសំអាងខាងក្នុងត្រូវបានលុប)។

ង) "អនុលោមតាមគោលការណ៍នៃការបកស្រាយលើ "*របបគតិយុត្ត*"ពិសេស [...] ទម្រង់នៃការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មអន្តរជាតិ អាចត្រូវបានអនុវត្តចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិតែប៉ុណ្ណោះ"[២០]។

៥. ហេតុដូច្នេះ ក.ស.ច.ស សម្រេចថា JCE មិនអាចអនុវត្តបានចំពោះបទល្មើសជាតិឡើយ។ ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ ក.ស.ច.ស សម្រេចបដិសេធ "សំណើសុំនេះ ដោយហេតុថា *ធាតុផ្សំសត្យានុម័ត* និង *ធាតុផ្សំអត្តនោម័ត*" នៃ JCE I និង JCE II និង *ធាតុផ្សំសត្យានុម័ត* នៃ JCE III ដោយអះអាងអំពីភាពអាចអនុវត្តបាននៃគោលការណ៍ទាំងនោះនៅចំពោះមុខ អ.វ.ត.ក[២១]។ ក.ស.ច.ស បានសម្រេចទទួលយកដោយផ្អែកនូវ "សំណើសុំនេះ ដោយហេតុថា ធាតុផ្សំអត្តនោម័តនៃ JCE III ដែលអាចត្រូវអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក គឺមានតែការទទួលយកជាអត្តនោម័តនៃផលវិបាកជាធម្មជាតិ និងផលវិបាកដែលគេមើលឃើញយ៉ាងច្បាស់នៃការអនុវត្តផែនការរួមតែប៉ុណ្ណោះ"[២២]។

## II. សេចក្តីសង្ខេបបណ្តឹងឧទ្ធរណ៍

៦. បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ផ្អែកលើមូលដ្ឋានចំនួនប្រាំពីរ ដោយស្នើសុំឱ្យអង្គបុរេជំនុំជម្រះ "បដិសេធដីកាដែលត្រូវបានជំទាស់នេះ និងសម្រេចថា អ.វ.ត.ក មិនមានយុត្តាធិការលើ JCE ដែលជាទម្រង់នៃការទទួលខុសត្រូវនោះទេ"[២៣]។ ម្យ៉ាងវិញទៀត ពួកគាត់ស្នើសុំឱ្យអង្គបុរេជំនុំជម្រះសម្រេចថា អ.វ.ត.ក មិនមានយុត្តាធិការលើទម្រង់ទីពីរ និងទីបី នៃ JCE ដោយផ្អែកលើមូលដ្ឋានថា សហព្រះរាជអាជ្ញាមិនបានសន្និដ្ឋានគ្រប់គ្រាន់ទាល់តែសោះ នូវទម្រង់នៃការទទួលខុសត្រូវនេះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហេតុដូច្នេះ JCE II និង JCE III មិនអាចយកមកអនុវត្តនៅក្នុងសំណុំរឿង០០២បានទេ។ មូលដ្ឋានទី១ ចោទប្រកាន់ថា ដីកាដែលត្រូវបានជំទាស់ ខ្វះភាពច្បាស់លាស់ និងមានលក្ខណៈមិនច្បាស់ ទាក់ទងនឹងការបង្កើតនូវទម្រង់ទីបីនៃ JCE[២៤]។ មូល

---

[២០] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ២២-២៣។

[២១] ដីកាដែលត្រូវបានជំទាស់ ផ្នែកសម្រេចសេចក្តី។

[២២] ដីកាដែលត្រូវបានជំទាស់ ផ្នែកសម្រេចសេចក្តី។

[២៣] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ១។

[២៤] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ៩។

00519403



ដ្ឋានទី២ ចោទប្រកាន់ថា ក.ស.ច.ស ខកខានមិនបានផ្តល់សំអាងហេតុអំពីមូលហេតុដែល ក.ស.ច.ស បដិសេធចោលទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា សាលដីកាលើបណ្តឹងសាទុក្ខក្នុងរឿងក្តី *Tadić* បង្កើតនូវយុត្តិសាស្ត្រមួយ ដែលមិនពេញលេញក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក្នុងការផ្អែកលើ JCE[២៥]។ មូលដ្ឋានទី៣ ចោទប្រកាន់ថា ក.ស.ច.ស ខកខានក្នុងការលើកឡើងទឡ្ហីករណ៍ដែលធ្វើឡើងតាងនាមឱ្យ អៀង ធីរិទ្ធ ដែលថា JCE មិនបានសន្និដ្ឋានឱ្យបានសមស្រប នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[២៦]។ មូលដ្ឋានទី៤ ចោទប្រកាន់ថា "ពុំមានមូលដ្ឋានសម្រាប់ JCE III នៅក្នុងប្រទេសកម្ពុជា ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ នោះទេ ហើយថាមូលដ្ឋានសម្រាប់ទម្រង់ទី២ នៃ JCE គឺមានលក្ខណៈមិនច្បាស់លាស់ផងដែរ"[២៧]។ មូលដ្ឋានទី៥ ចោទប្រកាន់ថា ក.ស.ច.ស យល់ឃើញដោយភាន់ច្រឡំថា ទម្រង់ទី២ និងទម្រង់ទី៣ នៃ JCE អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដោយសារតែ JCE III មិនមានចែងនៅក្នុងច្បាប់កម្ពុជា [មុនឬនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩] ហេតុដូច្នេះមូលដ្ឋាននៃ JCE II មានលក្ខណៈមិនច្បាស់លាស់[២៨]។ មូលដ្ឋានទី៦ ចោទប្រកាន់ថា ក.ស.ច.ស ខកខានមិនបានសម្រេចថា "ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួមជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងពេលវេលាពាក់ព័ន្ធ"[២៩]។ មូលដ្ឋានទី៧ ចោទប្រកាន់ថា ដីកាដែលត្រូវបានជំទាស់ ហាក់ដូចជាបានសន្និដ្ឋានថា "ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួមគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងពេលវេលាពាក់ព័ន្ធ" ហើយពិតណាស់ថា ការសន្និដ្ឋានបែបនេះ មិនមានមូលដ្ឋានជាបង្អែកនោះទេ[៣០]។

៧. បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចោទប្រកាន់ថា ក.ស.ច.ស ភាន់ច្រឡំលើចំណុចចំនួនប្រាំ នៅពេល ក.ស.ច.ស សម្រេចថា ការទទួលខុសត្រូវ JCE អាចអនុវត្តបាននៅ អ.វ.ត.ក ដោយរកឃើញ ឬសន្និដ្ឋានថា៖ ក) "អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការអន្តរជាតិ ពីព្រោះអ.វ.ត.ក ជា

[២៥] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ២២-២៤។

[២៦] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ២៨។

[២៧] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ៣៨។

[២៨] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ៤៤។

[២៩] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ៥២។

[៣០] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ៦០។

00519404



តុលាការកម្ពុជាថ្នាក់ជាតិ"[៣១]។ ខ) អ.វ.ត.ក អាចអនុវត្តដោយផ្ទាល់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងករណីដែលគ្មានបទប្បញ្ញត្តិជាក់លាក់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ឬយុត្តិសាស្ត្រជាតិ ដោយរួមបញ្ចូលច្បាប់ទំនៀមទម្លាប់ចូលទៅក្នុងច្បាប់ជាតិ ប៉ុន្តែ អ.វ.ត.ក[៣២]។ គ) "ការទទួលខុសត្រូវ JCE ពិតជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងចន្លោះឆ្នាំ១៩៧៥-៧៩" ដោយមិនចាំបាច់មានការវិភាគណាដាច់ដោយឡែកនោះទេ[៣៣]។ ឃ) ការព្រមទទួលថា "ការទទួលខុសត្រូវ JCE ដែលបង្កើតឡើងដោយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY លើរឿងក្តី *Tadić* អាចស្ថិតនៅក្រោមបទប្បញ្ញត្តិ "ការប្រព្រឹត្តិបទល្មើស" ដែលមានចែងនៅក្នុងមាត្រា២៩" នៃច្បាប់ អ.វ.ត.ក[៣៤]។ និង ង) "ការសម្រេចថា ការអនុវត្តការទទួលខុសត្រូវ JCE មិនបានរំលោភបំពានគោលការណ៍នីត្យានុកូលភាពនោះទេ"[៣៥]។

៨. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ ជាដំបូង ខៀវ សំផន បានចោទប្រកាន់ថា ដីកាដែលត្រូវបានជំទាស់ បានចេញយឺតពេល[៣៦] និងមិនបានជូនដំណឹងឱ្យបានត្រឹមត្រូវ ដល់ដើមបណ្តឹងឧទ្ធរណ៍អំពីបទចោទនានាលើ ខៀវ សំផន នោះទេ[៣៧]។ គាត់ក៏បានចោទប្រកាន់ថា JCE មិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក[៣៨] ទេ។ ជាចុងក្រោយ គាត់បានចោទប្រកាន់ថា ដីកាសម្រេចលើ JCE បង្កើត

[៣១] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ២ ក។

[៣២] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ២ ខ។ បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ លើកហេតុសំអាងស្រដៀងគ្នានេះនៅក្នុងមូលហេតុទី៥របស់ខ្លួន។

[៣៣] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ២ គ។

[៣៤] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ២ ឃ។

[៣៥] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ២ ង។

[៣៦] បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន កថាខណ្ឌ៤៥-៥១។

[៣៧] បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន កថាខណ្ឌ៥២-៥៥។

[៣៨] បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន កថាខណ្ឌ៥៦-៥៩ (ទទួលយកសារណាដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីផ្សេងទៀត និងសង្កត់ធ្ងន់ថា ដីកាដែលត្រូវបានជំទាស់ នៅក្នុងបរិបទនេះដែលប្រាសចាកពីមូលដ្ឋានច្បាប់គឺជា "សេចក្តីសម្រេចចិត្តតាមកាលានុវត្តភាព ដែលឆ្លើយតបទៅនឹងវត្ថុបំណងនៃការបង្ក្រាបជាក់ស្តែង" នាំឱ្យមានការរំលោភទៅលើ "គោលការណ៍មូលដ្ឋានច្បាប់ព្រហ្មទណ្ឌសំខាន់បំផុត" ដោយរួមទាំងគោលការណ៍នីត្យានុកូលភាព ក៏ដូចជា "ស្មារតីនិងបំណងនៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក" ផងដែរ។

ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌពីរថ្នាក់ រីឯក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងមាត្រា២៩ នៃច្បាប់ អ.វ.ត.ក ពុំបានយោងទៅលើរបបគតិយុត្តិពិសេសសម្រាប់បទល្មើសអន្តរជាតិ ច្បាប់គួរត្រូវបានបកស្រាយឱ្យសមស្រប និងបកស្រាយជាប្រយោជន៍ដល់ជនត្រូវចោទ[៣៩]។

៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ទម្រង់ទាំងបី នៃ JCE អាចយកទៅអនុវត្តបានចំពោះមុខ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មនានា ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ និងក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជាឆ្នាំ១៩៥៦។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា "ការទទួលខុសត្រូវ JCE មានចែងនៅក្នុងច្បាប់កម្ពុជាក្នុងឆ្នាំ១៩៥៦ ក្រោមពាក្យថា "*ការរួមប្រព្រឹត្ត និងការផ្សំគំនិត*" (coaction and complicité) និងយ៉ាងហោចណាស់បានរួមបញ្ចូលនូវទម្រង់ពីរដំបូង នៃ JCE"[៤០]។ ផ្អែកលើមូលដ្ឋាននេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើឱ្យបដិសេធចោលដីកាសម្រេចរបស់ ក.ស.ច.ស លើបញ្ហា JCE ដែលមានចែងនៅក្នុងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា[៤១]។

១០. នៅក្នុងចម្លើយតបរួម[៤២] ក.ស.ព "បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ បដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ ដោយសារតែបណ្តឹងនេះត្រូវបានហាមឃាត់តាមនីតិវិធីផង និងខ្វះខាតអង្គសេចក្តីផង ពីព្រោះ ១) "សហឧក្រិដ្ឋកម្មរួម គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៤០"។ ២) "វាអាចអនុវត្តបានចំពោះមុខ អ.វ.ត.ក ដោយសារតែតុលាការនេះមានកាតព្វកិច្ចកាត់ទោស

---

[៣៩] បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន កថាខណ្ឌ៦០-៧១។

[៤០] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចអនុវត្តបាននៃទំរង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១០ ឯកសារ D97/17/1 ("បណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ១០។

[៤១] បណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសល់មិនចាត់ទុកជាបណ្តឹងឧទ្ធរណ៍ទេ តែជាជាងជាការគាំទ្រដល់ដីការដែលត្រូវបានជំទាស់។

[៤២] តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានទទួលយកពាក្យសុំពន្យាពេល និងបន្ថែមចំនួនទំព័រកំណត់របស់សហព្រះរាជអាជ្ញា (ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ឯកសារ D97/15/2) ដោយអនុញ្ញាតិឱ្យព្រះរាជអាជ្ញាដាក់ចម្លើយតប ៤០ទំព័រ ត្រឹមថ្ងៃទី១៩ ខែកុម្ភៈ។ សេចក្តីសម្រេចលើសំណើសុំពន្យាពេល និងមន្ថែមចំនួនទំព័ររបស់សហព្រះរាជអាជ្ញាក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ខៀវ សំផន អៀង សារី និង ដើម្បណ្តឹងរដ្ឋប្បវេណីមួយចំនួនប្រឆាំងនឹងដីកាសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D97/16/4។

00519406



ឧក្រិដ្ឋកម្មអន្តរជាតិ និង [...]តុលាការនេះមានលក្ខណៈជាតុលាការអន្តរជាតិ" និង ៣) "ក្នុងនាមជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ សហឧក្រិដ្ឋកម្មរួមអាចអនុវត្តបានក្នុងប្រទេសកម្ពុជា ដោយមិនគិតថាតើមានឬមិនមានចែងក្នុងច្បាប់ជាតិនោះទេ"[៤៣]។

១១. នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេច អំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[៤៤] ដោយបង្គាប់ឲ្យសហមេធាវីការពារក្តីជនត្រូវចោទដាក់ការឆ្លើយតបរបស់ខ្លួន ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេលប្រាំ (៥) ថ្ងៃ។

១២. នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ មេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា[៤៥] ។

១៣. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ មេធាវីការពារក្តី អៀង សារី បានដាក់ "ការឆ្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និងខៀវ សំផន ស្តីពី JCE" ("ការឆ្លើយតបរបស់អៀង សារី")[៤៦]។

---

[៤៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D97/16/5 ("ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ៣។

[៤៤] សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្តីបង្គាប់ដាក់ការឆ្លើយតប ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១០ ឯកសារ D97/14/11 ។

[៤៥] ចម្លើយតបរបស់មេធាវីការពារក្តីចំពោះសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ឯកសារ D97/15/8 ("ចម្លើយតបរបស់អ្នកស្រី អៀង ធីរិទ្ធ")។

[៤៦] សូមមើល សេចក្តីសម្រេចលើសំណើសុំឲ្យមានការបន្ថែមពេលវេលាកំណត់ ដើម្បីដាក់ការឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ ឯកសារ D97/14/13 ទទួលយកការពន្យាពេលដែលស្នើសុំដោយលោក អៀង សារី។

១៤. នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ មេធាវីការពារក្តី ខៀវ សំផន បានដាក់ “” (“ការឆ្លើយតបរបស់ ខៀវ សំផន”)[៤៧]។

១៥. អនុលោមតាមសេចក្តីសម្រេចលើសំណើសុំពន្យារថិរវេលា[៤៨] នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ មេធាវីការពារក្តី អៀង សារី បានដាក់ការឆ្លើយតបរបស់ខ្លួន[៤៩]។

## III ការទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១៦. ជាបញ្ហាបឋម អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីជាបណ្តឹងឧទ្ធរណ៍ដែលដាក់ដោយ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ផ្អែកលើវិធាន៧៤(៣)(ក) ដែលអនុញ្ញាតឱ្យជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលលើកឡើងដោយបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ហាក់ដូចជាលើកឡើងនូវទឡ្ហីករណ៍ទាំងឡាយ ដែលអាចនឹងមិនទាក់ទងនឹងបញ្ហាយុត្តាធិការ។ ជាដំបូង នៅក្នុងមូលដ្ឋានទី២ និងទី៤-ទី៦ នៃបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តី អៀង ធីរិទ្ធ ចោទប្រកាន់ថា អ.វ.ត.ក មិនមានយុត្តាធិការលើ JCE ដែលជាទម្រង់នៃការទទួលខុសត្រូវក្នុងសំណុំរឿង០០២ ឬនិយាយម្យ៉ាងទៀត អ.វ.ត.ក មិនមានយុត្តាធិការអនុវត្តទម្រង់ទីបីនៃ JCE នៅក្នុងរឿងក្តីនេះឡើយ[៥០]។ ចំណុចទីពីរ មូលដ្ឋានទី១ និងទី៣ ចោទប្រកាន់ថា ក.ស.ព មិនបានសន្និដ្ឋានគ្រប់គ្រាន់ទាល់តែសោះនូវទម្រង់ទីមួយ និងទីបីនៃ JCE នៅក្នុងដីកា

---

[៤៧] សូមមើល សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេលដាក់ការឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ឯកសារ D97/16/8 ទទួលយកការពន្យារថិរវេលាដែលស្នើសុំដោយលោក ខៀវ សំផន។

[៤៨] សេចក្តីសម្រេចលើសំណើសុំឱ្យមានការបន្ថែមពេលវេលាកំណត់ ដើម្បីដាក់ការឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ ឯកសារ D97/14/13។

[៤៩] សារណាតបរបស់លោក អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ (សារណាតបរបស់លោក អៀង សារី) ឯកសារ D97/14/14។

[៥០] បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ កថាខណ្ឌ១។



ECCC * CETC PRE-TRIAL CHAMBER CHAMBRE

សន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ឬការបង្កើតទម្រង់ទីបីនៃ JCE នៅក្នុងដីកាដែលត្រូវបានជំទាស់ គឺមិនមានលក្ខណៈគ្រប់គ្រាន់ ហេតុដូច្នេះទម្រង់ទាំងនោះនៃ JCE មិនអាចយកមកអនុវត្តបាននៅក្នុងសំណុំរឿង០០២ទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១ និងទី៣ នៃបណ្តឹងឧទ្ធរណ៍ មិនបានតវ៉ាលើបញ្ហាយុត្តាធិការទេ ប៉ុន្តែបែរជាលើកបញ្ហាថាតើជនត្រូវចោទបានទទួល ឬមិនបានទទួលការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទទៅវិញ។

១៧. ក.ស.ព បានលើកឡើងអញ្ញត្រកម្មចំនួនប្រាំទាក់ទងនឹងបណ្តឹងឧទ្ធរណ៍[៥១] ដែលអង្គបុរេជំនុំជម្រះនឹងពិចារណាម្តងមួយៗ[៥២]។

## ក. តើដីកាដែលត្រូវបានជំទាស់ មានតម្លៃស្មើនឹង "ដីកា" ឬ "សេចក្តីសម្រេច" ឬក៏គ្រាន់តែជា "សេចក្តីប្រកាស" តែប៉ុណ្ណោះ?

១៨. អនុលោមតាមវិធាន៧៤(៣) ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងលើដីកា ឬសេចក្តីសម្រេច ចំនួនប្រាំបួនប្រភេទ ដែលសម្រេចដោយក.ស.ច.ស។ នៅក្នុងករណីនេះ ក.ស.ព បានបដិសេធពីដំបូងថា ដីកាដែលត្រូវបានជំទាស់មិនមែនជាប្រភេទ "ដីកា" ឬ "សេចក្តីសម្រេច" ឡើយ ប៉ុន្តែពួកគាត់បានលើកឡើងថា វាគ្រាន់តែជាប្រភេទ "សេចក្តីប្រកាស" នៃច្បាប់ជាធរមាន ដែលធ្វើឡើងដើម្បីឆ្លើយតបទៅនឹងបណ្តឹងដែលដាក់ដោយមេធាវីការពារក្តី អៀង សារី។ បណ្តឹងនោះបានលើកឡើងថា ក.ស.ច.ស ប្រកាសថា ការទទួលខុសត្រូវនៃ JCE មិនអាចយកមកអនុវត្តបាននៅចំពោះមុខ

[៥១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤-២២ លើកឡើងនូវការជំទាស់ខាងក្រោម ចំពោះភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍៖ បើទោះជាការប្រកាស JCE ត្រូវបានចាត់ទុកថាជាដីកាក៏ដោយ ១) "វាមិនបានបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក ហើយដូច្នេះ មិនអាចប្តឹងឧទ្ធរណ៍បានទេ" អនុលោមតាមវិធាន ៧៤(៣)(ក) ២) "វាមិនបានបដិសេធលើសំណើបំពេញកិច្ចស៊ើបសួរណាមួយទេ ហើយដូច្នេះ មិនអាចប្តឹងឧទ្ធរណ៍បានទេ" ៣) "វាមិនរំលោភលើសិទ្ធក្នុងការទទួលបានការជំនុំជម្រះទោសប្រកបភាពយុត្តិធម៌ឡើយ ហើយដូច្នេះ មិនអាចប្តឹងឧទ្ធរណ៍បានទេ អនុលោមតាម វិធាន ២១" និង ៤) "ការបដិសេធបណ្តឹងឧទ្ធរណ៍នឹងជួយជំរុញសេដ្ឋកិច្ចខាងនីតិវិធី"។

[៥២] អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើចំណុចនៃការឆ្លើយតបទាក់ទិនទៅនឹង ចម្លើយតបរួមរបស់ ក.ស.ព ដែលបានលើកឡើងក្នុងការឆ្លើយតបរបស់ អៀង ធីរិទ្ធ។

អ.វ.ត.ក[៥៣] ទេ។ យោងតាម ក.ស.ព "សេចក្ដីប្រកាស" ធ្វើឡើងដើម្បីធានានូវការជូនដំណឹងឱ្យបានគ្រប់គ្រាន់ចំពោះភាគីនានា ហើយសេចក្ដីប្រកាសនេះមិនអាចប្ដឹងឧទ្ធរណ៍បានទេ[៥៤]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍បែបនេះហាក់ដូចជាមិនសមស្របទេ។ ជាការពិត មិនត្រឹមតែចំណងជើងនៃដីកាដែលត្រូវបានជំទាស់បញ្ជាក់ថា វាជាប្រភេទ "ដីកា" នោះទេ សូម្បីតែខ្លឹមសាររបស់វា ក៏សំដៅដោះស្រាយបញ្ហាការអនុវត្ត JCE ដែលជាទម្រង់នៃការទទួលខុសត្រូវចំពោះមុខ អ.វ.ត.ក ដែរ[៥៥]។ អាស្រ័យហេតុនេះ ទម្រង់ និងខ្លឹមសារនៃដីកាសម្រេចលើ JCE បង្ហាញថា ដីកាដែលត្រូវបានជំទាស់នេះ មានតម្លៃលើសពី "សេចក្ដីប្រកាស" ហើយវាមានតម្លៃស្មើនឹង "ដីកា" ឬ " សេចក្ដីសម្រេច" ដែលមានចែងនៅក្នុងវិធាន៧៤ នៃវិធានផ្ទៃក្នុង។

## ខ. តើដីកាដែលត្រូវបានជំទាស់ អាចប្ដឹងឧទ្ធរណ៍បានដែរឬទេ អនុលោមតាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង?

១៩. អនុលោមតាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍លើដីកា ឬសេចក្ដីសម្រេចរបស់ ក.ស.ច.ស ទាក់ទងនឹងការបញ្ជាក់យុត្តាធិការនៃ អ.វ.ត.ក។

២០. មូលដ្ឋានទី២ និង៤-៦ នៃបណ្ដឹងឧទ្ធរណ៍ ចោទប្រកាន់ថា ក.ស.ច.ស ភាន់ច្រឡំក្នុងការសម្រេចថា ទម្រង់ទាំងបី នៃ JCE អាចអនុវត្តបាននៅ អ.វ.ត.ក ពីព្រោះអង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការអនុវត្ត JCE ដែលជាទម្រង់ទទួលខុសត្រូវ ហើយម្យ៉ាងវិញទៀតមិនអាចអនុវត្ត*ទម្រង់ជាប្រព័ន្ធ* និង*ទម្រង់ទូលាយ* នៃ JCE (JCE II និង JCE III) បានឡើយ។ អនុលោមតាមដើមបណ្ដឹងឧទ្ធរណ៍ វិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដែលចែងថា ជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ទាក់ទងនឹងការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក បានផ្ដល់នូវមូលដ្ឋានផ្នែកច្បាប់សម្រាប់បណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន។ អង្គបុរេជំនុំជម្រះយល់ឃើញថា ដើមបណ្ដឹងឧទ្ធរណ៍ចាត់

---

[៥៣] អង្គបុរេជំនុំជម្រះ បដិសេធពាក្យសុំដែលបានធ្វើឡើងក្នុងនាម អៀង ធីរិទ្ធ ដែលថា ក.ស.ព ត្រូវតែបញ្ឈប់លើកឡើងនូវអំណះអំណាងបែបនេះ។ ចម្លើយតបរបស់លោកស្រី អៀង ធីរិទ្ធ កថាខណ្ឌ ៦។

[៥៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥-៦។

[៥៥] សូមមើល ជាពិសេស ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៨-២១។

ទុកដីកាដែលត្រូវបានជំទាស់ ជា"ដីកាបញ្ជាក់យុត្តាធិការនៃ អ.វ.ត.ក" ដោយរកឃើញថា JCE ទាំងបីទម្រង់អនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែលចោទប្រកាន់។

២១. ក.ស.ព មិនបានលើកទឡ្ហីករណ៍ថា ការអនុវត្តទម្រង់ទទួលខុសត្រូវ JCE ចំពោះមុខ អ.វ.ត.ក មិនមានតម្លៃស្មើនឹងបណ្តឹងជំទាស់យុត្តាធិការនោះទេ។ ផ្ទុយមកវិញ ក.ស.ព យល់ឃើញថា "ប្រសិនបើចោទប្រកាន់ជនត្រូវចោទពាក់ព័ន្ធនឹងការទទួលខុសត្រូវ JCE ដើមបណ្តឹងឧទ្ធរណ៍នឹងនៅតែមានមូលហេតុដែលមានសុពលភាព ដើម្បីដាក់បណ្តឹងជំទាស់យុត្តាធិការទៅអង្គជំនុំជម្រះសាលាដំបូងយោងតាមមាត្រា៨៩(១)"[៥៦]។ ទោះបីជាយ៉ាងណាក៏ដោយ ក.ស.ព *បដិសេធ*បណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានថា ដីកាដែលត្រូវបានជំទាស់ មិនបាន "បញ្ជាក់អំពីយុត្តាធិការរបស់អ.វ.ត.ក" ទាក់ទងនឹងបញ្ហាណាមួយនោះទេ[៥៧]។ មុនពេលពិចារណាលើទឡ្ហីករណ៍នេះ អង្គបុរេជំនុំជម្រះត្រូវតែកំណត់ថាតើបណ្តឹងជំទាស់ការអនុវត្តJCE ចំពោះមុខ អ.វ.ត.ក បច្ចុប្បន្ន ពិតជាមានតម្លៃស្មើនឹងបណ្តឹងជំទាស់យុត្តាធិការ ឬយ៉ាងណា។ ប្រសិនបើវាមិនមានតម្លៃស្មើនឹងបណ្តឹងជំទាស់យុត្តាធិការទេ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលមានបញ្ហានេះ មិនអាចប្តឹងឧទ្ធរណ៍បានឡើយតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដោយមិនចាំបាច់ពិនិត្យការជំទាស់របស់ ក.ស.ព។

២២. អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងជំទាស់យុត្តាធិការនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលជាតិ មិនបានរួមបញ្ចូលអត្ថិភាព និងភាពអាចអនុវត្តបាននូវទម្រង់នៃការទទួលខុសត្រូវនោះទេ។ នេះគឺជាបញ្ហាពីព្រោះទម្រង់នៃការទទួលខុសត្រូវមានចែង និងកំណត់និយមន័យយ៉ាងច្បាស់។ ទម្រង់នៃការទទួលខុសត្រូវមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ហើយក្នុងករណីដែលក្រមនេះមិនមានចែងនូវនិយមន័យលម្អិតទេ ក៏យុត្តិសាស្ត្រដែលវិវត្តន៍ជាយូរយារមកហើយនោះ មានចែងអំពីធាតុផ្សំរបស់ទម្រង់នៃការទទួលខុសត្រូវ។ នៅក្នុងច្បាប់កម្ពុជា ក៏ដូចជានៅក្នុងច្បាប់បារាំង តុលាការត្រូវតែរកឲ្យឃើញថាតើតុលាការមានយុត្តាធិការពេលវេលា និងយុត្តាធិការដែនដី ចំពោះអង្គហេតុនានាដែលលើកឡើងចំពោះមុខតុលាការ ព្រមទាំងយុត្តាធិការលើកម្មវត្ថុចំពោះបទចោទនានាដែលត្រូវបានចោទប្រកាន់ដែរឬទេ។ តុលាការត្រូវតែប្រកាសថាខ្លួនមិនមានសមត្ថកិច្ច នៅពេលដែលទទួលបានបណ្តឹងពាក់ព័ន្ធ

[៥៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦។

[៥៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧-៩។

នឹងបទចោទនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការជាន់ខ្ពស់។ ផ្ទុយមកវិញ បញ្ហាយុត្តាធិការ មិនបានរួមបញ្ចូលបញ្ហាជម្លោះ ឬជំទាស់ទៅនឹងភាពអាចអនុវត្តបាននូវទម្រង់នៃការទទួលខុសត្រូវ ដែលនឹងត្រូវពិចារណា នៅពេលក្រោយដោយអង្គជំនុំជម្រះសាលាដំបូង។ ស្ថាប័នតុលាការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") មិនបានចាត់ទុកការប្តឹងជំទាស់ប្រឆាំងនឹងអត្ថិភាពរបស់ទម្រង់នៃការទទួលខុសត្រូវ គឺជាបញ្ហាយុត្តាធិការនោះទេ។ នេះធ្វើឱ្យយើងយល់ដឹងអំពីភាពទូលំទូលាយនៃមាត្រា២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលចែងអំពីនិយមន័យទម្រង់នៃការទទួលខុសត្រូវ និងអង្គហេតុដែលថា លក្ខន្តិកៈទីក្រុងរ៉ូម អនុវត្តតែលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត ក្រោយពេលលក្ខន្តិកៈចូលជាធរមានតែប៉ុណ្ណោះ។

២៣. ដូចដែលបានលើកឡើងខាងលើ ស្ថានភាពមានលក្ខណៈខុសគ្នានៅតុលាការ *មិនអចិន្ត្រៃយ៍*នានា។ នៅក្នុងស្ថាប័នតុលាការនីមួយៗ បណ្តឹងជំទាស់ទាក់ទងនឹងបញ្ហាជាក់លាក់មួយចំនួននៃបទល្មើសសំខាន់មួយ[៥៨] ឬទម្រង់នៃការទទួលខុសត្រូវ គឺជាបញ្ហាដែលត្រូវដោះស្រាយនៅតុលាការ[៥៩]។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តឹងជំទាស់អត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវ ឬការទទួលស្គាល់

---

[៥៨] ប្រៀបធៀបនឹង រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Delalic, Mucić, Delić, និង Landžo*, IT-96-21-AR72.5, សេចក្តីសម្រេចលើពាក្យសុំអនុញ្ញាតប្តឹងឧទ្ធរណ៍ ដោយ Hazim Delić (វិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៦ កថាខណ្ឌ ២៧ (សម្រេចថា ការខ្វែងគំនិតគ្នាមួយណាអំពីសារធាតុនៃបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងមាត្រា ២, ៣, ៤ និង ៥ នៃច្បាប់លក្ខន្តិកៈ "គឺជាបញ្ហាសម្រាប់ការជំនុំជម្រះទោស មិនមែនសម្រាប់ ការជំទាស់មុនការជំនុំជម្រះទោសឡើយ") ។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Furundžija* សំណុំរឿងលេខ IT-05-17/1-T, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៧២-១៨៦ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kunarac, Kovač, and Vuković* សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ ("សាលក្រមលើរឿងក្តី *Kunarac*") កថាខណ្ឌ ៤៣៦-៤៦០ (សេចក្តីបញ្ជាក់របស់សាលក្រម អំពីរូបភាពនៃបទរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមមាត្រា ៥(ឆ) នៃច្បាប់លក្ខន្តិកៈ)។

[៥៩] ប្រៀបធៀបនឹង រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blaškić*, IT-95-14-A សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ ("សាលដីកាលើរឿងក្តី *Blaškić*") កថាខណ្ឌ ៣២-៤២ (សេចក្តីបញ្ជាក់របស់សាលដីកា អំពីរូបភាពនៃធាតុផ្សំអត្តនោម័តនៃ "ការបញ្ជា" ក្រោមមាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈ។ ផងដែរ សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Milutinović និងអ្នកផ្សេងទៀត* IT-05-87-PT សេចក្តីសម្រេចលើញត្តិជំទាស់នឹងយុត្តាធិការ – ការរួមប្រព្រឹត្តដោយផ្ទាល់ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ ("សេចក្តីសម្រេចលើការរួមប្រព្រឹត្តរបស់ *Ojdanić*") កថាខណ្ឌ ២៣។

ទម្រង់នោះតាមច្បាប់ទំនៀមទម្លាប់នៅពេលដែលចោទប្រកាន់ ត្រូវបានចាត់ទុកថាជាបណ្តឹងជំទាស់យុត្តាធិការ និងអាចលើកឡើងនៅក្នុងសំណើសុំស្តីពីអាញ្ញត្រកម្ម ក្នុងអំឡុងពេលមុនដំណាក់កាលនៃដំណើរការនីតិវិធីជំនុំជម្រះ និងបើកផ្លូវប្តឹងឧទ្ធរណ៍។ ជាក់ស្តែង វិធាននីតិវិធីនិងភស្តុតាងបច្ចុប្បន្នរបស់តុលាការ *មិនអចិន្ត្រៃយ៍*នានា បានចាត់ទុកថាការជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋានដែលថា ដីកាមិនបានលើកឡើងពាក់ព័ន្ធនឹងទម្រង់ណាមួយ នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលមានចែងនៅក្នុងមាត្រា៧ នៃលក្ខន្តិកៈតុលាការ ICTY និងមាត្រា៦ នៃលក្ខន្តិកៈតុលាការ ICTR គឺជាការជំទាស់ទៅនឹងយុត្តាធិការ[៦០]។ អាស្រ័យហេតុនេះ យុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍*ទាំងពីរ គឺច្បាស់ណាស់ដែលថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទប្តឹងទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវ រួមមានការចូលរួមរបស់ជនជាប់ចោទនៅក្នុង JCE មិនស្ថិតនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដូច្នេះប្តឹងនេះមានចរិតលក្ខណៈជាបណ្តឹងជំទាស់យុត្តាធិការ។ ដូច្នេះ បណ្តឹងជំទាស់បែបនេះ អាចចាត់ទុកថាជាសំណើសុំស្តីពីអញ្ញាត្រកម្ម នៅក្នុងអំឡុងពេលនៃដំណាក់កាលមុនពេលជំនុំជម្រះ[៦១]។ ប្រសិនបើមានដូចករណីនេះ វាមិនមែនត្រឹមតែពាក្យពេចន៍ទូលាយដែលប្រើប្រាស់នៅក្នុងមាត្រា៧ នៃលក្ខន្តិកៈ

---

[៦០] សូមមើល វិធាននៃនីតិវិធី និងភស្តុតាង វិធាន ៧២(ឃ)(iv) ("សម្រាប់គោលបំណងនៃកថាខណ្ឌ (ក)(i) និង (ខ)(i) ញត្តិជំទាស់យុត្តាធិការយោងទាំងស្រុងទៅលើញត្តិដែលជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបង្ហាញមូលហេតុថា វាមិនទាក់ទិនទៅនឹង : [...] (iv) ការរំលោភណាមួយឡើយដែលមានចែងនៅក្នុងមាត្រា [...] ៧ នៃច្បាប់លក្ខន្តិកៈ")។ វិធាន ៧២(ឃ)(iv) នៃវិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR ចែងនូវបទប្បញ្ញត្តិស្រដៀងគ្នានេះដែរ។

[៦១] សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Ojdanić* កថាខណ្ឌ ៥ ដោយយោងទៅលើរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Milutinović, Šainović, និង Ojdanić*, IT-99-37-AR72, សេចក្តីសម្រេចរបស់អង្គចៅក្រម អនុលោមតាមវិធាន ៧២(ង) អំពីសុពលភាពនៃបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៣ ទំព័រ ៣ (អង្គចៅក្រមតុលាការកំពូលសម្រេច ថា បណ្តឹងឧទ្ធរណ៍របស់ Ojdanić's បានដាក់ដោយមានសុពលភាព ក្នុងវិសាលភាពដែលបណ្តឹងឧទ្ធរណ៍នោះជំទាស់ទៅនឹងយុត្តាធិការរបស់តុលាការ ទាក់ទិនទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ចំពោះការចូលរួមដែលត្រូវបានចោទប្រកាន់ក្នុង JCE)។ សេចក្តីសម្រេចអំពីការរួមប្រព្រឹត្តក្នុងរឿងក្តី *Accord Ojdanić* កថាខណ្ឌ២៣។ ផងដែរ សូមមើលរឿងក្តី *Rwamakuba* ទល់នឹងរដ្ឋអាជ្ញា ICTR-98-44-AR72.4 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំស្តីពីការអនុវត្តសហឧក្រិដ្ឋកម្មរួមចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ ("សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Rwamakuba*") កថាខណ្ឌ ៣,៥,៣១។

ICTY និងមាត្រា៦ នៃលក្ខន្តិកៈICTR ប៉ុន្តែក៏វាដោយសារតែអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចថា៖

> "ដរាបណាមានការពាក់ព័ន្ធនឹងយុត្តាធិការលើ *បុគ្គល* របស់តុលាការ របាយការណ៍របស់អគ្គលេខាធិការ មិនមានលើកឡើងអំពីការកំណត់ច្បាស់ណាមួយចំពោះប្រភេទនៃច្បាប់ដែលតុលាការអាចយកមកអនុវត្ត ជាជាងសេចក្តីថ្លែងការណ៍យ៉ាងច្បាស់អំពីការអនុវត្តទូទៅចំពោះអនុភាពដែលថា "តុលាការអន្តរជាតិមានភារកិច្ចអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិដែលមានស្រាប់" [...]។ ទោះបីជាយ៉ាងក៏ដោយ គោលការណ៍នីត្យានុកូលភាព តម្រូវឱ្យតុលាការអនុវត្តច្បាប់ជាធរមាន ចំពោះអំពើដែលចោទប្រកាន់ជនជាប់ចោទនៅពេលនោះ។ ចំពោះករណីទាក់ទងនឹងយុត្តាធិការ *កម្មវត្ថុ* របស់តុលាការ វិធានច្បាប់ត្រូវតែអនុវត្តតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[១២]។

មានបណ្តឹងជំទាស់ជាច្រើនទៅនឹងយុត្តាធិការរបស់តុលាការ ICTY ពីសំណាក់ជនត្រូវចោទ ដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចំពោះយុត្តាធិការរបស់តុលាការ ICTY លើទម្រង់នៃការទទួលខុសត្រូវ ដូចជា JCE និងការទទួលខុសត្រូវរបស់ថ្នាក់លើ។ បណ្តឹងឧទ្ធរណ៍បែបនោះ ជារឿយៗផ្អែកលើទឡ្ហីករណ៍ដែលថា ទម្រង់នៃការទទួលខុសត្រូវទាំងនេះ មិនមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលពាក់ព័ន្ធ ឬមិនអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាក់លាក់មួយ ហើយការអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវ នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព។ យុត្តិសាស្ត្ររបស់តុលាការ ICTY បានទទួលយកបណ្តឹងទាំងនេះថាជាបណ្តឹងជំទាស់យុត្តាធិការ។

២៤. ចំពោះថាតើភាពអាចអនុវត្តបាននូវ JCE ចំពោះមុខ អ.វ.ត.ក មានតម្លៃស្មើនឹងបណ្តឹងជំទាស់យុត្តាធិការ អង្គបុរេជំនុំជម្រះយល់ឃើញថា អ.វ.ត.ក ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានឹងតុលាការ *មិនអចិន្ត្រៃយ៍* នានា។ អង្គបុរេជំនុំជម្រះនាពេលនេះនឹងពិចារណាលើការជំទាស់របស់ ក.ស.ព ដែលថា "ដីកាសម្រេចដែលត្រូវបានជំទាស់ មិនបាន "បញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.

[១២] សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Ojdanić* កថាខណ្ឌ ១០។

00519414



ត.ក" ទាក់ទងនឹងបញ្ហាណាមួយទេ"[៦៣]។ ទោះបីជាវាត្រឹមត្រូវដែលថា ដីកាសម្រេចដែលត្រូវបានជំទាស់ មិនបានបញ្ជាក់ច្បាស់ថា អ.វ.ត.ក មានយុត្តាធិការអនុវត្តទម្រង់នៃការទទួលខុសត្រូវ JCE ក៏ដោយ ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាសម្រេចនេះបានបង្កប់ន័យអំពីការបញ្ជាក់យុត្តាធិការ។ ដីកាសម្រេចនេះ បានផ្អែកយ៉ាងច្បាស់លើយុត្តិសាស្ត្ររបស់តុលាការ ICTY ដែលចាត់ទុកថាជាបញ្ហាយុត្តាធិការ ចំពោះបញ្ហាថាតើទម្រង់នៃការទទួលខុសត្រូវ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ឬយ៉ាងណា[៦៤]។

២៥. អង្គបុរេជំនុំជម្រះយល់ឃើញថា ពាក់ព័ន្ធនឹងមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ ទី២ និង ទី៤-៧ ដីកាដែលត្រូវបានជំទាស់ អាចប្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[៦៥]។ អង្គបុរេជំនុំជម្រះនឹងពិចារណាការជំទាស់របស់សហព្រះរាជអាជ្ញាដែលថា ដីកាដែលត្រូវបានជំទាស់ មិនអាចប្ដឹងឧទ្ធរណ៍តាមវិធាន៧៤(៣)(ខ)។

## គ. <u>តើដីកាដែលត្រូវបានជំទាស់ អាចប្ដឹងឧទ្ធរណ៍តាមវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុងដែរឬទេ?</u>

២៦. ក.ស.ព បដិសេធការទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលត្រូវបានជំទាស់ដែលធ្វើឡើងតាមវិធាន៧៤(៣)(ខ) ដោយសារតែដីកាសម្រេចនេះ មិនបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរណាមួយឡើយ (ដែលមានចែងនៅក្នុងវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង)[៦៦] ប៉ុន្តែវាជាសំណើសុំ "ឲ្យសហចៅក្រមស៊ើបអង្កេត ឬអ្នកតំណាងរបស់គេ ធ្វើការងារដែលមានគោល

---

[៦៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧-៩។

[៦៤] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៩-២១ យោងទៅលើសេចក្ដីសម្រេចអំពីការរួមប្រព្រឹត្តក្នុងរឿងក្ដី *Ojdanić* កថាខណ្ឌ ៣៧។

[៦៥] អង្គបុរេជំនុំជម្រះកត់សម្គាល់ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៨-១២។

[៦៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០-១៣។

បំណងប្រមូលព័ត៌មាន ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិតលើអង្គហេតុ ដូច ដែលបានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ”[១៧]។

២៧. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន៧៤(៣)(ក) ដែលដើមបណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ យកមកសម្អាងជាមូលដ្ឋានច្បាប់សម្រាប់បណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ គឺមានលក្ខណៈមិនគ្រប់គ្រាន់ចំពោះមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទី១ និងទី៣ ដោយសារតែបញ្ហាដែលដើមបណ្តឹងឧទ្ធរណ៍លើកឡើងថា តើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសម្រេចលើ JCE ផ្តល់នូវការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទប្រឆាំងនឹងដើមបណ្តឹងឧទ្ធរណ៍ចំពោះ JCE I និង III ច្បាស់ណាស់គឺវាមិនមែនជាបញ្ហាយុត្តាធិការនោះទេ។

២៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីសំណើសុំដែលត្រូវបានសម្រេចដោយដីកាសម្រេចដែលត្រូវបានជំទាស់ ត្រូវបានដាក់ដោយភាន់ច្រឡំដោយមេធាវីការពារក្តី អៀង សារី ក្រោមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតសម្រេច *“ដោយតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់* (proprio motu) ធ្វើការពិចារណាសំណើសុំនេះ ដោយយោងទៅលើវិធានផ្ទៃក្នុងដែលត្រឹមត្រូវ គឺវិធាន ៥៥(១០)នៃ[វិធានផ្ទៃក្នុង]”[១៨]។ បទប្បញ្ញត្តិនេះ ផ្តល់ឱ្យភាគីពាក់ព័ន្ធនានាអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត “ចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាចាំបាច់ដល់ការស៊ើបសួរ”។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីអង្កេតបឋមស្តីពី JCE របស់ អៀង ធីរិទ្ធ លើកទឡ្ហីករណ៍ថា ទម្រង់ទីមួយ និងទីបី នៃ JCE មិនមានសន្និដ្ឋានគ្រប់គ្រាន់ទាល់តែសោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ករណីនេះ នឹងនាំឱ្យមានការរំលោភបំពានលើសិទ្ធិរបស់ជនត្រូវចោទទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់ ដូច្នេះទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះ មិនត្រូវរាប់បញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

---

[១៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២ យោងទៅលើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/I/20 (“សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការបកប្រែ”) កថាខណ្ឌ ២៨។

[១៨] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ៨ កត់សម្គាល់ថា វិធានផ្ទៃក្នុង ៥៣(១) ពិភាក្សាអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយ ក.ស.ព។

ទេ[៦៩]។ អង្គបុរេជំនុំជម្រះចាត់ទុកសារណានេះ មានតម្លៃស្មើនឹងសំណើដែលស្នើឱ្យ ក.ស.ច.ស ចេញដីកាដែលមេធាវីការពារក្តី អៀង ធីរិទ្ធ យល់ឃើញថាចាំបាច់ដល់ការស៊ើបសួរ ដោយសារវានឹងផ្តល់ឱ្យជនត្រូវចោទនូវការជូនដំណឹងគ្រប់គ្រាន់ អំពីទម្រង់នៃការទទួលខុសត្រូវ ដែលចោទប្រកាន់មកលើខ្លួន។ ទោះបីជា ក.ស.ច.ស យល់ឃើញថា វាចាំបាច់ដើម្បីឱ្យខ្លួនឆ្លើយតបទៅនឹងសំណើចំពោះមុខពួកគាត់ (អង្គបុរេជំនុំជម្រះយល់ដឹងថាមានទាំងខ្លឹមសារក្នុងសារណាដែលបានលើកឡើងខាងលើរបស់ អៀង ធីរិទ្ធ ផងនោះក៏ដោយ) ក៏គោលបំណងនៃចម្លើយតបរបស់ ក.ស.ច.ស ក្នុងបញ្ហានេះ គឺផ្តល់ការជូនដំណឹងគ្រប់គ្រាន់ទាក់ទងនឹងការទទួលខុសត្រូវ ដែលមិនមានចែងច្បាស់នៅក្នុងច្បាប់ ឬកិច្ចព្រមព្រៀង។ ក.ស.ច.ស ទទួលយកដោយផ្អែកនូវសំណើសុំដែលធ្វើមកនេះ ដោយហេតុថា*ធាតុផ្សំអត្តនោម័ត*នៃ JCE III ដែលអាចត្រូវអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក គឺមានតែការទទួលយកជាអត្តនោម័តនៃផលវិបាកជាធម្មជាតិ និងផលវិបាកដែលគេមើលឃើញយ៉ាងច្បាស់នៃការអនុវត្តផែនការរួមតែប៉ុណ្ណោះ[៧០]។

២៩. អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយ ពាក់ព័ន្ធនឹងបរិបទបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ខៀវ សំផន ស្តីពីភាពមិនស្របគ្នាដែលអាចមានរវាងវិធាន៧៤(៣)(ខ)[៧១]និងវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ដោយយោងតាមដើមបណ្តឹងឧទ្ធរណ៍ វិធាននេះនឹងផ្តល់ឱ្យជនត្រូវចោទនូវសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះដីការបស់ ក.ស.ច.ស ដែលសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ និងដីកាទាំងឡាយណាដែលបដិសេធសំណើសុំចេញដីកាដែលចាំបាច់សម្រាប់កិច្ចស៊ើបអង្កេត[៧២]។ អង្គបុរេជំនុំជម្រះសម្រេចថា "ភាពមិនស៊ីគ្នាដែលអាចកើតចេញមកពីលទ្ធភាពទូទៅក្នុងការប្តឹងឧទ្ធរណ៍ ដែល

---

[៦៩] សេចក្តីសន្និដ្ឋានរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣០-៣១។

[៧០] ដីកាដែលត្រូវបានជំទាស់ សេចក្តីប្រកាសអនុម័ត បដិសេធយ៉ាងដាច់ខាតនូវសំណើ ក្នុងវិសាលភាពអំពើឧក្រិដ្ឋ និងចេតនាឧក្រិដ្ឋសម្រាប់ JCE I និង II និងអំពើឧក្រិដ្ឋសម្រាប់ JCE III។

[៧១] កំណត់លទ្ធភាពសម្រាប់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍លើដីការបស់ ក.ស.ច.ស បដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនៅចំពោះមុខអង្គបុរេជំនុំជម្រះ។

[៧២] សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីការប្រើប្រាស់ចម្លើយសារភាពដែលទទួលបាន ឬអាចទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ D130/10/12 កថាខណ្ឌ ១៤-១៧។

បានលើកឡើង ស្របតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង និងលទ្ធភាពដែលមានដែនកំណត់ក្នុងការប្ដឹងឧទ្ធរណ៍សម្រាប់ជនត្រូវចោទ ស្របតាមវិធាន៧៤(៣)(ខ) មិនអាចនាំឲ្យមានសេចក្ដីសន្និដ្ឋាន ដូចដែលបានធ្វើដោយសហមេធាវីការពារក្ដីស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នេះឡើយ”[៧៣]។ ដោយបានពិនិត្យមើលមូលដ្ឋាននៃបណ្ដឹងមុនពេលជំនុំជម្រះ ដែលមានចែងនៅក្នុងវិធាន៥៥(១០) និងវិធាន៧៤(៣) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ណាមួយ ចែងពិតប្រាកដអំពីមូលដ្ឋានច្បាប់ចំពោះបណ្ដឹងឧទ្ធរណ៍មុនពេលជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋានថា មានភាពខ្វះខាតក្នុងការជូនដំណឹង។ ដូច្នេះ អង្គបុរេជំនុំជម្រះទទួលយកសេចក្ដីសន្និដ្ឋានជំទាស់ទីបីរបស់សហព្រះរាជអាជ្ញា និងបែរមកពិចារណាមើលសេចក្ដីសន្និដ្ឋានជំទាស់ទីបួនរបស់ ក.ស.ព ដែលថា ដីកាសម្រេចដែលត្រូវបានជំទាស់ មិនបានរំលោភសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយ “អង្គហេតុ និងកាលៈទេសៈនៃបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន មិនតម្រូវឲ្យអង្គបុរេជំនុំជម្រះចាំបាច់ត្រូវទទួលយកនូវការបកស្រាយទូលំទូលាយចំពោះវិធាន៧៤(៣)” បើយោងតាមវិធាន២១[៧៤]។

## ឃ. <u>តើអង្គហេតុ និងកាលៈទេសៈនៃបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន តម្រូវឲ្យទទួលយកនូវការបកស្រាយទូលំទូលាយចំពោះវិធាន៧៤(៣) ដើម្បីធានាថា ដំណើរការនីតិវិធីលើជនត្រូវចោទមានលក្ខណៈយុត្តិធម៌ដែរឬទេ?</u>

៣០. វិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង ចែង (មួយផ្នែក) ថា “(...) ជនណា [ដែលត្រូវសង្ស័យ ឬត្រូវបានចោទប្រកាន់] មានសិទ្ធិទទួលដំណឹងអំពីបទល្មើស ដែលចោទប្រកាន់ចំពោះខ្លួន (...)”។ អង្គ

---

[៧៣] ដូចសេចក្ដីយោងខាងលើ កថាខណ្ឌ ១៧។

[៧៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤-១៥។ ពួកគាត់លើកទឡ្ហីករណ៍ជាពិសេសថា នាពេលនេះការសម្រេចអំពីបញ្ហាដែលលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍អាចគ្រាន់តែជា “ទ្រឹស្ដីប៉ុណ្ណោះ” ពីព្រោះដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចមិនបានដាក់បញ្ចូលនូវការទទួលខុសត្រូវ JCE ហើយថា មេធាវីការពារក្ដីគ្រប់កាលៈទេសៈទាំងអស់ នៅតែមានឱកាសដាក់បណ្ដឹងជំទាស់យុត្តាធិការទៅអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៨៩(១)។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥-១៦។

បុរេជំនុំជម្រះនឹងពិចារណាថាតើអង្គហេតុនានា និងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍បច្ចុប្បន្នតម្រូវឲ្យទទួលយកនូវការបកស្រាយទូលំទូលាយចំពោះសិទ្ធិរបស់ជនត្រូវចោទ ដើម្បីប្តឹងឧទ្ធរណ៍ដើម្បីធានាថាដំណើរការនីតិវិធីមានលក្ខណៈយុត្តិធម៌ដែរឬយ៉ាងណា។

៣១. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន៥៣ និងវិធាន៦៧ នៃវិធានផ្ទៃក្នុង ចែងអំពីក្របខណ្ឌផ្នែកច្បាប់ទាក់ទងនឹងការជូនដំណឹងជនត្រូវចោទអំពីការចោទប្រកាន់លើរូបគាត់។ ជាក់ស្តែង វិធាន៥៣ នៃវិធានផ្ទៃក្នុង តម្រូវឲ្យសហព្រះរាជអាជ្ញារួមបញ្ចូលក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ អំពីព័ត៌មានសេចក្តីសង្ខេបអំពីអង្គហេតុ ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងដាក់ទោសលើបទឧក្រិដ្ឋទាំងនេះ និងដាក់នូវសំណុំរឿង និងសម្ភារៈដទៃទៀតដែលមានតម្លៃជាភស្តុតាងដែលសហព្រះរាជអាជ្ញាមាន[៧៥]។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("CPC") ចែងអំពីបទប្បញ្ញត្តិស្រដៀងគ្នានេះនៅក្នុងមាត្រា៤៤។ លើសពីនេះ វិធាន៦៧(២) នៃវិធានផ្ទៃក្នុង ចែងថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវរៀបរាប់អំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយ ក.ស.ច.ស ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងនូវបទប្បញ្ញត្តិស្រដៀងគ្នានេះ នៅក្នុងមាត្រា២៤៧។ វិធានផ្ទៃក្នុង និង CPC មិនមានចែងអំពីការចង្អុលបង្ហាញបន្ថែមអំពីរបៀប ដែលដីកាដំណោះស្រាយគួរត្រូវផ្តល់សំអាងហេតុទេ។ នៅក្នុងកាលៈទេសៈបែបនេះ អង្គបុរេជំនុំជម្រះនឹងអនុវត្តនូវបទដ្ឋានអន្តរជាតិ។

៣២. បទដ្ឋានអន្តរជាតិចែងថា ដើម្បីកំណត់បទល្មើសនានាលើរូបគាត់ ជនជាប់ចោទត្រូវមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាពិសេសជានេះ ជនជាប់ចោទទទួលបានការជូនដំណឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់លើរូបគាត់ និងសិទ្ធិមានពេលវេលា និងមូលដ្ឋានសម្ភារៈ

---

[៧៥] លើសពីនេះទៀត យោងតាមវិធានផ្ទៃក្នុង ៥៧ ចែងថា នៅពេលជនត្រូវចោទចូលបង្ហាញខ្លួនជាលើកដំបូង ក.ស.ច.ស ក្នុងចំណោមប្រការផ្សេងទៀត ត្រូវប្រាប់ជនត្រូវចោទអំពីបទចោទប្រកាន់។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងនូវបទប្បញ្ញត្តិស្រដៀងគ្នានេះដែរក្នុងមាត្រា ១៤៣។

គ្រប់គ្រាប់ដើម្បីត្រៀមរៀបចំការពារខ្លួន[៧៦]។ សិទ្ធិនេះ "ត្រូវបានបកស្រាយជាកាតព្វកិច្ចចំពោះរដ្ឋអាជ្ញា ដោយត្រូវលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះអំពីអង្គហេតុនានា ដែលគាំទ្របទចោទ"[៧៧]។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវតែមានលក្ខណៈគ្រប់គ្រាន់ នៅពេលពួកគេថែងអំពីអង្គហេតុនានានៃបណ្តឹងអាជ្ញា ដោយត្រូវមានព័ត៌មានលម្អិតគ្រប់គ្រាន់ក្នុងការជូនដំណឹងដល់ចុងចោទឱ្យបានច្បាស់អំពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់លើបុគ្គលនោះ ដើម្បីឱ្យបុគ្គលនោះអាចរៀបចំការការពារខ្លួនឱ្យមានប្រសិទ្ធិភាព និងសក្តិសម[៧៨]។ ជាការពិត ព្រះរាជអាជ្ញា មិនតម្រូវឱ្យលើកអំណះអំណាងភស្តុតាង ដែលមានបំណងបង្ហាញនូវអង្គហេតុនានានោះទេ[៧៩] ហើយធាតុសម្ភារៈនៃអង្គហេតុជាក់លាក់មួយ អាស្រ័យលើប្រភេទនៃបណ្តឹងអាជ្ញា[៨០]។

៣៣. ក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាដីកាចោទប្រកាន់ដំបូង ខកខានលើកនូវភាពច្បាស់លាស់គ្រប់គ្រាន់ចំពោះចំណុចនានានៃបណ្តឹងអាជ្ញា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបែបនេះមានវិការៈផ្នែកសម្ភារៈ[៨១]។ ក្នុងការអនុវត្តគោលការណ៍ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលផ្អែកលើភាពមិនច្បាស់លាស់នៃពាក្យពេចន៍ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និង ICTR បានប្រើប្រាស់វិធីសាស្ត្រតឹងរ៉ឹងលើកម្រិតនៃភាពច្បាស់លាស់នៃអង្គហេតុនានា ដែលគួរតែត្រូវបានលើកអំណះអំណាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះទាំងនេះ បាន

---

76 សូមមើល ជាពិសេស មាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR"), ដែលមានចែងយ៉ាងច្បាស់ក្នុងមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។

៧៧ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kupreškić*. IT-95-16-A សាលដីកា របស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ ("សាលដីកាលើរឿងក្តី *Kupreškić*") កថាខណ្ឌ ៨៨។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Hadžihasanović, Alagić* និង *Kubura*, IT-01-47-PT សេចក្តីសម្រេចលើទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០១ ("សេចក្តីសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងរឿងក្តី *Hadžihasanović*") កថាខណ្ឌ ៨។

៧៨ សេចក្តីសម្រេចលើដីការបញ្ជូនរឿងទៅជំនុំជម្រះក្នុងរឿងក្តី *Hadžihasanović* កថាខណ្ឌ ៨។

៧៩ សាលដីកាលើរឿងក្តី *Kupreškić* កថាខណ្ឌ ៨៨។

៨០ សាលដីកាលើរឿងក្តី *Kupreškić* កថាខណ្ឌ ៨៩។

៨១ សាលដីកាលើរឿងក្តី *Kupreškić* កថាខណ្ឌ ១១៤។

00519420



អនុវត្តវិធីសាស្ត្រតឹងរ៉ឹងចំពោះការបង្ហាញអំពីអំពើនានា និងទង្វើរបស់ជនជាប់ចោទ ដែលព្រះរាជអាជ្ញាផ្អែកលើ ក្នុងការកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ[៨២]។ នៅក្នុង *រឿងក្តី* Kvočka et al. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ទោះបីអង្គហេតុជាធាតុផ្សំសម្ភារៈ ឬ មិនមែនក្តី វាអាស្រ័យលើភាពនៅកៀករបស់ជនជាប់ចោទទៅនឹងហេតុការណ៍ ដែលបុគ្គលនោះ ត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"[៨៣]។ លើសពីនេះទៀត៖

> "នៅពេលដែលភាពនៅកៀករបស់ជនជាប់ចោទទៅនឹងហេតុការណ៍ មានគម្លាតឃ្លាតឆ្ងាយពីគ្នា ការបញ្ជាក់នូវភាពច្បាស់លាស់ចំពោះព័ត៌មានលម្អិតជាក់លាក់ទាំងនោះ មិនសូវជាតម្រូវការខ្លាំងពេកនោះទេ ប៉ុន្តែទង្វើរបស់ជនជាប់ចោទត្រូវតែគួសបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត ចំពោះចំណុចដែលរដ្ឋអាជ្ញាផ្អែកលើ ដើម្បីកំណត់នូវការទទួលខុសត្រូវថាជាអ្នកសមគំនិត ឬជាថ្នាក់លើ របស់បុគ្គលដែលបានប្រព្រឹត្តិអំពើនោះដោយផ្ទាល់ ដែលនាំឱ្យមានការចោទប្រកាន់លើរូបគាត់"[៨៤]។

៣៤. ដោយពិចារណាថា ទាំងបទដ្ឋានអន្តរជាតិ និងមាត្រា៣៥ (ថ្មី) នៃច្បាប់ អ.វ.ត.ក តម្រូវឱ្យមានភាពច្បាស់លាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដូចនេះអង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីឱ្យមានភាពយុត្តិធម៌ អង្គបុរេជំនុំជម្រះប្រកាសទទួលយកមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងអំពីបញ្ហានៃការជូនដំណឹងអំពីបទចោទ ទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវ ដែលចោទប្រកាន់ចំពោះជនត្រូវចោទ។ ជាចុងក្រោយ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលការជំទាស់ទីប្រាំ

---

[៨២] សូមមើល រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង. Milan Milutinović, Nikola Sainović, Dragoljug Ojdanić, Nebojsa Pavković, Vladimir Lazarević, Vlastimir Djordjević and Sreten Lukić*, រឿងក្តីលេខ IT-05-87-PT.("រឿងក្តី *Milutinović, et al.*")។ សេចក្តីសម្រេចលើពាក្យសុំស្តីពីអញ្ញត្រកម្មលើទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងរឿងក្តី *Vladimir Lazarevic* ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៥ ( "សេចក្តីសម្រេចលើទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងរឿងក្តី *Vladimir Lazarevic* និងជនដទៃទៀត") សូមអានកថាខណ្ឌទី ៦។

[៨៣] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kvočka* និងអ្នកផ្សេងទៀត IT-98-30/1-A, សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ("សាលដីកាលើរឿងក្តី *Kvočka* ") កថាខណ្ឌ ៦៥។

[៨៤] សាលដីកាលើរឿងក្តី *Kvočka* កថាខណ្ឌ ៦៥ ដកស្រង់រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Galic*, IT-98-29-AR72 សេចក្តីសម្រេចលើពាក្យសុំអនុញ្ញាតដើម្បីប្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០១ ("សេចក្តីសម្រេចលើពាក្យសុំអនុញ្ញាតប្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Galic*") កថាខណ្ឌ ១៥។



ECCC * CETC PRE-TRIAL CHAMBER

របស់ ក.ស.ព ទៅនឹងបណ្តឹងឧទ្ធរណ៍ ដែលផ្អែកលើការសន្និដ្ឋានរបស់ខ្លួនថា ការបដិសេធបណ្តឹងឧទ្ធរណ៍នឹងជួយពន្លឿននីតិវិធី[៨៥]។

## ង. តើការបដិសេធបណ្តឹងឧទ្ធរណ៍នឹងជួយពន្លឿននីតិវិធីដែរឬទេ? ប្រសិនបើអាច តើការសន្និដ្ឋាននេះអាចជាមូលដ្ឋានមានសុពលភាព ដើម្បីសម្រេចអំពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍បច្ចុប្បន្នឬទេ?

៣៥. អង្គបុរេជំនុំជម្រះទទួលស្គាល់អង្គហេតុថា វិធាន៧៤(៣)(ក) និង វិធាន៨៩ (១) នៃវិធានផ្ទៃក្នុងបើកឱ្យមាននូវលទ្ធភាពលើកឡើងអំពីបញ្ហាយុត្តាធិការចំពោះមុខអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង។ អង្គបុរេជំនុំជម្រះក៏បានដឹងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេច នៅក្នុងសំណុំរឿង០០១ថា ខ្លួនមិនមានកាតព្វកិច្ចគោរពតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទេ[៨៦]។ ហេតុនេះ ការដោះស្រាយបញ្ហាយុត្តាធិការដែលលើកឡើងដោយបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននៅដំណាក់កាលនេះ នឹងមិននាំឱ្យមានការសន្សំពេលវេលា និងធនធានរបស់តុលាការឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ផលប្រយោជន៍នៅក្នុងការសន្សំនូវធនធានតុលាការ ហើយការបង្កើនល្បឿននៃដំណើរការនីតិវិធី និងច្បាប់ មិនមានសារៈសំខាន់ជាងមូលហេតុនានា ដែលបានលើកឡើងខាងលើ ក្នុងការបដិសេធចោលអញ្ញត្រកម្មទីពីរ និងទីបួន ដែលលើកឡើងដោយ ក.ស.ព ឡើយ[៨៧]។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C.

---

[៨៥] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៨-២២។

[៨៦] សំណុំរឿង កាំង ហ្គេកអ៊ាវ ០០១/១៨-០៧-២០០៧- អវតក/អជសដ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ដែលស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ E65/9 កថាខណ្ឌ ១២។

[៨៧] អង្គបុរេជំនុំជម្រះបដិសេធសំណើដែលធ្វើឡើងក្នុងនាម អៀង ធីរិទ្ធ ដែលស្នើសុំឱ្យហាមឃាត់ ក.ស.ព កុំឱ្យលើកឡើងនូវអំណះអំណាងអំពីសេដ្ឋកិច្ចតុលាការ។ សូមមើល ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៤។

## IV. **អង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍**

៣៦. ចំពោះបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលអនុវត្តចំពោះការភាន់ច្រឡំដូចដែលចោទប្រកាន់នៅក្នុងបណ្ដឹងឧទ្ធរណ៍វិញ បណ្ដឹងឧទ្ធរណ៍ អៀងធីរិទ្ធ យោងលើលក្ខណៈវិនិច្ឆ័យចំពោះការបដិសេធចោលសេចក្ដីសម្រេចដែលធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់ ក.ស.ច.ស ដូចដែលសម្រេចដោយអង្គបុរេជំនុំជម្រះនៅក្នុងសាលដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩[៨៨]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដរាបណាដីកាដែលត្រូវបានជំទាស់ ដោះស្រាយបញ្ហាយុត្តាធិការដីកានោះមិនពាក់ព័ន្ធនឹងឆន្ទានុសិទ្ធិរបស់ ក.ស.ច.ស ទេ។ ទោះបីជាយ៉ាងណាក៏ដោយ លក្ខណៈវិនិច្ឆ័យដែលអនុវត្តចំពោះការភាន់ច្រឡំផ្នែកច្បាប់ ដែលត្រូវបានចោទប្រកាន់ថា "ជាការបកស្រាយមិនត្រឹមត្រូវចំពោះច្បាប់ជាធរមាន" អនុវត្តផងដែរចំពោះការភាន់ច្រឡំផ្នែកច្បាប់ ដែលចោទប្រកាន់នៅក្នុងបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន[៨៩]។

៣៧. អង្គបុរេជំនុំជម្រះរំលឹកឡើងវិញថា សំអាងហេតុរបស់ខ្លួននៅក្នុងសំណុំរឿង០០១ ដែលថា JCE គឺជា "ទម្រង់មួយនៃការទទួលខុសត្រូវក្នុងការពិណ៌នាអំពីស្ថានភាពអង្គហេតុ ដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងរួមគ្នាដោយចារីពីរ ឬច្រើន [... គឺ] ពាក់ព័ន្ធនឹងការកំណត់ថាតើទម្រង់នៃការទទួលខុសត្រូវនេះអាចអនុវត្តបានចំពោះមុខ អ.វ.ត.ក ដែរឬយ៉ាងណា"[៩០]។ នៅក្នុងសេចក្ដីសម្រេចជាមួយគ្នានោះ អង្គបុរេជំនុំជម្រះលើកឡើងថា JCE[៩១] ត្រូវបានបែងចែកចេញជាបីប្រភេទ។

---

[៨៨] បណ្ដឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៦ ដកស្រង់សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ D164/4/13 ("សាលដីកាលើឃ្លាំងផ្ទុកឯកសាររួម") កថាខណ្ឌ ២៦។

[៨៩] សាលដីកាលើឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ២៦។

[៩០] សំណុំរឿង កាំង ហ្កេកអ៊ាវ ០០១/១៨-០៧-២០០៧-អវតក/អបជ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ D99/3/42 ("សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ") កថាខណ្ឌ ១១៤។

[៩១] អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្ដី *Tadić* បានប្រើប្រាស់ពាក្យដែលអាចជំនួសគ្នាបាន "សហឧក្រិដ្ឋកម្មរួម" "គោលបំណងរួម" និង "សហឧក្រិដ្ឋកម្ម" ទោះបីជាទស្សនទានជាទូទៅសំដៅទៅលើ "សហឧក្រិដ្ឋកម្មរួម" ដូចនៅក្នុងដីកាដែលត្រូវបាន

ប្រភេទទាំងនេះ ដកស្រង់ចេញពីការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY នៃយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ស្តីពីការទទួលខុសត្រូវលើ "ផែនការរួម"។ JCE ទម្រង់មូលដ្ឋាន (JCE I) កើតមាននៅពេលដែលអ្នកចូលរួមទាំងឡាយ បានប្រព្រឹត្តដោយផ្អែកលើមូលដ្ឋាននៃគ្រោងការណ៍រួម ឬសហគ្រាសរួមមួយ ហើយមានចេតនាដូចគ្នា ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម[៩២]។ JCE ទម្រង់ជាប្រព័ន្ធ (JCE II) កើតមាននៅពេលអ្នកចូលរួមពាក់ព័ន្ធនៅក្នុងផែនការឧក្រិដ្ឋមួយ ដែលបានអនុវត្តនៅក្នុងក្របខណ្ឌនៃស្ថាប័ន ដូចជាជំរំប្រមូលផ្តុំ[៩៣] ដែលពាក់ព័ន្ធនឹងប្រព័ន្ធធ្វើបាបដែលមានការចាត់តាំង[៩៤]។ អង្គបុរេជំនុំជម្រះយល់ឃើញថា JCE II មានលក្ខណៈខុសគ្នាបន្តិចពី JCE I[៩៥]។ ទម្រង់ទូលាយ (JCE III) កើតមាននៅពេលអ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមទាំងឡាយ ពាក់ព័ន្ធនឹងអំពើដែលកើតឡើងហួសពីផែនការឧក្រិដ្ឋ។ ប៉ុន្តែ

---

ជំទាស់ក៏ដោយ។ ផងដែរសូមមើល សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Ojdanić* កថាខណ្ឌ ២0 ស្តីអំពីសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការប្រព្រឹត្ត។

[៩២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៣២ និងជើងទំព័រ ៨២ យោងទៅលើរឿងក្តី *Almelo* ដែលជារឿងក្តីមួយក្នុងចំណោមរឿងក្តីជាច្រើនទៀត របស់តុលាការយោធា ដែលត្រូវបានពិនិត្យ និងដកស្រង់ដោយសាលដីកាលើរឿងក្តី *Tadić* ។

[៩៣] ដូចសេចក្តីយោងខាងលើ កថាខណ្ឌ ២0២ យោងទៅលើសាលដីកាលើរឿងក្តី *Tadić* ។

[៩៤] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Vasiljević*, IT-98-32-A សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២00៤ ("សាលដីកាលើរឿងក្តី *Vasiljević* ") កថាខណ្ឌ ៩៨។

[៩៥] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២0២-២0៣។ ទោះបីជាអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនៃប្រភេទនេះ ភាគច្រើនជាសមាជិកនៃអង្គការឧក្រិដ្ឋកម្មក៏ដោយ រឿងក្តី *Tadić* មិនតម្រូវឱ្យបុគ្គលម្នាក់ជាសមាជិករបស់អង្គការនោះ ដើម្បីចាត់ទុកថាជាអ្នកចូលរួមម្នាក់ក្នុងសហឧក្រិដ្ឋកម្មរួមឡើយ។ សាលដីកាលើរឿងក្តី *Krnojelac* រកឃើញថា ប្រភេទ "ជាប្រព័ន្ធ" នៃសហឧក្រិដ្ឋកម្មរួមនេះ អាចត្រូវបានយកមកអនុវត្តចំពោះរឿងក្តីដទៃទៀត និងជាពិសេសចំពោះការរំលោភ ដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវបានប្រព្រឹត្តឡើងក្នុងទឹកដីអតីតយូហ្គោស្លាវី ចាប់តាំងពីឆ្នាំ១៩៩១។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Krnojelac*, IT-97-25-A សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២00៣ ("សាលដីកាលើរឿងក្តី *Krnojelac*") កថាខណ្ឌ ៨៩។

អំពើទាំងនោះជាផលវិបាកដែលអាចមើលឃើញនិងកើតឡើងដោយឯកឯង នៃការសម្រេចផែនការណ៍រួម[៩៦]។

៣៨. ធាតុផ្សំសត្យានុម័ត (*actus reus*) មានលក្ខណៈដូចគ្នាចំពោះទម្រង់ទាំងបីរបស់JCE ពោលគឺ (i) ផែនការរួម (អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ផែនការរួមនេះ ត្រូវតែមានន័យស្មើ ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិបទល្មើសនៅក្នុងយុត្តាធិការរបស់តុលាការ) (ii) ពាក់ព័ន្ធនឹងមនុស្សច្រើននាក់ និង (iii) ការរួមចំណែកដោយឡែកៗពីគ្នារបស់ជនត្រូវចោទ ឬជនជាប់ចោទចំពោះការប្រព្រឹត្តិផែន ការណ៍រួម[៩៧]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាជនជាប់ចោទមិនចាំបាច់អនុវត្តផ្នែកណាមួយនៃ*ធាតុផ្សំសត្យានុម័ត* នៃបទល្មើសដែលបានប្រព្រឹត្តក៏ដោយ[៩៨] ក៏វាទាមទារឱ្យជនជាប់ចោទ "បានចូលរួមនៅក្នុងការបន្តគោលបំណងរួមនៅក្នុងចំណុចសំខាន់នៃ JCE"[៩៩]។ មិនមែនរាល់ប្រភេទនៃទង្វើទាំងអស់ មានតម្លៃស្មើនឹងការចូលរួមសំខាន់គ្រប់គ្រាន់ ក្នុងការនាំឱ្យមាននូវការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទ ដោយផ្អែកលើការចូលរួមរបស់ពួកគេនៅក្នុង JCE[១០០]។

៣៩. ធាតុផ្សំអត្តនោម័ត (*mens rea*) មានលក្ខណៈខុសគ្នា អាស្រ័យលើទម្រង់នៃ JCE។ JCE I ទាមទារឱ្យមានចេតនារួម ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[១០១]។ JCE II ទាមទារឱ្យបុគ្គលដឹងឮដោយខ្លួនឯងចំពោះ

---

[៩៦] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣២ យោងទៅលើសាលដីកាលើរឿងក្តី *Kvočka* កថាខណ្ឌ ២៦៧។

[៩៧] ដូចសេចក្តីយោងខាងលើ យោងទៅលើ សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២២៧។

[៩៨] សាលដីកាលើរឿងក្តី *Kvočka* កថាខណ្ឌ ៩៩ ("អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ចូលរួមដោយផ្ទាល់ក្នុងធាតុផ្សំណាមួយនៃបទឧក្រិដ្ឋណាមួយឡើយ ប្រសិនបើលក្ខខណ្ឌតម្រូវនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមត្រូវបានបំពេញ")។ សាលដីកាលើរឿងក្តី *Vasiljević* កថាខណ្ឌ ១០០, ១១៩។ សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ១៩៦,២២៧។

[៩៩] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Brđanin*, IT-99-36-A សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ ("សាលដីកាលើរឿងក្តី *Brđanin*") កថាខណ្ឌ ៤២៧។

[១០០] ដូចសេចក្តីយោងខាងលើ។

[១០១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៣២។

ប្រព័ន្ធនៃការធ្វើបាប[១០២] *និងចេតនាចង់សម្រេចលើប្រព័ន្ធថែមទៀត*[១០៣]។ JCE III ទាមទារឲ្យមានចេតនាក្នុងការចូលរួមនៅក្នុងផែនការឧក្រិដ្ឋ ឬគោលបំណង JCE និងចេតនាក្នុងការចូលរួមចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម "ដោយមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រៅផែនការ ដែលជនជាប់ចោទអាចប្រមើលមើលឃើញនូវការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួន ហើយស្ម័គ្រចិត្តប្រថុយប្រថាន"[១០៤] --ឬនិយាយម្យ៉ាងទៀត "ទោះបីជាដឹងថាបទល្មើសបែបនេះ អាចជាផលវិបាកនៃប្រព្រឹត្តរបស់សហគ្រាសហើយនោះ ហើយទោះជាមានការដឹងបែបនេះក្តី [ក៏បានសម្រេចចិត្ត] ចូលរួមនៅក្នុងសហគ្រាសនោះ"[១០៥]។

៤០. ការពិនិត្យមើលឡើងវិញ នូវសេចក្តីសម្រេចជាច្រើនរបស់តុលាការយោធាក្រោយសង្គ្រាមលោកលើកទីពីរ តុលាការ ICTY តុលាការ ICTR តុលាការ ICC និងការបោះពុម្ពផ្សាយពាក់ព័ន្ធផ្សេងៗ ដែលបានដាក់ ឬ យោងជាឯកសារសំអាងផ្លូវច្បាប់ ដោយភាគីទាំងឡាយនៅក្នុងរឿងក្តីនេះ[១០៦] បានបង្ហាញថា ទស្សនទាននៃ JCE ជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងច្បាប់អន្តរជាតិ គឺជាទស្សនទានពិសេសមួយ។ JCE រួមផ្សំលក្ខណៈនានាពីច្បាប់ទំនៀមទម្លាប់ផ្សេងៗគ្នា និងត្រូវបានអនុវត្តនិងរៀបចំដោយតួអង្គផ្សេងៗដែលមានសាវតាច្បាប់ខុសៗគ្នា។ ព្រះរាជអាជ្ញា និងចៅក្រមនៅគណៈកម្មការយោធា និងតុលាការយោធា ដែលបង្កើតឡើងក្រោយសង្គ្រាមលោកលើកទីពីរ បានអនុវត្តនូវទស្សនទានទាក់ទងនឹងការទទួលខុសត្រូវដែលមានចែងនៅក្នុងធម្មនុញ្ញ Nuremberg និងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ ទស្សនទាននេះមិនត្រឹមតែដាក់ការទទួលខុសត្រូវលើចារីទាំងនោះដែលបានប្រព្រឹត្តអំពើផ្ទាល់ចំពោះការរំលោភលើច្បាប់មនុស្សធម៌ ប៉ុន្តែក៏ដាក់ការទទួលខុសត្រូវ

---

[១០២] ដូចសេចក្តីយោងខាងលើ។

[១០៣] សាលដីកាលើរឿងក្តី *Vasiljević* កថាខណ្ឌ ១០១។

[១០៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៣២ យោងទៅលើសាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២២៨។

[១០៥] សាលដីកាលើរឿងក្តី *Vasiljević* កថាខណ្ឌ ១០១។ ផងដែរ សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Karadzic,* IT-95-5/18-AR72.4 សេចក្តីសម្រេចលើញត្តិរបស់អយ្យការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភាពអាចប្រមើលមើលដឹងជាមុននៃ JCE III ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ១៥-១៨។

[១០៦] សេចក្តីសម្រេចទាំងនេះមួយចំនួន នឹងត្រូវបានពិភាក្សាលម្អិតនៅខាងក្រោម។

លើបុគ្គលទាំងឡាយដែលបានចូលរួមនៅក្នុងការប្រព្រឹត្តិបទល្មើសបែបនោះ ដើម្បីសម្រេចគម្រោងរួមជាមួយអ្នកផ្សេងទៀត។ នៅក្នុងរឿងក្ដីមួយចំនួន ហើយជាពិសេសជនទាំងឡាយដែលគាំទ្ររបបណាហ្ស៊ី (Nazi) ដែលបានពាក់ព័ន្ធនៅក្នុងហិង្សាជាក្រុមប្រឆាំងនឹងយោធាសម្ព័ន្ធមិត្ត និងកងកម្លាំងតស៊ូ ក៏បទល្មើសទាំងអស់ត្រូវបានប្រព្រឹត្តផ្ទាល់ដោយបុគ្គលនានា ដែលមានចេតនារួមដូចគ្នានឹងពិរុទ្ធជន ហើយបុគ្គលទាំងនេះមិនស្ថិតនៅឆ្ងាយពីការប្រព្រឹត្តិបទល្មើស[១០៧]។ នៅក្នុងករណីមួយចំនួនផ្សេងទៀត ដែលពាក់ព័ន្ធបទល្មើសដែលប្រព្រឹត្តនៅក្នុងទំហំធំ និងពាក់ព័ន្ធជាមួយភ្នាក់ងាររដ្ឋ ជាធម្មតា ពិរុទ្ធជននៅឆ្ងាយពីការប្រព្រឹត្តិបទល្មើសផ្ទាល់ ហើយគេមិនចាំបាច់ពិចារណាអំពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬសូម្បីតែស្ថានស្មារតីរបស់ចារីដែលបានប្រព្រឹត្តផ្ទាល់[១០៨]។

---

[១០៧] សូមមើល ជាពិសេស រឿងក្ដីចំនួន ៦ ដែលសាលដីកាលើរឿងក្ដី *Tadić* យកមកធ្វើជាសំអាង កថាខណ្ឌ ១៩៧-២០០ ក្នុងការគាំទ្រទម្រង់មូលដ្ឋាននៃJCE។

[១០៨] សូមមើល ឧទាហរណ៍ រឿងក្ដីពីររបស់ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង សហរដ្ឋអាមេរិក ទល់នឹង *Altstoetter* និងអ្នកផ្សេងទៀត (ឆ្នាំ១៩៤៧) តុលាការយោធាសហរដ្ឋអាមេរិក III យោបល់ និងសាលក្រម នៅក្នុងការជំនុំជម្រះទោសឧក្រិដ្ឋជន សង្គ្រាមនៅចំពោះមុខតុលាការយោធា *Nuernberg* ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង វ៉ុល III ។ (ការិយាល័យបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឆ្នាំ១៩៥១) ("រឿងក្ដី *Justice*") និងសហរដ្ឋអាមេរិក ទល់នឹង *Greifelt* និងអ្នក ផ្សេងទៀត (ឆ្នាំ១៩៤៨) តុលាការយោធាសហរដ្ឋអាមេរិក I យោបល់ និងសាលក្រម នៅក្នុងការជំនុំជម្រះទោសក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង វ៉ុល V (ការិយាល័យបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឆ្នាំ១៩៤៩) ("រឿងក្ដី *RuSHA*") ។ រឿងក្ដីទាំងនេះ ដែលក្នុងចំណោមប្រការផ្សេងទៀត ត្រូវបានអង្គជំនុំជម្រះតុលាការកំពូល ICTR យកមកធ្វើជាសំអាងក្នុងការធ្វើសេចក្ដីសន្និដ្ឋានថា ត្រឹមឆ្នាំ១៩៩២ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានអនុញ្ញាតឱ្យមានការដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌលើអ្នកចូលរួមក្នុងផែនការរួមក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។ សូមមើលសេចក្ដីសម្រេចលើ JCE ក្នុងរឿងក្ដី *Rwamakuba* កថាខណ្ឌ ១៤-២៣។ កថាខណ្ឌទាំងនេះពាក់ព័ន្ធជាមួយនឹង ១) លំនាំ និងផែនការធ្វើទុក្ខបុកម្នេញផ្នែកជាតិសាសន៍ ដើម្បីដាក់ឱ្យអនុវត្តនូវច្បាប់ព្រហ្មទណ្ឌប្រឆាំងនឹងជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វដែលពាក់ព័ន្ធនឹងរដ្ឋអាជ្ញាដែលបានផ្ដន្ទាទោស និងចៅក្រមដែលបានកាត់ទោស និងថែមទាំងបានកាត់ទោសប្រហារជីវិតជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វ ស្របតាមគោលនយោបាយរបស់រដ្ឋ Nazi ក្នុងការធ្វើទុក្ខបុកម្នេញ ធ្វើទារុណកម្ម និងសម្លាប់បំផុតពូជជាតិសាសន៍ជ្វីហ្វ និងប៉ូឡូញ និង ២) បុគ្គលដែលបានចូលរួមក្នុងគោលបំណងពីរយ៉ាងក្នុងការធ្វើឱ្យចុះខ្សោយ និងចុងក្រោយកម្ទេចបណ្ដាប្រទេសដទៃទៀត ដោយទន្ទឹមពេលគ្នានោះដែរ ពង្រឹងប្រទេសអាល្លឺម៉ង់ផងដែរ ផ្នែកទឹកដី និងជីវសាស្ត្រ ដែលធ្វើឱ្យខូចខាតដល់បណ្ដាប្រទេស ដែលត្រូវស្ថិតនៅក្រោមការត្រួតត្រានោះ។ ផែនការនៃ "ការធ្វើអាល្លឺម៉ង់តូបនីយកម្ម" នេះទាក់ទិននឹងការប្រព្រឹត្តនូវអំពើរំលូតកូនទៅលើជនបរទេស ដែលមានផ្ទៃពោះដោយសារពូជជនជាតិអាល្លឺម៉ង់ ការដាក់ទណ្ឌកម្ម

៤១. ទោះបីជាវាមានលក្ខណៈពិសេសក៏ដោយ ទស្សនទាន JCE យ៉ាងហោចណាស់ទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធ (JCE I & II) ស្រដៀងគ្នានឹងការទទួលខុសត្រូវនៅក្នុងច្បាប់ស៊ីវិលចាស់។ ច្បាប់ស៊ីវិលចាស់ ចាត់ទុកសហចារី មិនមែនត្រឹមតែបុគ្គលទាំងឡាយណាដែលប្រព្រឹត្តដោយផ្ទាល់នូវ *អំពើពិរុទ្ធ*នៃបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែជនទាំងឡាយដែលមាន*ចេតនាប្រព្រឹត្ត*បទល្មើស ហើយចូលរួម ឬ ជួយក្នុងការប្រព្រឹត្តិ។ នៅក្នុងគំនិតនេះ JCE មានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជា។ ច្បាប់ព្រហ្មទណ្ឌមាននាពេលពាក់ព័ន្ធ គឺជាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ ដូចដែលបានកត់សម្គាល់ដោយសារណាមួយក្នុងចំណោម*សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ថា៖

> ដោយយោងលើ*សេចក្តីអត្ថាធិប្បាយលើ "គម្រោងក្រមព្រហ្មទណ្ឌថ្មី"* ដែលសម្របសម្រួលដោយ Michel Bonnieu ច្បាប់កម្ពុជាចាស់ បែងចែករវាងចារីគ្រោះថ្នាក់ និងចារីមិនគ្រោះថ្នាក់ ("malfaiteur dangereux" និង "non dangereux") និងមាត្រា៧៦ នៃក្រមឆ្នាំ១៩២៩ និង១៩៥៥(១៩៥៦) ផ្តល់និយមន័យ "auteur" (ចារី) ថាជាបុគ្គលដែលប្រព្រឹត្តបទល្មើស ("infractions qu'elle comment ...")។ ការរួមប្រព្រឹត្ត ត្រូវបានកំណត់និយមន័យថាជា "co-action" (coaction) នៅក្នុងក្រមឆ្នាំ១៩២៩ និង១៩៥៦ និងលក្ខខណ្ឌសំខាន់ចាំបាច់បំផុតរបស់វា គឺការព្រមព្រៀងរួមគ្នារវាងសហចារី។ អាស្រ័យហេតុនេះ តាមការបកស្រាយរបស់វា បទប្បញ្ញត្តិមិនបានបញ្ចូលអំពើនានាដែលស្ថិតនៅក្រៅកិច្ចព្រមព្រៀងទេ។ ករណីនេះអាចត្រូវបានផ្តន្ទាទោសជាបទសមគំនិត។ ជាការពិត មាត្រា៨២ បែងចែករវាងការចូលរួមផ្ទាល់ និងការចូលរួមមិនផ្ទាល់ និងចាត់ទុកការចូលរួមផ្ទាល់ជាការរួមប្រព្រឹត្ត និងការចូលរួមមិនផ្ទាល់ជាការសមគំនិត។ យោងតាមមាត្រា៨៧ ជំនួយ ឬការទំនុកបំរុង តម្រូវឱ្យមាន "ការជួយដោយដឹងច្បាស់"។ អ្នកជួយនិងទំនុកបម្រុងអាចចាត់ទុកថាជាសហចារី "លុះត្រាតែអ្នកជួយនិងទំនុកបម្រុងនោះ បានជួយឱ្យសម្រេចបទល្មើសនោះ" ពោលគឺ នៅពេលអ្នកជួយនិងទំនុកបម្រុងខ្លួនឯង ដែលជាអ្នកធ្វើឱ្យសម្រេចបទល្មើស[១០៩]។

---

ចំពោះការរួមភេទរវាងជនជាតិអាល្លឺម៉ង់ និងអ្នកដែលមិនមែនជនជាតិអាល្លឺម៉ង់ ការធ្វើការធូនដូចទាសកររបស់ជនប៉ូឡូញ និងជនជាតិប៉ែកខាងកើតដទៃទៀត ការធ្វើទុក្ខបុកម្នេញជនជាតិជ្វីហ្វ និងជនជាតិប៉ូឡូញ និងការចាប់ពង្រត់កុមារបរទេស។

[១០៩] សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី Kai Ambos ទំព័រ ២៩ ដោយយោងទៅលើ M. Bonnieu និងអ្នកផ្សេងទៀត, *Projet de Nouveau Code Penal. Commenté et comparé* (2008) នៅចំណុច ១៣, ១៤ (ដោយយោងទៅលើចំណុចនេះ មាត្រាថ្មី L. 1121-2 តម្រូវឱ្យមាន ['ការយល់ព្រមរួម]'") ១៥ (ការធ្វើអត្ថាធិប្បាយលើមាត្រា L. 1121-5។

សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដដែល បានកត់សម្គាល់ថា នៅក្នុងរឿងក្តី ០០១ សារណាឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានយោងលើ មាត្រា១៤៥ នៃក្រមដដែលនេះ ថាបានផ្តល់នូវនិយមន័យនៃពាក្យ "ការរួមប្រព្រឹត្ត" រវាង៖

> គូកនច្រើននាក់ ដែល "បានមូលមាត់គ្នា" ដើម្បីប្រព្រឹត្តបទល្មើស។ "ក្រៅពីសំអាងលើមាត្រា ១៤៥ ដែលមិនបានលើកឡើងអំពីប្រភពដែលមានផ្សេងទៀត សារណាឧទ្ធរណ៍បង្កើតយ៉ាង ត្រឹមត្រូវជាថ្មីនូវច្បាប់ធរមាននាពេលប្រព្រឹត្ត"។ ដោយពិចារណាឥទ្ធិពលរបស់ច្បាប់ព្រហ្ម ទណ្ឌបារាំងនៅក្នុងប្រទេសកម្ពុជា វាមានតម្លៃក្នុងការកត់សម្គាល់ថា ក្រមព្រហ្មទណ្ឌបារាំងជា ធរមាននាពេលនោះ (ក្រមព្រហ្មទណ្ឌឆ្នាំ១៨១០[១១០] មាត្រា៥៩ មាត្រា៦០) ដែលមិនបានផ្តល់ និយមន័យអំពីទម្រង់ខុសគ្នានៃការប្រព្រឹត្តិ ក្រមនេះបានបែងចែករវាង "acteur" (តារា) និង "complice" (អ្នកជួយនិងជំរុញ អ្នកសមគំនិត) ហេតុដូចនេះយ៉ាងហោចណាស់បានបញ្ជាក់ អំពីទម្រង់នៃការចូលរួម ដែលក្រមកម្ពុជាយកគ្រាប់តាម[១១១]។

នេះមិនមែនមានន័យថា "ការចូលរួមនៅក្នុង JCE" ដូចគ្នាបេះបិតនឹង "ការរួមប្រព្រឹត្ត" នៅក្នុងក្រម ព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នោះទេ។ ទោះបីជាទាំងការចូលរួមនៅក្នុង JCE និង ការរួមប្រព្រឹត្ត តម្រូវឱ្យអ្នកចូលរួមមានចេតនារួមក្នុងការប្រព្រឹត្តិបទល្មើស ក៏ការចូលរួមនៅក្នុង JCE បើទោះ ជាការចូលរួមនៅក្នុង JCE ត្រូវតែជាជាការចូលរួមជាក់ស្តែងក៏ដោយ វាហាក់ដូចជាបញ្ចូលស្ថាន ភាព ដែលជនជាប់ចោទអាចស្ថិតនៅកាន់តែឆ្ងាយពីការប្រព្រឹត្តិជាក់ស្តែងនៃ*អំពើពិរុទ្ធ*នៃបទល្មើស ជាងការចូលរួមផ្ទាល់ដែលតម្រូវតាមច្បាប់ជាតិ។ នេះក៏មិនមានន័យផ្ទុយទៅនឹងអ្វីដែលដើមបណ្តឹង ឧទ្ធរណ៍ម្នាក់ ក្នុងចំណោមដើមបណ្តឹងឧទ្ធរណ៍ទាំងនោះចោទប្រកាន់ថា ការចូលរួមក្នុង JCE គឺជា ទម្រង់នៃការទទួលខុសត្រូវមួយ "ធ្ងន់ធ្ងរជាង" ទម្រង់នៃ "ការរួមប្រព្រឹត្តិ" ក្នុងច្បាប់ជាតិ[១១២]។

---

[១១០] អាចរកមើលបាននៅគេហទំព័រ http://ledroitcriminel.free.fr/la_legislation_criminelle/anciens_textes/code_penal _de _1810.htm (បានពិនិត្យមើលនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨)។

[១១១] សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី Kai Ambos ទំព័រ ៣០។

[១១២] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២៦។

00519429



៤២. អង្គបុរេជំនុំជម្រះក៏កត់សម្គាល់ផងដែរថា បញ្ហាចោទអំពីឋានៈរបស់ JCE នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលបទល្មើសកើតឡើង ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន ក៏ត្រូវបានលើកឡើងនៅក្នុងសំណុំរឿង០០១។ ទោះបីជាមានករណីបែបនេះក្តី ជនត្រូវចោទមិនត្រូវបានគេជូនដំណឹងអំពីការចោទប្រកាន់ ចំពោះការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ ហើយវាមិនបានបង្កើតជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុសម្រាប់ការស៊ើបសួរ។ ដោយសារមូលហេតុនេះ អង្គបុរេជំនុំជម្រះមិនសម្រេចលើបញ្ហានេះទេ[១១៣]។

៤៣. មាត្រា៣៣(២) ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា អ.វ.ត.ក ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR)។ មាត្រា១៥(១) នៃICCPR ចែងថាអំពីគោលការណ៍ *គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ដូចតទៅ៖ "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើសកម្ម ឬអកម្មណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅខណៈពេលដែលបទល្មើសបានប្រព្រឹត្តនោះឡើយ"។ អង្គបុរេជំនុំជម្រះតក់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY បានកំណត់បុរេលក្ខខណ្ឌចំនួនបួន ដែលទម្រង់ណាមួយនៃការទទួលខុសត្រូវ ត្រូវតែបំពេញដើម្បីឲ្យស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការអន្តរជាតិ ដែលអាចសង្ខេបបានដូចខាងក្រោមនេះ ដើម្បីគោលបំណងរបស់ដំណើរការនីតិវិធី អ.វ.ត.ក៖

(i) បុរេលក្ខខណ្ឌត្រូវតែមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ឱ្យបានច្បាស់លាស់ ឬដោយលក្ខណៈប្រយោល។

(ii) បុរេលក្ខខណ្ឌត្រូវតែមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលពាក់ព័ន្ធ។

(iii) ច្បាប់ដែលមានចែងចំពោះទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអាចដឹងឱ្យបានគ្រប់គ្រាន់នៅពេលពាក់ព័ន្ធចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើនោះ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C.

[១១៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤១-១៤២។

(iv) ជននោះ ត្រូវតែអាចប្រមើលដឹងថា គាត់អាចត្រូវសម្រេចឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើរបស់គាត់ ប្រសិនបើរកឃើញ[១១៤]។

៤៤. អង្គបុរេជំនុំជម្រះ មិនជឿចំពោះទឡ្ហីករណ៍របស់លោក អៀង សារី ដែលលើកឡើងថា ក.ស.ច.ស គួរតែអនុវត្តលក្ខខណ្ឌតឹងរ៉ឹងមួយ ជាងលក្ខខណ្ឌតឹងរ៉ឹងដែលប្រើប្រាស់នៅកម្រិតអន្តរជាតិ ហើយតម្រូវថា ការទទួលខុសត្រូវ JCE គួរមានចែងនៅក្នុងច្បាប់កម្ពុជា ពីព្រោះ អ.វ.ត.ក "គឺជាតុលាការថ្នាក់ជាតិ"[១១៥]។ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌខាងលើ ដែលលើកសំអាងដោយ ក.ស.ច.ស[១១៦] គឺជាលក្ខខណ្ឌត្រឹមត្រូវមួយ។

៤៥. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីជាសេចក្តីសម្រេច ICTY មួយចំនួន បង្កប់ន័យថា ប្រសិនបើទម្រង់នៃការទទួលខុសត្រូវមួយ មានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលពាក់ព័ន្ធលក្ខខណ្ឌនៃភាពអាចប្រមើលដឹងថាជាបទល្មើសព្រហ្មទណ្ឌ និងលក្ខខណ្ឌដឹងថាមានច្បាប់ចែងអាចនឹងត្រូវបានសន្មតផងដែរ[១១៧]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញថា

---

[១១៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពី JCE ក្នុងរឿងក្តី *jdanić* កថាខណ្ឌ ២១។ Appeal Decision, para. 21. *Accord* រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blagojević* និង *Jokić*, IT-02-60-T, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង I ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ("សាលក្រមលើរឿងក្តី *Blagojević* និង *Jokić* ") កថាខណ្ឌ ៦៩៥ ជើងទំព័រ ២១៤៥។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Stakić*, IT-97-24-T សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង II ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ ("សាលក្រមលើរឿងក្តី *Stakić* ") កថាខណ្ឌ ៤៣១។

[១១៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២ក)។

[១១៦] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៩។

[១១៧] សូមមើលសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី កថាខណ្ឌ ១៣ និងជើងទំព័រ ៦ ដោយយោងទៅលើរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Martić*, IT-95-11-Aសាលក្រម-- យោបល់ដាច់ដោយឡែករបស់ចៅក្រម Schomburg ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ Milan Martić ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨។ ផងដែរសូមមើល សេចក្តីសម្រេចលើការរួមប្រព្រឹត្តក្នុងរឿងក្តី *Ojdanić* កថាខណ្ឌ ១៥ ដោយយោងទៅលើសេចក្តីសម្រេចនេះ "ដរាបណាវាច្បាស់លាស់ដែលថា ទម្រង់នៃការទទួលខុសត្រូវដែលចោទឡើងនេះ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលមានការប្រព្រឹត្តបទឧក្រិដ្ឋជាសារធាតុ ការផ្តន្ទាទោស ដែលអនុលោមតាមទម្រង់នៃការទទួលខុសត្រូវនោះ ចាំបាច់ស្របតាមគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង។ ជាលទ្ធផល បុរេលក្ខខណ្ឌ (iii) និង (iv) ត្រូវបានដាក់បញ្ចូលទៅក្នុងការវិភាគថាតើ បុរេលក្ខខណ្ឌ (ii) មានអត្ថិភាព ឬយ៉ាងណា ដោយយោងទៅលើ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Hadžihasanović* និងអ្នកផ្សេងទៀត IT-01-47-AR72,

វាកាន់តែច្បាស់លាស់ប្រសិនបើយើងមិនត្រឹមតែរកឃើញថាតើ JCE មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធ ដូច្នេះអាចផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ប៉ុន្តែយើងក៏ត្រូវរកឱ្យឃើញថាតើជនត្រូវចោទដឹងថាមានច្បាប់ចែង និងអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋដែរឬទេ។ ចំពោះលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ ជនត្រូវចោទត្រូវតែអាចបង្ហាញថា អំពើនោះគឺជាអំពើព្រហ្មទណ្ឌ នៅក្នុងអារម្មណ៍ដែលអាចដឹងជាទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយទេ។ ចំពោះលក្ខខណ្ឌតម្រូវនៃការដឹងថាមានច្បាប់ចែង វាក៏រួមបញ្ចូលសំអាងច្បាប់ទាំងឡាយណាដែលផ្អែកលើទំនៀមទម្លាប់ផងដែរ[១១៨]។ ផ្ទុយទៅនឹងអ្វីដែលអះអាងដោយដើមបណ្តឹងឧទ្ធរណ៍ បញ្ហាចោទថាតើ JCE គឺជាទម្រង់នៃការទទួលខុសត្រូវដែលបានទទួលស្គាល់នៅក្នុងច្បាប់ជាតិដែរឬយ៉ាងណា បញ្ហាចោទនេះអាចមានលក្ខណៈពាក់ព័ន្ធ នៅពេលកំណត់ថាតើជនត្រូវចោទអាចប្រមើលដឹងថាតើទង្វើដែលចោទប្រកាន់លើខ្លួនខ្លួនអាចនាំឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែរឬទេ។ ប៉ុន្តែ វាមិនមានលក្ខខណ្ឌតម្រូវថា ក្រៅពីជាទម្រង់នៃទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដើម្បីអាចយកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក JCE ក៏អាចផ្តន្ទាទោសបានតាមច្បាប់ជាតិដែរ[១១៩]។

៤៦. អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលលើចំណុចកាន់ច្រឡំមួយចំនួន ដែលចោទប្រកាន់ដោយបណ្តឹងឧទ្ធរណ៍ អៀង សារី និងបណ្តឹងឧទ្ធរណ៍ ខៀវ សំផន ដែលនៅក្នុងទស្សនៈរបស់ដើមបណ្តឹងឧទ្ធរណ៍យល់ឃើញថា ការអនុវត្ត JCE នៅក្នុង អ.វ.ត.ក ត្រូវតែរារាំង ដោយមិនគិតថាតើ JCE គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានទទួលស្គាល់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឬក្នុងអំឡុងពេលចន្លោះឆ្នាំ១៩៧៥-៧៩ នោះទេ។

---

សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំជំទាស់យុត្តាធិការ ទាក់ទិនទៅនឹងការទទួលខុសត្រូវក្នុងការបញ្ជា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៥៤។

[១១៨] សូមមើល សាលដីកាស្តីពី JCE ក្នុងរឿងក្តី *Ojdanić* កថាខណ្ឌ ៣៧-៣៩។

[១១៩] ផងដែរ សូមមើល កថាខណ្ឌ ៤៤, ៤៥ ខាងក្រោម។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

៤៧. ចំពោះការចោទប្រកាន់ថា ក.ស.ច.ស ភាន់ច្រឡំនៅពេល[១២០] ដែលខ្លួនបានលើកឡើងដកស្រង់ពីអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង០០១ថា "ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយ អ.វ.ត.ក គឺជាការសន្និដ្ឋានដែលទាញចេញអំពីហេតុដែលថា អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការអន្តរជាតិដែលអនុវត្តច្បាប់អន្តរជាតិ"[១២១] អង្គបុរេជំនុំជម្រះយល់ឃើញថា សំអាងហេតុរបស់ ក.ស.ច.ស វាមិនពាក់ព័ន្ធនឹងបញ្ហាថាតើ អ.វ.ត.ក អាចអនុវត្ត JCE បានដែរឬអត់នោះទេ។ ក.ស.ច.ស ពិតជាបានយោងទៅលើ "ចរិតលក្ខណៈអន្តរជាតិរបស់ អ.វ.ត.ក នេះ និងករណីដែលថាថា យុត្តិសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃអំពី JCE ត្រូវបានតាក់តែងឡើងមុនពេលនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរនៅមុខ អ.វ.ត.ក កើតមានឡើង ដើម្បីយកមកធ្វើជាការសន្និដ្ឋានថា អនុលោមតាមច្បាប់អន្តរជាតិ វាមានមូលដ្ឋានសម្រាប់អនុវត្ត JCE នៅចំពោះមុខ អ.វ.ត.ក"[១២២]។ យ៉ាងណាក៏ដោយ ទោះជា អ.វ.ត.ក "មានចរិតលក្ខណៈជាតុលាការអន្តរជាតិដែលអនុវត្តច្បាប់អន្តរជាតិ" "ក្នុងការអនុវត្តជាក់ស្តែងនិងតាមផ្លូវច្បាប់ [...] និងដំណើរប្រតិបត្តិការរបស់ខ្លួនដោយឯករាជ្យទាំងស្រុង នៅក្នុងរចនាសម្ព័ន្ធតុលាការជាតិកម្ពុជា [...]" ដែលត្រូវបានរកឃើញដោយអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង០០១[១២៣] ជា "តុលាការអន្តរូបនីយកម្ម តុលាការឯករាជ្យ និងតុលាការដែលបានបង្កើតឡើងដាច់ដោយឡែក" ដូចដែលបានយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីដូចគ្នា[១២៤] ឬ អ.វ.ត.ក ជាតុលាការថ្នាក់ជាតិក៏ដោយ ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខណៈទាំងនេះមិនមានផលប៉ះពាល់លើការសម្រេចរបស់ដីកាដែលត្រូវបានជំទាស់ ដែលសម្រេចថា JCE អាចអនុវត្តបានចំពោះមុខ អ.វ.ត.ក។ វាពិតជាមិនមាន

---

[១២០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៧, ដែលនិយាយយោងទៅដល់ដីកាដែលត្រូវបាន ជំទាស់ កថាខណ្ឌ ២១ ដែលបានដកស្រង់នូវ*សំណុំរឿង កាំង ហ្គេកអ៊ាវ* 001/18-07-2007-ECCC/PTC, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួន ឌុច កថាខណ្ឌ ២០។

[១២១] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២១។

[១២២] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២១។

[១២៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៧, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាឃុំខ្លួន ឌុច កថាខណ្ឌ ១៩។

[១២៤] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អង្គជំនុំជម្រះសាលាដំបូង សាលដីកាលើសំណើសុំដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារលេខ E39/5 កថាខណ្ឌទី១០។

00519433



ផលប៉ះពាល់មែននៅពេលពិចារណាពាក្យច្បាស់លាស់នៃមាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក ដែលគោលបំណងនៃច្បាប់នេះ គឺនាំយកមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា និងការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិនិងទំនៀមទម្លាប់អន្តរជាតិ ដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងករណីនេះ ច្បាប់អ.វ.ត.ក ក៏ចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការ ដែលមានសម្រាប់ក្នុងគោលបំណងនេះ។

៤៨. ការចោទប្រកាន់ដែលថា ក.ស.ច.ស ភាន់ច្រឡំក្នុងការសន្និដ្ឋានថា អ.វ.ត.ក អាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ និងដែលថា ពុំមានការលើកលែងណាមួយដែលអនុញ្ញាតឲ្យមានការយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តដោយផ្ទាល់ចំពោះរបបគតិយុត្តិពិសេស គឺត្រូវបានបដិសេធចោលដូចគ្នា[១២៥]។ ទឡ្ហីករណ៍ដែលថា អ.វ.ត.ក មិនអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ ពីព្រោះជាតុលាការជាតិរបស់ប្រទេសមួយដែលប្រកាន់យកប្រព័ន្ធទ្វិកនិយម និងក្នុង

---

[១២៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៥-៣២ ដែលនិយាយយោងទៅដល់ផ្នែកសំអាងហេតុនៅក្នុងដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២២ ដែលថា "ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានទទួលឥទ្ធិពលពីច្បាប់បារាំង ហើយតាមច្បាប់បារាំង ឧក្រិដ្ឋកម្មអន្តរជាតិដូចជាឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក គឺជាប្រភេទឧក្រិដ្ឋកម្មជាក់លាក់ តាម "របប" យុត្តាធិការស្វយ័ត ដែលខុសផ្សេងពីច្បាប់ឧក្រិដ្ឋកម្មជាតិ និងត្រូវបានកំណត់លក្ខណៈសម្គាល់ដោយបណ្តុំវិធាននៃនីតិវិធី និងខ្លឹមសារ"។ ខៀវ សំផន បានលើកឡើងនូវការតវ៉ាមួយស្រដៀងគ្នានេះ ដោយលើកទឡ្ហីករណ៍ថាច្បាប់បារាំងដែល ក.ស.ច.ស បានសំអាងក្នុងការគាំទ្រសំអាងហេតុរបស់ខ្លួនអំពីអត្ថិភាពនៃប្រព័ន្ធយុត្តាធិការស្វយ័ត ពុំបានមានអត្ថិភាពឡើយក្នុងអំឡុងរយៈកាលឆ្នាំ១៩៧៥-១៩៧៩ ប៉ុន្តែមានតែនៅក្នុងឆ្នាំ២០០២ ប៉ុណ្ណោះ ហើយផ្ទុយពីអ្វីដែលសហចៅក្រមស៊ើបអង្កេតលើកឡើង ទាក់ទិននឹង[ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ] បញ្ហានេះគឺបណ្តាលមកពី [ច្បាប់បារាំង] ជាធរមានចែងអំពីវិធានដែលតំណាងនូវការឃ្លាតចាកពីច្បាប់សាមញ្ញ ដែលសំណេររបស់អ្នកសាស្ត្រាចារ្យបញ្ជាវន្ត ចាត់ទុកឧក្រិដ្ឋកម្មទាំងនោះថាជាបទល្មើសពិសេសមួយប្រភេទ [...ហើយ] ពុំមែនផ្ទុយពីនោះឡើយ។ ចុងក្រោយ ប្រព័ន្ធយុត្តាធិការស្វយ័តសម្រាប់ឧក្រិដ្ឋកម្មទាំងនេះ តាមច្បាប់ឆ្នាំ២០០២ ពុំមានវិធានជាក់លាក់ណាមួយចែងអំពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលឡើយ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានគ្រប់គ្រងដោយវិធានសាមញ្ញនៃនីតិវិធី និងយុត្តាធិការ។ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន កថាខណ្ឌ ៦០-៦៦ និងចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៧-២១។

ពេលគ្មានសេចក្ដីណែនាំជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ឬយុត្តាសាស្ត្រជាតិ ឱ្យយកច្បាប់ទំនៀមទម្លាប់ទៅច្របាច់បញ្ចូលជាមួយច្បាប់ជាតិនោះទឡ្ហីករណ៍នេះគ្មានមូលដ្ឋាន។ ការអះអាងបែបនេះផ្ទុយខុសស្រឡះពីបទប្បញ្ញត្តិចែងយ៉ាងច្បាស់នៃមាត្រា២ នៃច្បាប់ អ.វ.ត.ក ដែលអាចត្រឹមតែនាំឱ្យគេសន្និដ្ឋានថា អ.វ.ត.ក មានយុត្តាធិការក្នុងការយកមកអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវ ដែលគេបានទទួលស្គាល់តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងពេលវេលាដែលពាក់ព័ន្ធ។ តាមហេតុផលដូចគ្នានេះ បើទោះបីជាផ្នែកសំអាងហេតុស្ដីពីរបបគតិយុត្តិពិសេសរបស់ ក.ស.ច.ស មានកំហុសឆ្គងក្ដី ក៏វាពុំមានប្រយោជន៍ ហើយអាចនឹងធ្វើឱ្យអសុពលភាពទៅដល់ផ្នែកសំអាងហេតុស្ដីពីការយក JCE មកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ឡើយ។

៤៩. ទាក់ទិនទៅនឹងការចោទប្រកាន់ដែលថា "ក.ស.ច.ស មានកំហុសឆ្គងក្នុងការទទួលស្គាល់ថា ការទទួលខុសត្រូវតាមទម្រង់ JCE ដូចតាមការតាក់តែងរបស់អង្គជំនុំជម្រះតុលាការកំពូលលើ *រឿងក្ដី Tadić* អាចស្ថិតនៅក្នុងប្រភេទនៃ "ការប្រព្រឹត្ដិ" ត្រង់មាត្រា២៩ នៃ[ច្បាប់ អ.វ.ត.ក]"[១២៦] នោះអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មាត្រា២៩ នេះ ដូចនឹងមាត្រា៦ នៃលក្ខន្តិកៈតុលាការ ICTR និងមាត្រា៧ នៃលក្ខន្តិកៈតុលាការ ICTY។ តុលាការ*មិនអចិន្ត្រៃយ៍*បានបញ្ជាក់ដោយស្របគ្នាថា ខ្លួនបានចាត់ទុកការចូលរួមក្នុង JCE ថាជាទម្រង់មួយនៃ "ការប្រព្រឹត្ដិ"[១២៧]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ដោយគិតដល់យុត្តិសាស្ត្រពីមុនដ៏មានសង្គតិភាពនេះ ប្រសិនបើអ្នកតាក់តែងច្បាប់ អ.វ.ត.ក មានបំណងចង់កំណត់ "ការប្រព្រឹត្ដិ" ដែលមានចែងនៅក្នុងមាត្រា២៩ ត្រឹមតែជនដែលប្រព្រឹត្តដោយផ្ទាល់ដៃនូវ *អំពើពិរុទ្ធ* (actus reus) នៃបទល្មើសមែននោះ ពួកគាត់នឹងកំណត់ឱ្យបានច្បាស់ជាក់ជាមិនខានឡើយ។

៥០. ពេលនេះ អង្គបុរេជំនុំជម្រះសូមបង្វែរមកនិយាយអំពីចំណុចសំខាន់នៃបណ្ដឹងឧទ្ធរណ៍នេះម្ដង ពោលគឺថាតើនៅក្នុងឆ្នាំ១៩៧៥-១៩៧៩ មានមូលដ្ឋានច្បាប់ទំនៀមទម្លាប់ណាមួយសម្រាប់ JCE និងទម្រង់ប្រព័ន្ធ ឬទម្រង់ទូលាយរបស់វាដែរឬទេ ហើយប្រសិនបើមាន សួរថាតើទម្រង់នៃការទទួលខុសត្រូវ

---

[១២៦] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២.ឃ, ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៤០-៥០។

[១២៧] សូមមើលជាពិសេស សាលដីកាបណ្ដឹងឧទ្ធរណ៍ JCE *Ojdanić* កថាខណ្ឌ ១២-១៨ ដែលនិយាយយោងទៅដល់ *Tadić* និងច្បាប់យុត្តិសាស្ត្រពាក់ព័ន្ធបន្តបន្ទាប់។

ទាំងអស់នោះ មានលក្ខណៈគ្រប់គ្រាន់ ក្នុងការឲ្យជនជាប់ចោទអាចដឹងថាមានច្បាប់ចែង និងអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋដែរឬទេ។

## ក. តើទស្សនទាននៃ JCE ត្រូវបានទទួលស្គាល់ថា ជាទម្រង់មួយនៃការទទួលខុសត្រូវតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនឆ្នាំ១៩៧៥ ដែរឬទេ?

### ១. សារណា

៥១. មូលដ្ឋានទី៧នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និងកំហុសឆ្គងទី៣ ដែលរងការចោទប្រកាន់ពីសំណាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី មានទឡ្ហីករណ៍ពាក់ព័ន្ធមួយចំនួនខាងក្រោម៖ i) នៅក្នុងដីកាដែលត្រូវបានជំទាស់ ពុំមានមូលដ្ឋានសម្រាប់ការសន្និដ្ឋានថា ទម្រង់ទាំង៣នៃ JCE បានបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងពេលពាក់ព័ន្ធឡើយ[១២៨] និង ii) ក.ស.ច.ស មានកំហុសឆ្គង ក្នុងការខកខានពុំបានធ្វើការវិភាគឯករាជ្យណាមួយពាក់ព័ន្ធទៅនឹងថាតើការទទួលខុសត្រូវតាមទម្រង់ JCE បានបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥-១៩៧៩ ដែរឬទេ[១២៩]។ បណ្តឹងឧទ្ធរណ៍ទាំងនោះចោទប្រកាន់ថា ក.ស.ច.ស បានសន្និដ្ឋានដោយពុំត្រឹមត្រូវថា JCE បានបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងរយៈកាល

---

[១២៨] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៦០,៧២,៧៣ (ក)។ ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបាននិយាយលម្អិតអំពីមូលហេតុនៃការខ្វះខាតមូលដ្ឋាននេះឡើយ។ ជាសំខាន់ គាត់គ្រាន់តែអះអាងថាមូលដ្ឋានទំនៀមទម្លាប់របស់ JCE "សម្រាប់តុលាការ ICTY" គឺមានលក្ខណៈ ចម្រូងចម្រាសខ្លាំង និងមិនគួរត្រូវបានដាក់មកលើកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ឡើយ ដោយគាំទ្រអំណះអំណាងនេះដោយយោងតាម M. Sassoli & L. M. Olson, *the Judgement of the ICTY Appeals Chamber on the Merits in the Tadić Case*, INT'L REV. RED CROSS 839, ទំព័រ ៧ (loc. cit. 60-62),ដែលបានបញ្ជាក់អំពីភាពចម្រូងចម្រាសទាក់ទិននឹងមូលហេតុដែលអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY រៀបរាប់លម្អិតអំពីច្បាប់យុត្តិសាស្ត្រអ៊ីតាលី ក្នុងការគាំទ្រដល់ទ្រឹស្តី JCE ខណៈពេលដែលស្ទើរតែមិនអើពើដល់ច្បាប់យុត្តិសាស្ត្រហូឡង់ និងអាឡឺម៉ង់ ដែលពុំគាំទ្រទ្រឹស្តី JCE។ គាត់ក៏បាននិយាយយោងទៅដល់ A. M. Danner & J. S. Martinez, "Guilty by Association: Joint Criminal Enterprise, Command Responsibility and the Development of International Criminal Law", ខែមីនា ឆ្នាំ២០០៤។ សូមមើលផងដែរនូវ ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៩-៣០។

[១២៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២.គ។

ពាក់ព័ន្ធតាមហេតុផលមួយចំនួនដូច។ ទីមួយ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បាន កំណត់ដោយពុំត្រឹមត្រូវថា ការទទួលខុសត្រូវតាមទម្រង់ JCE បានមានអត្ថិភាពតាមច្បាប់ទំនៀម ទម្លាប់អន្តរជាតិ[១៣០] នេះក៏ដោយសារខ្លួនបានសំអាងទៅលើតែករណីមួយចំនួនតូចប៉ុណ្ណោះ[១៣១] ហើយតាមការពិត សន្ធិសញ្ញាទាំងអម្បាលម៉ានដែលខ្លួនបានលើកយកមកសំអាងនោះ ពុំគាំទ្រដល់ ការទទួលខុសត្រូវតាមទម្រង់ JCE ដូចការអះអាងឡើយ ដោយហេតុថាសន្ធិសញ្ញាទាំងនោះពុំមាន អត្ថិភាពនៅក្នុងឆ្នាំ១៩៧៥-១៩៧៩[១៣២]ទេ។ លើសពីនេះ ក្នុងចំណោរក្រោយមកទៀត តុលាការ ICC "ក៏បានបដិសេធពុំទទួលស្គាល់ផងដែរនូវយុត្តិសាស្ត្រនៃ JCE របស់តុលាការមិនអចិន្ត្រៃយ៍ ដោយ តុលាការនេះពេញចិត្ត "ការគ្រប់គ្រងទៅលើវិធីសាស្ត្រឧក្រិដ្ឋកម្ម" ដែលបានបែងចែកដាច់ពីគ្នារវាង អាទិចារី និងអ្នកសមគំនិត" បើទោះបីឯកសារការងារត្រៀមរៀបចំ "*(Travaux préparatoires)* នៃ [អនុសញ្ញាអន្តរជាតិសម្រាប់បង្ក្រាបទៅលើការបំផ្ទុះគ្រាប់បែករបស់ភេរវជន] ពុំមានពន្យល់មូល ហេតុណាមួយចំពោះការប្រើប្រាស់ពាក្យពេចន៍មួយ ចំនួននៅក្នុងមាត្រា២ ក៏ដោយ"[១៣៣]។ ទីពីរ ការ ទទួលខុសត្រូវតាមទម្រង់ JCE ពុំធ្លាប់ជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានរដ្ឋយកទៅប្រើ ប្រាស់ជាទូទៅប្រកបដោយសង្គតិភាពឡើយ។ ច្បាប់យុត្តិសាស្ត្រ Nuremberg ពុំគាំទ្រនូវអត្ថិភាពនៃ ការទទួលខុសត្រូវតាមទម្រង់ JCE ឡើយ[១៣៤] ហើយប្រព័ន្ធច្បាប់ភាគច្រើនជ្រើសរើសយកទម្រង់នៃ

---

[១៣០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៦-៣៧។

[១៣១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៨-៤០ បានបញ្ជាក់ថាអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ *Tadić* គ្រាន់តែបានពឹង ផ្អែកទៅលើរឿងក្តីចំនួន៦ប៉ុណ្ណោះ ក្នុងការបង្កើតឱ្យមានទម្រង់ទី១នៃJCE និងរឿងក្តីចំនួន២ទៀត ដើម្បីបង្កើតឱ្យមានJCE II, ហើយសំអាងលើរឿងក្តី២ទៀតដើម្បីបង្កើតឱ្យមានJCE III។ បណ្តឹងឧទ្ធរណ៍នេះបានអះអាងថាច្បាប់ទំនៀម ទម្លាប់អន្តរជាតិ អាចត្រូវបានកំណត់ ដោយគ្រាន់តែយោងតាមទម្លាប់អនុវត្តន៍របស់រដ្ឋគ្រប់ទិសទីប្រកបដោយសង្គតិភាព និង*ទស្សនៈនៃច្បាប់* ប៉ុណ្ណោះ ហើយសេចក្តីថ្លែងការណ៍និយាម នៅក្នុងសេចក្តីសម្រេចរបស់តុលាការគួរត្រូវបានចាត់ទុកត្រឹមតែជាច្បាប់ទំនៀមទម្លាប់ ដែល កំពុងផុសចេញរូបរាងប៉ុណ្ណោះ ពុំមែនជាវិធានគតិយុត្តិវិជ្ជមានឡើយ។ ដើម្បីប្តូរច្បាប់នេះឱ្យទៅជាច្បាប់ទំនៀមទម្លាប់ពិត ប្រាកដ ចាំបាច់រដ្ឋក្នុងចំនួនភាគច្រើនត្រូវយកច្បាប់នេះទៅបញ្ជាក់អះអាងនៅក្នុងការអនុវត្ត គួបផ្សំជាមួយនឹង*ទស្សនៈនៃច្បាប់* ផង។

[១៣២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៧។

[១៣៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៤១-៤២។

[១៣៤] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ៤៤។ យោងតាមបណ្តឹងឧទ្ធរណ៍នេះ នៅឯតុលាការ Nuremberg ដោយអនុវត្ត តាមវិធីសាស្ត្រច្បាប់ទូទៅ "ជនជាប់ចោទពុំត្រូវបានចាត់ទុកថាជា "ចារី" ឬ "អ្នកសមគំនិត" សេចក្តីសម្រេចមានលក្ខណៈខ្លី

00519437



ការរួមប្រព្រឹត្ត ដែលខុសពី JCE ដែលបានបែងចែកដាច់ពីគ្នារវាងការទទួលខុសត្រូវក្នុងនាមជាអាទិចារី និងជនសមគំនិត[១៣៥]។ លក្ខន្តិកៈតុលាការ ICC ពុំយកការទទួលខុសត្រូវតាមទម្រង់ JCE ទៅចងក្រងធ្វើជាច្បាប់ឡើយ ហើយយុត្តិសាស្ត្ររបស់ខ្លួនក៏បានបដិសេធមិនទទួលស្គាល់ផងដែរ នូវការយកការទទួលខុសត្រូវតាមទម្រង់ JCE មកអនុវត្ត[១៣៦]។ ទីបី គ្រោះថ្នាក់ពីធម្មជាតិនៃការទទួលខុសត្រូវតាមទម្រង់ JCE មានឥទ្ធិពលរារាំង អ.វ.ត.ក ក្នុងការយកគោលការណ៍នេះមកធ្វើជាសំអាង[១៣៧]។ ទីបួន ប្រសិនបើ JCE ត្រូវបានគេទទួលស្គាល់ថា ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

មានសំអាងហេតុបន្តិចបន្តួច ហើយ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ *Tadić* ត្រូវទាញសន្និដ្ឋានអំពីទម្រង់នៃការទទួលខុសត្រូវដោយផ្អែកតាមកំណត់ហេតុរបស់រដ្ឋអាជ្ញា។ យោងតាមម្ចាស់បណ្ដឹងឧទ្ធរណ៍ ក៏មានគំរូមួយចំនួនស្ដីពីរឿងក្ដីនានានៅក្រោយសម័យសង្គ្រាមលោកលើកទី២ ដូចជារឿងក្ដី *Justice* ដែលក្នុងនោះទម្រង់ទូលាយនៃការទទួលខុសត្រូវតាមទម្រង់ JCE ពុំត្រូវបានយកមកប្រើប្រាស់ឡើយ, បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៤៦។

[១៣៥] បណ្ដឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ៤៧-៤៨។

[១៣៦] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៤៩-៥៨ ដោយយោងទៅដល់ជំហរដែល ត្រូវបានប្រកាន់យកដោយអង្គបុរេជំនុំជម្រះតុលាការ ICC នៅក្នុងរឿងក្ដី *Lubanga* ដែលពេញចិត្តនឹងវិធីសាស្ត្រ “ការគ្រប់គ្រងលើវិធីសាស្ត្រឧក្រិដ្ឋកម្ម” ដែលញែកដាច់ពីគ្នារវាង អាទិចារី និងអ្នកសមគំនិត ជាជាងវិធីសាស្ត្រអត្តនោម័ត JCE។ យោងតាមម្ចាស់បណ្ដឹងឧទ្ធរណ៍ “អ.វ.ត.ក ពុំអាចគ្រាន់តែទទួលយកសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងរឿងក្ដី *Stakić* បានឡើយ [ដែលថាទម្រង់ “ការគ្រប់គ្រងលើឧក្រិដ្ឋកម្ម” នៃការរួមប្រព្រឹត្ត ដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកអនុវត្ត ពុំមានការគាំទ្រនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ] ដោយពុំបានពន្យល់មូលហេតុដែលខ្លួនយល់ឃើញថាអង្គជំនុំជម្រះ *Stakić* និងតុលាការ ICC មានកំហុសឆ្គង” បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៥៧។

[១៣៧] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៥៩-៦២ ត្រង់ចំណុចដែលម្ចាស់បណ្ដឹងឧទ្ធរណ៍ លើកទឡ្ហីករណ៍ថា ការកំណត់នៅក្នុងរឿងក្ដី បានត្រូវបានលើកយកមកសំអាងនៅក្នុងដីកាដែលត្រូវ បានជំទាស់ ដែលថា JCE II គឺជាកែប្រែពី JCE I គឺនាំឱ្យមានការយល់ខុស និងមិនពិត ដោយហេតុថា “ JCE II តែងដូចគ្នាទៅនឹង JCE III ពុំមែន JCEI ទេ” ហើយ ការសំអាងទៅលើសារណាមិត្តតុលាការ Ambos ដែលថា “ពុំមាន *ចេតនាឧក្រិដ្ឋ* ដែលត្រូវបានគេទទួលស្គាល់ជាទូទៅ សម្រាប់ JCE III” ទម្រង់នៃការទទួលខុសត្រូវ *ជំនួស* មួយដែលបានទទួលការរិះគន់ខ្លាំងពីសំណាក់បញ្ញវន្ត ដែលមិនស្របជាមួយនឹងគោលការណ៍នៃការទទួលខុសត្រូវ បើទោះបីគេបានប្រើប្រាស់វិធីសាស្ត្រអត្តនោម័តក្ដី ដោយហេតុថាការតម្រូវឱ្យជនត្រូវចោទបានដឹងឮគ្រប់គ្រាន់ថាឧក្រិដ្ឋកម្មបន្ថែមណាមួយគឺជាផលវិបាកតាមធម្មជាតិ និងអាចដឹងមុនបានសម្រាប់ខ្លួន គឺ “ពុំអាចកើតមានឡើងដោយសមហេតុផលឡើយ។ ការដឹងឮគឺជាបទដ្ឋានមួយសម្រាប់ចេតនាឧក្រិដ្ឋ[...] បើទោះបីភាពអាចដឹងមុនស្ថិតក្នុងគោលការណ៍ទ្រឹស្ដីនៃភាពធ្វេសប្រហែស ឬមិនអើពើក្ដី”។




PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

នោះគេនឹងយកវាមកអនុវត្តដោយកំណត់ត្រឹមតែការរួមប្រព្រឹត្តប៉ុណ្ណោះ ដូចដែលមានចែងស្រាប់ក្នុងច្បាប់កម្ពុជា[១៣៨]។

៥២. ក.ស.ព បានឆ្លើយតបថា ក.ស.ច.ស "បានប្រកាសដោយត្រឹមត្រូវថាទម្រង់ទាំង៣នៃ JCE ធ្លាប់ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីមុនឆ្នាំ១៩៧៥-១៩៧៩ មកម្ល៉េះ"[១៣៩]។ ក.ស.ព បានចាត់ទុក "លក្ខន្តិកៈអន្តរជាតិ រឿងក្តី និងសេចក្តីសម្រេចតាមផ្លូវច្បាប់ជាច្រើន ព្រមទាំងរឿងក្តីក្នុងស្រុកផងដែរ ដែលសុទ្ធតែបានគាំទ្រនូវអត្ថិភាពកាលពីមុនរបស់ JCE ចាប់តាំងពីមានតុលាការព្រហ្មទណ្ឌ Nuremberg [...ថាជា]ភស្តុតាងនៃទម្លាប់អនុវត្តរបស់រដ្ឋនៅគ្រប់ទិសទី និងទស្សនៈច្បាប់ (opinio juris) ដែលបង្កើតឱ្យមានច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[១៤០]។ ក.ស.ព បានឆ្លើយ

---

[១៣៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៦៣-៦៥ ត្រង់កន្លែងដែល ម្ចាស់បណ្តឹងឧទ្ធរណ៍ យោងទៅដល់សារណាមិត្តតុលាការ Kai Ambos កថាខណ្ឌ ១១ ។ យោងតាមសារណានោះ "លក្ខខណ្ឌតម្រូវនៃការរួមប្រព្រឹត្តត្រូវបានបំពេញដោយ JCE I តែប៉ុណ្ណោះ ហើយបើទោះបី គេបានចាត់ទុកវាថាជារចនាសម្ពន្ធអត្តនោម័ត-សត្យានុម័ត ដោយតម្រូវឱ្យមានការប្រព្រឹត្តិជាក់ស្តែងរបស់សមាជិករបស់នូវអំពើណាមួយ ក្រៅតែពីគោលបំណង ឬឆន្ទៈរួម"។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងករណីបន្ថែមទៀតថា "ដោយហេតុថាការរួមប្រព្រឹត្តគឺជាទម្រង់ មួយនៃការទទួលខុសត្រូវរួចទៅហើយនោះ ដែលមានចែងនៅក្នុងច្បាប់កម្ពុជាពុំមានហេតុផលណាមួយដែលត្រូវយក JCE I មកអនុវត្តជាទម្រង់នៃការទទួលខុសត្រូវមួយដោយឡែកឡើយ ជាពិសេសដោយគិតដល់ការពិតដែលថា "អ.វ.ត.ក ត្រូវធ្វើជា "គំរូ" សម្រាប់តុលាការកម្ពុជា" ហើយ "រដ្ឋាភិបាលកម្ពុជាបានបដិសេធយ៉ាងច្បាស់ក្រឡែតនូវការទទួលខុសត្រូវតាមទម្រង់ JCE" ក្នុងពេលអនុម័តក្រមព្រហ្មទណ្ឌថ្មីរបស់ខ្លួន។ សូមមើលផងដែរចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៣២-៣៩ ដែលបានអះអាងថា ការទទួលខុសត្រូវតាមទម្រង់ JCE គឺគេពុំអាចដឹងជាមុនបាននៅកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩។

[១៣៩] ចម្លើយតបរួម របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២ ដោយយោងទៅដល់ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២១។

[១៤០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២ ដោយយោងទៅដល់ចម្លើយតបរបស់ សហព្រះរាជអាជ្ញាចំពោះសារណារបស់ អៀង សារី ស្តីពីសហឧក្រិដ្ឋកម្មរួម ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ D97/II ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី១១ ខែសីហា") និង សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ D97/8 ("សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា")។ សហព្រះរាជអាជ្ញាក៏បានយោងទៅដល់ "ការដកទម្រង់ "ផែនការរួម" នៃការទទួលខុសត្រូវនៅក្នុងធម្មនុញ្ញ Nurember និងនៅក្នុង Allied Control Council Law លេខ ១០ និងសេចក្តីសម្រេចនានារបស់បណ្តាសាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមនាក្រោយសម័យសង្គ្រាមលោកលើកទី ២" ដែលសេចក្តីសម្រេចចំនួន ១០ ត្រូវបានលើកឡើងនៅក្នុងរឿងក្តី *Tadić* ក្នុងនោះសេចក្តីសម្រេចចំនួន ៦ គាំទ្រ JCE I, ២ទៀតគាំទ្រ JCE II, និង ២ គាំទ្រ JCE III ដែលអះអាងថា "JCE ដែលមានទម្រង់ច្បាស់លាស់ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ" (សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា

តបទៅនឹងការមិនទទួលស្គាល់នូវទម្រង់ទូលាយនៃ JCE តាមរយៈការលើកទឡ្ហីករណ៍ថា "យុត្តាធិការក្នុងសម័យទំនើបៗជាច្រើន បានទទួលស្គាល់ទម្រង់នៃការរួមប្រព្រឹត្ត ដែលស្រដៀងគ្នាទៅនឹង JCE III [ក្នុងនោះរួមមាន] គោលការណ៍ស្តីពីការសមគំនិត ទ្រឹស្តីបទល្មើសមនុស្សឃាដ [និង] ទស្សនទាននៃសហឧក្រិដ្ឋកម្ម *(associatioin de malfaiteurs)* [ព្រមទាំង] គោលការណ៍នៃការរួមប្រព្រឹត្តមួយចំនួនផ្សេងទៀត (ទឡ្ហីករណ៍ទាំងអស់នេះត្រូវបានលើកយកមកពិចារណាត្រង់ផ្នែកខាងក្រោម)[១៤១]។ យោងតាម ក.ស.ព ការលើកទឡ្ហីករណ៍ថាផ្នែកសំអាងហេតុនៅក្នុងរឿងក្តី *Tadić* ដែលថា JCE គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយបានផ្អែកមូលដ្ឋានទៅលើរឿងក្តីតែមួយចំនួនតូចពីយុត្តាធិការមួយចំនួនតូចនោះ គឺមិនអើពើដល់ភស្តុតាងសំខាន់ៗជាច្រើនសន្ធឹកសន្ធាប់ដែលគាំទ្រសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY។

## ២. ការពិភាក្សា

### (i) កំណត់សម្គាល់ទូទៅ

៩៣. អង្គបុរេជំនុំជម្រះសូមរំលឹកថា ក្នុងពេលកំណត់លក្ខណៈរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិទាក់ទិននឹងអត្ថិភាពនៃឧក្រិដ្ឋកម្មមួយ ឬទម្រង់នៃការទទួលខុសត្រូវជាលក្ខណៈបុគ្គល តុលាការត្រូវវាយតម្លៃអំពីអត្ថិភាពនៃទម្លាប់អនុវត្តន៍"ទូទៅប្រកបដោយសង្គតិភាព និងរលូន" របស់រដ្ឋ"[១៤២] ឬ*ទស្សនៈ*

---

កថាខណ្ឌ ១០)។ ពួកគាត់ក៏បាននិយាយទៅដល់របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិអង្គការសហប្រជាជាតិ ស្តីពីការងាររបស់វគ្គលើកទី៤៨ ថ្ងៃទី៦ ខែឧសភា ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦។ យោងតាមរបាយការណ៍នោះ លិខិតុបករណ៍អន្តរជាតិដែលបានលើកឡើងខាងលើ "ផ្តល់ កំណើតទៅដល់គំរូរបស់អន្តរជាតិទាំងមូលអំពីការទទួលខុសត្រូវឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល" និងយោងតាមអង្គហេតុដែលថា នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ "អង្គមហាសន្និបាតអង្គការសហប្រជាជាតិ បានសម្រេចជាឯកច្ឆន្ទគាំទ្រគោលការណ៍នានាដែលដកចេញពីធម្មនុញ្ញ Nurember និងសាលក្រម សាលដីកាផ្សេងៗ" (ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥)។

[១៤១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣ ដោយយោងទៅដល់សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០& nn.22-26។

[១៤២] *Fisheries Jurisdiction Case (United Kingdom v Iceland)*, អង្គសេចក្តី 1974 ICJ Rep. 3, at 50។

00519440



*ច្បាប់*[១៤៣] ពោលគឺ អ្វីដែលរដ្ឋនានាយកមកអនុវត្ត និងនិយាយនោះ តំណាងឲ្យច្បាប់។ ទម្លាប់អនុវត្តន៍ជាច្រើនរបស់រដ្ឋពុំសូវភ្ជាប់មកជាមួយនូវការសន្មតជាមុនថា ទស្សនៈច្បាប់មានអត្ថិភាពឡើយ។ "អំពើដែលពាក់ព័ន្ធមិនត្រូវបានរាប់ថាត្រឹមតែជាទម្លាប់អនុវត្តអចិន្ត្រៃយ៍ប៉ុណ្ណោះទេ ប៉ុន្តែអំពើទាំងនោះត្រូវតែជាទម្លាប់អនុវត្តន៍អចិន្ត្រៃយ៍ ឬត្រូវបានយកមកអនុវត្តក្នុងលក្ខណៈអាចជាភស្តុតាងឱ្យគេជំនឿថាទម្លាប់អនុវត្តន៍នេះជាកាតព្វកិច្ច តាមរយៈអត្ថិភាពនៃវិធាននៃច្បាប់ដែលតម្រូវឲ្យមានទម្លាប់អនុវត្តន៍នេះ"[១៤៤]។ ដោយហេតុថាតាមការឯកភាព រដ្ឋជាអ្នកកំណត់អត្ថន័យនៃច្បាប់អន្តរជាតិ ហើយសេចក្ដីសម្រេចនានារបស់តុលាការគឺពិតជាបានបង្កើតជា "មធ្យោបាយបន្ទាប់បន្សំក្នុងការកំណត់អំពីវិធាននៃច្បាប់"[១៤៥]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ពុំមានភាពច្បាស់លាស់ថាតើ "គោលការណ៍ទូទៅនៃច្បាប់ដែលបានការទទួលស្គាល់ពីសំណាក់បណ្ដាប្រទេសមានអារ្យធម៌ខ្ពង់ខ្ពស់"[១៤៦] គួរត្រូវបានទទួលស្គាល់ថាជាប្រភពគោល ឬជាប្រភពបន្ទាប់បន្សំនៃច្បាប់អន្តរជាតិ ឬយ៉ាងណា។ បើទោះបីជាយ៉ាងដូច្នេះក្ដី គោលការណ៍ទូទៅទាំងអស់នេះត្រូវបានតុលាការ ICTY លើកយកមកពិចារណានៅក្នុងពេលកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ[១៤៧] ឬវិសាលភាពនៃទម្រង់នៃការទទួលខុសត្រូវ[១៤៨] ឬក៏បើមិនដូច្នោះទេ គេគួរទទួលស្គាល់គោលការណ៍ទាំងនេះនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

---

[១៤៣] មាត្រា ៣៨(១) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិឆ្នាំ១៩៤៦ ដែលត្រូវបានទទួលស្គាល់ជា ទូទៅថាជាសេចក្ដីប្រកាសស្ថាពររបស់ប្រភពនៃច្បាប់អន្តរជាតិតម្រូវឲ្យតុលាការនៅក្នុងប្រការផ្សេងៗ ត្រូវយកមកអនុវត្តនូវ "ទំនៀមទម្លាប់អន្តរជាតិ ដែលជាភស្តុតាងបញ្ជាក់អំពី ទម្លាប់អនុវត្តន៍ទូទៅដែលត្រូវបានទទួលស្គាល់ជាច្បាប់"។

[១៤៤] *North Sea Continental Shelf (Federal Republic of Germany v. Denmark, Federal Republic of Germany v. Netherlands)*, អង្គសេចក្ដី ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៦៩ ICJ Rep. 3, កថាខណ្ឌ ៧៧។

[១៤៥] អនុកថាខណ្ឌ (ឃ) នៃមាត្រា ៣៨(១) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិឆ្នាំ១៩៤៦។

[១៤៦] អនុកថាខណ្ឌ (គ) នៃមាត្រា ៣៨(១) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិឆ្នាំ១៩៤៦។

[១៤៧] ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្ដី *Furundžija* បានបញ្ជាក់ថា "ដើម្បីឈានដល់ការកំណត់និយមន័យត្រឹមត្រូវនៃពាក្យថារំលោភសេពសន្ថវៈ ដោយផ្អែកតាមគោលការណ៍ជាក់លាក់នៃច្បាប់ឧក្រិដ្ឋកម្ម [...] ចាំបាច់គេត្រូវស្វែងរកគោលការណ៍នៃច្បាប់ឧក្រិដ្ឋកម្មដែលមានលក្ខណៈសាមញ្ញចំពោះប្រព័ន្ធច្បាប់ឧក្រិដ្ឋកម្មរបស់ពិភពលោក។ គោលការណ៍ទាំងនេះអាចចេញមកពីច្បាប់ជាតិ"។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង *Furundžija* កថាខណ្ឌ ១៧៧។

[១៤៨] សាលដីកាបណ្ដឹងឧទ្ធរណ៍ *Blaškić* កថាខណ្ឌ ៣៤-៤២។

៥៤. សាលដីការបស់តុលាការ ICTY លើរឿងក្តី *Tadić* គឺជាសាលដីកាលើកដំបូងនៃតុលាការអន្តរជាតិ ដែលតាមដានស្វែងយល់អំពីអត្ថិភាព និងការវិវត្តនៃគោលការណ៍ JCE ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ សាលដីកានេះរកឃើញថា "សង្គតិភាព និងអនុភាពនៃច្បាប់យុត្តិសាស្ត្រ និងសន្ធិសញ្ញាដែល [ខ្លួន] បាននិយាយយោងដល់ [...] និងភាពស៊ីគ្នាជាមួយគោលការណ៍ទូទៅស្តីពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មត្រូវបានចែងនៅក្នុងលក្ខន្តិកៈ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិទូទៅ និងនៅក្នុងច្បាប់ជាតិ" អាចឱ្យគេសន្និដ្ឋានថា ច្បាប់យុត្តិសាស្ត្រឆ្លុះបញ្ចាំងនូវវិធានទំនៀមទម្លាប់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ"[១៤៩]។ ដូច្នេះ ដីកាដែលត្រូវបានជំទាស់មានភាពសមហេតុផល នៅពេលយកសេចក្តីសម្រេចដ៏មានសារសំខាន់ខាងលើរបស់តុលាការ ICTY ស្តីពី JCE ធ្វើជាអំណះអំណាងដ៏គួរឱ្យជឿជាក់សម្រាប់ខ្លួនក្នុងការសន្និដ្ឋានថា "ដោយពិចារណាទៅដល់លក្ខណៈអន្តរជាតិនៃ អ.វ.ត.ក និងការពិតដែលថា យុត្តិសាស្ត្រដែលគេបានយកមកសំអាងនៅក្នុងការបញ្ជាក់អំពី JCE មានអត្ថិភាពនៅមុនពេលហេតុការណ៍ក្រោមកិច្ចស៊ើបសួរនៅ អ.វ.ត.ក គេមានមូលដ្ឋានមួយតាមច្បាប់អន្តរជាតិក្នុងការយក JCE មកអនុវត្តនៅចំពោះមុខ អ.វ.ត.ក"[១៥០]។

៥៥. ក្នុងការឈានដល់សេចក្តីសំអាងហេតុរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY *ក្នុងរឿងក្តី Tadič* បានបកស្រាយលក្ខន្តិកៈតុលាការ ICTY ដោយឈរលើមូលដ្ឋាននៃគោលបំណងរបស់ខ្លួន ដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិផ្ញើជូនក្រុមប្រឹក្សាសន្តិសុខ[១៥១]។ អង្គជំនុំជម្រះតុលាការកំពូលមួយនេះ ក៏បានពិចារណាអំពីលក្ខណៈ

---

[១៤៩] សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ២២៦។

[១៥០] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២១ ដោយយោងទៅដល់សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ១៨៥ et seq។ ដីកាដែលត្រូវបានជំទាស់នេះគ្រង់កន្លែងផ្សេងបានសំអាងលើ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ស្តីពី JCE *Ojdanić* ទាក់ទិននឹងការ យកគោលការណ៍នីត្យានុកូលភាព មកអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ ឧក្រិដ្ឋកម្មអន្តរជាតិ និងចំពោះរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krajišnik*, IT-00-39-A, សាលដីកា, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ("សាលដីកាបណ្តឹងឧទ្ធរណ៍ *Krajišnik*") និង *Kvočka et al.* និងសាលដីកាបណ្តឹងឧទ្ធរណ៍ *Brđjanin* ទាក់ទិននឹងសម្ភារៈ មួយចំនួន ឬធាតុផ្សំខាងស្មារតីនៃទម្រង់ផ្សេងៗនៃ JCE។

[១៥១] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ (១៩៩៣) U.N. Doc. S/25704 ថ្ងៃទី ៣ ខែឧសភា ឆ្នាំ១៩៩៣។



ECCC * CETC PRE-TRIAL CHAMBER CHAMBRE

សម្គាល់ជាក់លាក់មួយចំនួន នៃឧក្រិដ្ឋកម្មជាច្រើនដែលត្រូវបានប្រព្រឹត្តនៅក្នុងសង្គ្រាម។ នៅត្រង់ប្រការនេះ អង្គបុរេជំនុំជម្រះឯកភាពជាមួយវិធីសាស្ត្រនៅក្នុងរឿងក្តី *Tadić* ដែលថា គេត្រូវតែយល់អំពីការវិវត្តនៃទម្រង់នៃការទទួលខុសត្រូវ ដែលគេអាចយកមកអនុវត្តបានចំពោះការរំលោភច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ដោយគិតទៅដល់លក្ខណៈនៃឧក្រិដ្ឋកម្មទាំងនេះ ដែលតែងតែត្រូវបានប្រព្រឹត្តដោយក្រុមមនុស្សដើម្បីសម្រេចតាមគម្រោងការឧក្រិដ្ឋរួម[១៥២]។ តាមន័យនៅក្នុងរឿងក្តី *Tadić* "បើទោះបីជាមានតែសមាជិកមួយចំនួនប៉ុណ្ណោះនៃក្រុមនេះអាចប្រព្រឹត្តដោយផ្ទាល់នូវអំពើឧក្រិដ្ឋកម្មក្តី ក៏ការចូលរួមនិងការរួមចំណែករបស់សមាជិកឯទៀតនៃក្រុមនេះ តែងជួយជាប្រយោជន៍ទៅដល់ការសម្រួលឲ្យមានការប្រព្រឹត្តិបទល្មើស។ ដូច្នេះស្ថានទម្ងន់ទោសនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម តែងតែពុំសូវមានលក្ខណៈស្រាលជាង ឬខុសគ្នាប៉ុន្មានពីស្ថានទម្ងន់ទោសនៃមនុស្សដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ[១៥៣]"។ ឧក្រិដ្ឋកម្មទាំងអស់នេះខុសពីឧក្រិដ្ឋកម្មធម្មតា មិនមែនត្រឹមតែត្រង់ទំហំទ្រង់ទ្រាយប៉ុណ្ណោះទេ ប៉ុន្តែដោយសារឧក្រិដ្ឋកម្មទាំងនេះតែងកើតមានក្នុងអំឡុងជម្លោះផងដែរ។ ផ្ទុយពីឧក្រិដ្ឋកម្មធម្មតាដែលត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ ឬមនុស្សមួយក្រុមតូច ឧក្រិដ្ឋកម្មទាំងនេះតែងតែត្រូវបានប្រព្រឹត្តឡើង តាមរយៈការចូលរួមរបស់ស្ថាប័នរដ្ឋ ដើម្បីសម្រេចតាមគោលនយោបាយឧក្រិដ្ឋ និងតាមរយៈការប្រើប្រាស់នូវរាល់គ្រប់មធ្យោបាយទាំងអស់ដែលមានចំពោះគោលបំណងឧក្រិដ្ឋទាំងនោះ។

៥៦. ដើម្បីកំណត់អំពីឋានៈនៃច្បាប់ទំនៀមទម្លាប់ក្នុងរង្វង់បញ្ហានេះ *រឿងក្តី Tadić* បានលើកយកមកសិក្សាលម្អិតនូវយុត្តិសាស្ត្រទាក់ទិននឹងរឿងក្តីឧក្រិដ្ឋកម្មសង្គ្រាមចំនួន១០ នៅក្រោយសម័យសង្គ្រាមលោកលើកទី២[១៥៤] និងបានពិចារណាបន្ថែមអំពីបញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញាអន្តរជាតិចំនួន២ ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវទស្សនៈរបស់បណ្តារដ្ឋជាច្រើននៅក្នុងបញ្ហាច្បាប់ (មាត្រា២(៣)(គ) នៃអនុសញ្ញា

---

[១៥២] សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ១៩១ ដែលនិយាយថា "ភាគច្រើន ឧក្រិដ្ឋកម្មទាំងនេះពុំបណ្តាលមកពីទំនោរឧក្រិដ្ឋរបស់បុគ្គលណាម្នាក់ឡើង ប៉ុន្តែគឺជាការបង្ហាញឲ្យឃើញអំពីឧក្រិដ្ឋភាពរួម៖ ឧក្រិដ្ឋកម្មទាំងនេះតែងត្រូវបានអនុវត្តដោយក្រុមមនុស្សដែលប្រព្រឹត្តដើម្បីសម្រេចតាមផែនការឧក្រិដ្ឋរួម"។

[១៥៣] សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ១៩១។

[១៥៤] កថាខណ្ឌ ១៩៧ et seq ។

អន្តរជាតិសម្រាប់បង្ក្រាបទៅលើការបំផ្ទុះគ្រាប់បែករបស់ភេរវជន[១៥៥] មាត្រា២៥ នៃលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ[១៥៦])[១៥៧]។ លើសពីនេះ អង្គជំនុំជម្រះតុលាការកំពូលបាននិយាយយោងទៅដល់ច្បាប់ជាតិ និងយុត្តិសាស្ត្រ ដោយកត់សម្គាល់ថាសញ្ញាណនៃ "គោលបំណងរួម" ដែលត្រូវបានបង្កើតឡើងនៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិមានមូលដ្ឋានគ្រឹះ នៅក្នុងប្រព័ន្ធច្បាប់ជាតិជាច្រើនដែលទទួលស្គាល់ថាពុំទាន់មានការបញ្ជាក់ណាមួយថា ប្រទេសទាំងអស់នោះភាគច្រើនសុទ្ធតែប្រកាន់សញ្ញាណ នៃគោលបំណងរួមដូចៗគ្នាក៏ដោយ[១៥៨]។

### (ii) JCE I និង JCE II ពោលគឺទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធនៃ JCE

៥៧. ពាក់ព័ន្ធនឹងទម្រង់មូលដ្ឋាន និងទម្រង់ប្រព័ន្ធនៃ JCE (JCE I & II) ទោះបីជាដីកាដែលត្រូវបានជំទាស់ ផ្អែកជាសំខាន់លើ *រឿងក្តី Tadić* ទាក់ទិនទៅនឹងបញ្ហា JCE យ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះមិនចាំបាច់កំណត់ថាតើអង្គជំនុំជម្រះតុលាកាកំពូល ICTY បានផ្អែកលើករណីតិចតួចបំផុតនៅក្នុងរឿងក្តីនោះ ដូចដែលដើមបណ្តឹងឧទ្ធរណ៍ម្នាក់បានលើកឡើង ឬយ៉ាងណានោះទេ[១៥៩]។ អង្គបុរេជំនុំជម្រះនឹងមិនកម្រិតការវាយតម្លៃរបស់ខ្លួនត្រឹមការពិនិត្យឡើងវិញអំពីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលអង្គជំនុំជម្រះតុលាការកំពូល ICTY បានផ្អែកទៅលើអំពីថាតើរឿងក្តី *Tadić* បានសម្រេចដោយមិនត្រឹមត្រូវថាការទទួលខុសត្រូវ JCE មានអត្ថិភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ [ក្នុងឆ្នាំ១៩៩២][១៦០] ឬយ៉ាងណានោះទេ។ តាមពិត ដូចដែលបានកត់សម្គាល់យ៉ាងត្រឹមត្រូវ

---

[១៥៥] អនុម័តដោយការបោះឆ្នោតជាឯកច្ឆន្ទ ដោយអង្គមហាសន្និបាតនៅក្នុងសេចក្តីសម្រេចលេខ 52/164 ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ និងដាក់ឱ្យ ចុះហត្ថលេខានៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៩៨។

[១៥៦] អនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដោយ Diplomatic Conference of Plenipotentiaries ប្រារព្ធធ្វើនៅទីក្រុងរ៉ូម។

[១៥៧] សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ២២១-២២២។

[១៥៨] សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ២២៤-២២៥។

[១៥៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៨-៤០ សង្កត់ធ្ងន់ថា អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ផ្អែកទៅលើរឿងក្តីចំនួនប្រាំមួយប៉ុណ្ណោះ ដើម្បីនូវទម្រង់ទីមួយនៃ JCE និងផ្អែកលើរឿងក្តីចំនួនតែពីរទៀតប៉ុណ្ណោះ ដើម្បីកំណត់នូវទម្រង់ទីពីរ និងផ្អែកលើរឿងក្តីចំនួនពីរ ដើម្បីកំណត់នូវទម្រង់ទីបី នៃ JCE។

[១៦០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៣៦-៣៧។

00519444



ដោយអង្គជំនុំជម្រះតុលាការកំពូល ICTR[១៦១] ការគូសបញ្ជាក់នៅក្នុង *រឿងក្តី Tadić* ដែលថាច្បាប់ទំនៀមទម្លាប់អន្តរជាតិបានអនុញ្ញាតឲ្យមានការអនុវត្ត "សញ្ញាណនៃគោលបំណងរួម" ចំពោះបទឧក្រិដ្ឋនានាស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ត្រូវបានគាំទ្រដោយយុត្តិសាស្ត្រដែលបង្កើតឡើងអំពីទ្រឹស្តីនៃគ្រោងការណ៍រួម ឬផែនការរួម នៅក្នុងលិខិតុបករណ៍នៃតុលាការក្រោយសង្គ្រាមលោកលើកទី២ ដូចជា ១) មាត្រា ៦ នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ[១៦២] ("ធម្មនុញ្ញ London ឬធម្មនុញ្ញ Nuremberg") ចែងថា បុគ្គល "ដែលបានចូលរួមក្នុងការបង្កើត ឬការអនុវត្តផែនការរួម ឬការសមគំនិតដើម្បីប្រព្រឹត្ត 'ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ' ត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ដែលប្រព្រឹត្តដោយបុគ្គលណាម្នាក់ដែលបានអនុវត្តផែនការរួមនេះ"[១៦៣] និង ២) ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង ដែលជាច្បាប់របស់អង្គការនីតិបញ្ញត្តិដែលត្រូវបានអនុម័តរួមគ្នា ក្នុងឆ្នាំ១៩៤៥ ដោយមហាអំណាចត្រួតត្រាចំនួនបួន (Occupying Powers) ឆ្លុះបញ្ចាំងនូវកិច្ចព្រមព្រៀងជាអន្តរជាតិក្នុងចំណោមប្រទេសមហាអំណាចស្តីអំពីច្បាប់ដែលអាចអនុវត្តបាន ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងយុត្តាធិការរបស់តុលាការយោធា

---

[១៦១] សេចក្តីសម្រេចអំពី JCE លើរឿងក្តី *Rwamakuba* កថាខណ្ឌ ១៨។

[១៦២] ចេញនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ធម្មនុញ្ញ London របស់តុលាការយោធាអន្តរជាតិ ចែងអំពីច្បាប់ និងនីតិវិធី ដែលត្រូវអនុវត្តដោយតុលាការ Nuremberg ។ តុលាការយោធាអន្តរជាតិ ដែលមានទីតាំងនៅ Nuremberg ត្រូវបានបង្កើតឡើង អនុលោមតាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក រដ្ឋាភិបាលបណ្តោះអាសន្នរបស់សាធារណរដ្ឋបារាំង រដ្ឋាភិបាលចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមសហភាពសូវៀត។ តុលាការយោធាអន្តរជាតិមួយត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះទោសឲ្យបានឆាប់រហ័ស និងប្រកបដោយយុត្តិធម៌ និងដើម្បីផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមដ៏សំខាន់ៗនៃសម្ព័ន្ធមិត្តអឺរ៉ុប។ តុលាការ Nuremberg បានកាត់ទោសសមាជិកដែលនៅរស់រានមានជីវិតដែលមានឋានៈខ្ពស់បំផុតចំនួន **២២**នាក់ របស់របប Nazi។

[១៦៣] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ មាត្រា ៦ នៅក្នុងការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ វ៉ុល១ ទំព័រ ១១ (សេចក្តីបញ្ជាក់បន្ថែម)។ ផ្ទុយទៅនឹងអ្វីដែល ការឆ្លើយតបរបស់ អៀង សារី អះអាង (កថាខណ្ឌ ២២ កំណត់សម្គាល់ ៤៥) ការទទួលខុសត្រូវផែនការរួម អនុវត្តចំពោះបទឧក្រិដ្ឋណាដែលបានបញ្ជាក់ ដែលនៅក្នុងមាត្រា ៦ នៃធម្មនុញ្ញ អនុវត្តមិនត្រឹមតែបទឧក្រិដ្ឋប្រឆាំងសន្តិភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមផងដែរ។



PRE-TRIAL CHAMBER CHAMBRE PRÉ... E.C.C.C * C.E.T.C.

ដែលត្រូវបានយកមកប្រើដើម្បីសម្រេចលើបទឧក្រិដ្ឋទាំងនោះ[១៦៤] ដែលបានចែងថា ទាំងអាទិចារី និងបុគ្គល"ដែលជាប់ពាក់ព័ន្ធនឹងផែនការ ឬគ្រោងការណ៍រួម ដែលទាក់ទិនទៅនឹងការប្រព្រឹត្តិបទឧក្រិដ្ឋមួយ ត្រូវបានចាត់ទុកថា "បានប្រព្រឹត្ត" បទឧក្រិដ្ឋនោះ[១៦៥]។

៥៨. រដ្ឋដែលជាភាគីលិខិតុបករណ៍អន្តរជាតិទាំងនេះ បានទទួលស្គាល់ថា ជនដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋអន្តរជាតិ មិនត្រូវបានកំណត់ត្រឹមតែជនទាំងឡាយណាដែលប្រព្រឹត្តបទឧក្រិដ្ឋនោះដោយផ្ទាល់ឡើយ។ ផ្ទុយទៅវិញ បុគ្គលទាំងឡាយក៏នឹងទទួលខុសត្រូវផងដែរ នៅពេលដែលពួកគេមានចេតនាចូលរួមក្នុងការបង្កើត ឬការអនុវត្តសហកម្ម ឬផែនការរួម ទាក់ទិនទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ នេះបង្កើតបានជាការគាំទ្រដែលមិនអាចបដិសេធបានឡើយដល់ទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធ (JCE I & II) នៃការទទួលខុសត្រូវ JCE។

៥៩. មុនពេលបែរទៅពិនិត្យឡើងវិញនូវយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ដែលបានបង្កើតដោយតុលាការយោធានានា អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បណ្តឹងឧទ្ធរណ៍ទាំងនេះ ដេញដោលលើការពឹងផ្អែកលើយុត្តិសាស្ត្ររបស់*រឿងក្តី Tadić* ដើម្បីស្វែងរកឲ្យឃើញអំពីលក្ខណៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

៦០. អង្គបុរេជំនុំជម្រះពិចារណាថា យុត្តិសាស្ត្រដែលបានមកពីតុលាការយោធាដែលបានបញ្ជាក់ខាងលើផ្តល់នូវការបកស្រាយតាមផ្លូវច្បាប់នៃលិខិតុបករណ៍ជាមូលដ្ឋានរបស់តុលាការទាំងនោះ ហើយ

---

[១៦៤] ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ គ្រប់គ្រងទៅលើការជំនុំជម្រះទោសថ្នាក់បន្ទាប់នៃឧក្រិដ្ឋជនសង្គ្រាមអាល្លឺម៉ង់ នៅចំពោះមុខតុលាការយោធាអូស្ត្រាលី កាណាដា អង់គ្លេស និងសហរដ្ឋអាមេរិក ព្រមទាំងតុលាការអាល្លឺម៉ង់នៅក្នុងប្រទេសអាល្លឺម៉ង់ដែលត្រូវបានគេត្រួតត្រា។ តុលាការយោធាទាំងនេះអនុវត្តតាមធម្មនុញ្ញ និងយុត្តិសាស្ត្ររបស់តុលាការ Nuremberg (ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០, *Official Gazette of the Control Council for Germany* (1946) វ៉ុល៣ ទំព័រ ៥០។

[១៦៥] សូមមើលច្បាប់ក្រុមប្រឹក្សាគ្រង់គ្រងលេខ១០ មាត្រា II(2), in *Official Gazette of the Control Council for Germany* (1946) វ៉ុល ៣ ទំព័រ ៥០ ចែងថា "ជនណាក៏ដោយ ... ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទឧក្រិដ្ឋមួយ ដែលបានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ប្រសិនបើជននោះគឺជា (ក) មេក្លោង ឬ (ខ) ជាអ្នកសមគំនិតក្នុងការប្រព្រឹត្ត បទឧក្រិដ្ឋណាមួយនោះ ឬបានបញ្ជា ឬបានជ្រួមជ្រែងដូចគ្នា ឬ (គ) បានចូលរួមដោយស្ម័គ្រចិត្តនៅក្នុងបទឧក្រិដ្ឋនោះ ឬ (ឃ) ពាក់ព័ន្ធជាមួយនឹងផែនការ ឬសហកម្ម ដែលទាក់ទិនទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនោះ"។

អាចត្រូវបានគេផ្អែកតាម ដើម្បីកំណត់នូវលក្ខណៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទិនទៅនឹងអត្ថិភាពនៃ JCE ជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង០០២។ តាមពិត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុងរឿងក្តី *Kupreškić* បានធ្វើការកត់សម្គាល់ដូចខាងក្រោមនេះ ដែលអង្គបុរេជំនុំជម្រះយល់ឃើញថា គួរឱ្យជឿជាក់ ពាក់ព័ន្ធទៅនឹងការផ្តល់តម្លៃទៅលើសេចក្តីសម្រេចរបស់សាលាក្តី និងតុលាការអន្តរជាតិដ៏ទៃទៀតក្នុងការកំណត់ថា តើការអនុវត្តរបស់រដ្ឋ និងទស្សនច្បាប់ គាំទ្រអត្ថិភាពនៃវិធានដែលបានបញ្ជាក់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬយ៉ាងណា:

> សេចក្តីសម្រេចរបស់តុលាការ អាចបង្ហាញថាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការសម្រេចអំពីច្បាប់ដែលមាន...។ វាមិនអាចត្រូវបានគេបដិសេធឡើយថា តម្លៃដ៏សំខាន់គួរតែត្រូវបានភ្ជាប់ទៅនឹងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងនេះ ដូចជាតុលាការអន្តរជាតិ Nuremberg ឬ Tokyo ឬក៏ភ្ជាប់ទៅនឹងតុលាការជាតិដែលដំណើរការ ដោយសារតែ និងពីព្រោះតែ ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង [...]។ តុលាការទាំងនេះបានដំណើរការក្រោមលិខិតុបករណ៍អន្តរជាតិ ដែលចែងអំពីបទប្បញ្ញត្តិនានា ដែលជាការប្រកាសអំពីច្បាប់ដែលមានស្រាប់ ឬដែលត្រូវបានប្រែក្លាយជាបណ្តើរៗឱ្យទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ[១៦៦]។

៦១. លើសពីនេះទៀត ដូចដែលបានគូសបញ្ជាក់យ៉ាងត្រឹមត្រូវដោយ ក.ស.ព គណៈកម្មាការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ ចាត់ទុកគោលការណ៍នៃការទទួលខុសត្រូវជាបុគ្គល និងការដាក់ទណ្ឌកម្មចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់នៅតុលាការ Nuremberg ថាជា "មូលដ្ឋានច្បាប់អន្តរជាតិ"[១៦៧]។ សេចក្តីសម្រេចដែលបញ្ជាក់អំពីគោលការណ៍ Nurmeberg បានណែនាំគណៈកម្មាការច្បាប់អន្តរជាតិ របស់អង្គការសហប្រជាជាតិឱ្យចងក្រង

---

[១៦៦] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kupreškić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-95-16-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៤០-៥៤១។

[១៦៧] ចម្លើយតបរួមរបស់អយ្យការ កំណត់សម្គាល់ ៥៦ ដែលយោងទៅលើរបាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិ ស្តីពីកិច្ចការនៃកិច្ចប្រជុំលើកទី៤៨ ចុះថ្ងៃទី៦ ខែឧសភា-ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ កំណត់ហេតុផ្លូវការរបស់មហាសន្និបាត កិច្ចប្រជុំលើកទី៥១ លេខបន្ថែម១០ ទំព័រ១៩។



PRE-TRIAL CHAMBER · E.C.C.C · C.E.T.C

00519447



គោលការណ៍ទាំងនេះ នៅក្នុងក្រមអន្តរជាតិនៃបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ។ សេចក្តីព្រាងក្រមដំបូងរបស់គណៈកម្មាការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានរួមបញ្ចូលយ៉ាងច្បាស់នូវ "គោលការណ៍ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល ចំពោះការរៀបចំផែនការ ឬការចូលរួមប្រព្រឹត្តក្នុងផែនការរួម ឬការសមគំនិតដើម្បីប្រព្រឹត្តបទល្មើសមួយ"[១៦៨]។ នៅពេលដែលពិចារណាអំពីប្រភពនៃច្បាប់អន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY អនុវត្តត្រឹមត្រូវនៅពេលដែលអង្គជំនុំជម្រះនេះកត់សម្គាល់ថា សេចក្តីព្រាងក្រមរបស់គណៈកម្មាការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ មិនបានបង្កើតជាការអនុវត្តរបស់រដ្ឋឡើយ ទាក់ទិនទៅនឹងការកំណត់អំពីវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ប៉ុន្តែគ្រាន់តែតំណាងឲ្យវិធីសាស្ត្របន្ទាប់បន្សំប៉ុណ្ណោះ សម្រាប់ការកំណត់អំពីវិធានគតិយុត្តិ។ ទោះបីជាយ៉ាងនេះក្តី "សេចក្តីព្រាងក្រមនេះអាចឆ្លុះបញ្ចាំងអំពីការពិចារណាតាមផ្លូវច្បាប់ ដែលត្រូវបានរួមចំណែកយ៉ាងធំពីសំណាក់សហគមន៍អន្តរជាតិ ហើយសេចក្តីព្រាងក្រមនេះ អាចកំណត់អត្តសញ្ញាណបានយ៉ាងត្រឹមត្រូវនូវវិធាននៃច្បាប់អន្តរជាតិ"[១៦៩]។

៦២. ក្នុងការគាំទ្រទម្រង់មូលដ្ឋាន និងទម្រង់ប្រព័ន្ធ នៃ JCE (JCE I & II) អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានពិនិត្យឡើងវិញនូវរឿងក្តីចំនួនប្រាំបី (រួមទាំងរឿងក្តីជំរំប្រមូលផ្តុំចំនួនពីរ) ដែលបង្ហាញឲ្យឃើញថា ទម្រង់ទាំងពីរនៃការទទួលខុសត្រូវតម្រូវថា ជនជាប់ចោទមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ដែលបង្កើតបានជាផ្នែកនៃផែនការរួម។ រឿងក្តីទាំងនេះ មានដូចខាងក្រោមនេះ ៖

ក) រឿងក្តី *Georg Otto Sandrock* ***និងអ្នកផ្សេងទៀត*** (ត្រូវបានគេស្គាល់ថា ជាការជំនុំជម្រះទោស Almelo) ដែលជាប់ពាក់ព័ន្ធនឹងតុលាការយោធាអង់គ្លេសមួយ ដែល "រកឃើញថា

[១៦៨] ចម្លើយតបរួមរបស់អយ្យការ កំណត់សម្គាល់ ៥៧ ដែលយោងទៅលើរបាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិស្តីពី កិច្ចការនៃកិច្ចប្រជុំលើកទី៤៨ ចុះថ្ងៃទី៦ ខែឧសភា-ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតកិច្ចប្រជុំលើកទី៥១ លេខបន្ថែម១០ ទំព័រ២១។

[១៦៩] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Vasiljević*, IT-98-32-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ ("សាលក្រមលើរឿងក្តី Vasiljevic កថាខណ្ឌ ២០០។")



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ជនជាតិអាល្លឺម៉ង់បីនាក់ ដែលបានសម្លាប់ឈ្លើយសឹកជនជាតិអង់គ្លេសម្នាក់មានពិរុទ្ធភាពក្រោមទ្រឹស្តីនៃ "សហកម្មរួម" [១៧០] ។

ខ) រឿងក្តី *Hoelzer និងអ្នកផ្សេងទៀត* ត្រូវបានជំនុំជម្រះទោសនៅចំពោះមុខតុលាការយោធាកាណាដា ដែលនៅក្នុងសេចក្តីសង្ខេបរបស់គាត់ មេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈ (Judge Advocate) បានមានប្រសាសន៍អំពី "សហកម្មរួម" ទាក់ទិនទៅនឹងការធ្វើឃាតឈ្លើយសឹកជនជាតិកាណាដា ពីសំណាក់ជនជាតិអាល្លឺម៉ង់បីនាក់ ហើយបានសង្កត់ធ្ងន់ថា ជនទាំងបីនាក់នោះបានដឹងថា គោលបំណងក្នុងការយកគាត់ទៅកន្លែងពិសេសមួយនោះ គឺដើម្បីសម្លាប់គាត់[១៧១]។

គ) រឿងក្តី *Jepsen និងអ្នកផ្សេងទៀត* ដែលតុលាការអង់គ្លេសត្រូវតែសម្រេចអំពីការទទួលខុសត្រូវរបស់ Jepsen (ជនជាប់ចោទម្នាក់ក្នុងចំណោមជនជាប់ចោទជាច្រើនទៀត) ចំពោះការស្លាប់អ្នកទោសក្នុងជំរំប្រមូលផ្តុំ ដែលកំពុងផ្លាស់ទៅកាន់ជំរំប្រមូលផ្តុំមួយផ្សេងទៀត[១៧២] ក្នុងរយៈពេលពីរបីសប្តាហ៍ ដែលនាំឱ្យមានការចុះចាញ់របស់អាល្លឺម៉ង់ ក្នុងឆ្នាំ១៩៤៥។ រឿងក្តី *Tadić* បានកត់សម្គាល់ថា:

> រដ្ឋអាជ្ញាបានលើកឡើង (ហើយការលើកឡើងនេះ មិនត្រូវបានបដិសេធពីមេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈឡើយ) ថា "ប្រសិនបើ Jepsen ចូលរួមក្នុងការធ្វើមនុស្ស

---

[១៧០] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ១៩៧ ដោយយោងទៅលើការជំនុំជម្រះ ទោស *Otto Sandrock និងបីនាក់ ផ្សេងទៀត* តុលាការយោធាអង់គ្លេស សម្រាប់កាត់ទោសឧក្រិដ្ឋជនសង្គ្រាម ដែលត្រូវបានធ្វើឡើងនៅអគារតុលាការ ក្នុងទីក្រុង Almelo ប្រទេសហូឡង់ នៅថ្ងៃទី២៤-២៦ ខែវិច្ឆិកា ឆ្នាំ១៩៤៥ UNWCC វ៉ុល I ទំព័រ៣៥)។

[១៧១] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ១៩៧ យោងទៅលើ *Hoelzer និងអ្នកផ្សេងទៀត*។ តុលាការយោធាកាណាដា ទីក្រុង Aurich ប្រទេសអាល្លឺម៉ង់ កំណត់ហេតុសវនាការថ្ងៃទី២៥ ខែមីនា-ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៤៦ វ៉ុល I ទំព័រ 341, 347, 349 (RCAF Binder 181.009 (D2474)។

[១៧២] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ១៩៨ យោងទៅលើការជំនុំជម្រះទោស *Gustav Alfred Jepsen និងអ្នកផ្សេងទៀត* ដំណើរការនីតិវិធី នៃការជំនុំជម្រះទោសឧក្រិដ្ឋកម្មសង្គ្រាម ដែលប្រព្រឹត្តឡើងនៅ *Luneberg ប្រទេសអាល្លឺម៉ង់* (ថ្ងៃទី១៣-២៣ ខែសីហា ឆ្នាំ១៩៤៦) សាលក្រម ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៤៦ (ប្រតិចារិតដើមនៅក្នុងការិយាល័យកំណត់ហេតុសាធារណៈ Kew, Richmond)។



ECCC · CETC PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ឃាតដោយចេតនាទៅលើមនុស្សប្រហែលប៉ែតសិបនាក់ ឬប្រហាក់ប្រហែលនេះ ដោយជួយអ្នកដទៃទៀតក្នុងការរួមចំណែករបស់គាត់ក្នុងការសម្លាប់មនុស្ស សាកសពប្រហែលជាប៉ែតសិបនាក់នោះ អាចត្រូវបានគេដាក់តំរៀបនៅមាត់ទ្វាររបស់គាត់ និងនៅមាត់ទ្វាររបស់ជនគ្រប់រូបដែលបានចូលរួមជួយក្នុងអំពើនោះមិនថាតាមវិធីណាក៏ដោយ”[១៧៣]។

ឃ) រឿងក្តី *Schonfeld* ដូចដែល *Tadić* បានកត់សម្គាល់ មេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈបានបញ្ជាក់ថា “ប្រសិនបើមនុស្សជាច្រើនបានចូលរួមគ្នាក្នុងគោលបំណងខុសច្បាប់មួយ ឬក៏ធ្វើឲ្យគោលបំណងស្របច្បាប់មួយទទួលរងផលប៉ះពាល់ដោយមធ្យោបាយខុសច្បាប់ ហើយបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងនោះ សម្លាប់មនុស្សម្នាក់ក្នុងការអនុវត្តគោលបំណងនោះ វាគឺជាអំពើមនុស្សឃាតចំពោះជនទាំងអស់ដែលមានវត្តមាននៅទីនោះ [...] ប្រសិនបើការស្លាប់នោះបង្កឡើងដោយសមាជិកបក្សម្នាក់ នៅក្នុងការខិតខំប្រឹងប្រែងរបស់គាត់ ដើម្បីធ្វើឲ្យកម្មវត្ថុរបស់ក្រុមនោះបានសម្រេច”[១៧៤]។

ង) រឿងក្តី *Ponzano*[១៧៥] ពាក់ព័ន្ធនឹងការសម្លាប់ឈ្លើយសឹកជនជាតិអង់គ្លេសបួននាក់ ជាការរំលោភទៅលើវិធាននៃការធ្វើសង្គ្រាម។ រឿងក្តី *Tadić* សង្កត់ធ្ងន់ថា រឿងក្តីនេះ ទំនងជាភ្ជាប់សញ្ញាណ នៃគោលបំណងរួមទៅនឹងចំណងនៃហេតុនិងផល ហើយដកស្រង់សំដីរបស់មេធាវីដែលតែងតាំងដើម្បីផលប្រយោជន៍សាធារណៈ ដែលអនុម័តវិធីសាស្ត្រដែលបានស្នើឡើងដោយរដ្ឋអាជ្ញា[១៧៦] ហើយសង្កត់ធ្ងន់ថា ៖

---

[១៧៣] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ១៩៨ យោងទៅលើការជំនុំជម្រះទោស *Gustav Alfred Jepsen និងអ្នកផ្សេង* ទំព័រ ២៤១។

[១៧៤] ការជំនុំជម្រះទោស *Franz Schonfeld និងអ្នកផ្សេងទៀត* តុលាការយោធាអង់គ្លេស Essen ថ្ងៃទី១១-២៦ ខែមិថុនា ឆ្នាំ១៩៤៦, UNWCC, វ៉ុល XI ទំព័រ ៦៨ (សេចក្តីសង្ខេបរបស់មេធាវីដែលតែងតាំងដើម្បីផលប្រយោជន៍សាធារណៈ)។

[១៧៥] ការជំនុំជម្រះទោស *Feurstein និងអ្នកផ្សេងទៀត* ដំណើរការនីតិវិធីនៃការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ដែលប្រព្រឹត្តឡើងនៅ Hamburg ប្រទេសអាល្លឺម៉ង់ (ថ្ងៃទី៤-២៤ ខែសីហា ឆ្នាំ១៩៤៨) សាលក្រមចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៤៨ (ប្រតិចារិតដើមនៅក្នុងការិយាល័យកំណត់ហេតុសាធារណៈ Kew, Richmond)។

[១៧៦] “រដ្ឋអាជ្ញាបានបញ្ជាក់ដូចខាងក្រោម ៖

“វាគឺជាគោលការណ៍បើកចំហនៃច្បាប់ប្រទេសអង់គ្លេស ហើយតាមពិតនៅគ្រប់ច្បាប់ទាំងអស់ ដែលមនុស្សម្នាក់ត្រូវទទួលខុសត្រូវ ចំពោះអំពើរបស់ខ្លួន ហើយមានចេតនាទទួលយកនូវផលវិបាកនៃអំពើរបស់ខ្លួនពីធម្មជាតិ និងធម្មតា



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00519450



> "[...] លក្ខខណ្ឌតម្រូវដែលជនជាប់ចោទម្នាក់ មុនពេលគាត់អាចត្រូវបានគេរកឃើញពិរុទ្ធភាព ត្រូវតែមានជាប់ពាក់ព័ន្ធនឹងបទល្មើស។ ដើម្បីធ្វើឲ្យជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តិបទល្មើសមួយ [...] មិនគ្រាន់តែមានន័យថា ជននោះគឺជាមនុស្សដែលតាមការពិតបានបង្ករបួសស្នាមដល់ស្លាប់ និងបណ្តាលឲ្យស្លាប់ដោយផ្ទាល់ តាមរយៈការបាញ់ប្រហារ ឬតាមរយៈអំពើហិង្សាផ្សេងៗទៀត ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានន័យផងដែរ ថាជាកម្រិតនៃការចូលរួមដោយប្រយោលផងដែរ [...]។ ម្យ៉ាងវិញទៀត ជននោះត្រូវតែជាចំណែកមួយនៃហេតុការណ៍ទាំងឡាយដែលនាំឲ្យមានកើតចេញនូវលទ្ធផលនោះយ៉ាងពិតប្រាកដ។ ជននោះមិនត្រឹមតែអាចចេញបញ្ជាឲ្យមានការប្រព្រឹត្តិបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវមធ្យោបាយដទៃទៀតផង" [...][១៧៧] ។

ច) រឿងក្តី *Einsatzgruppen*[១៧៨] គឺជារឿងក្តីចុងក្រោយដែលត្រូវបានពិនិត្យឡើងវិញដោយរឿងក្តី *Tadić* ក្នុងការគាំទ្រទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម (JCE I) ដែលតុលាការសហរដ្ឋអាមេរិក មានទីតាំងនៅ Nuremberg បានកត់សម្គាល់ថា ៖

---

ហើយប្រសិនបើមនុស្សទាំងនេះ [...] បានរៀបចំគម្រោងធ្វើនូវអំពើដែលមនុស្ស៤នាក់ត្រូវបានគេបាញ់សម្លាប់ដោយគម្រោងនេះ ដូច្នេះពួកគេទាំងអស់គ្នាមានទោសពីបទឧក្រិដ្ឋសម្លាប់មនុស្សទាំងនេះ។ វាមិនសំខាន់ទេសម្រាប់នរណាម្នាក់ដែលបានយកទាហានទាំងនោះចេញទៅ ឬសម្លាប់ពួកគេដោយផ្ទាល់ ឬបានដឹកជញ្ជូនពួកគេដោយផ្ទាល់នោះទេ។ នោះមិនមែនជាការចាំបាច់ទាស់តែសោះ។ ជាការចាំបាច់គឺថា ពួកគេត្រូវទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានរៀបចំគម្រោង ដែលធ្វើឲ្យមនុស្សទាំង៤នាក់ស្លាប់ (ដូចសេចក្តីយោងខាងលើ ទំព័រ ៤)។

[១៧៧] មេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈ បានកត់សម្គាល់បន្ថែមទៀតថា "ក្នុងខណៈដែលការជាប់ពាក់ព័ន្ធរបស់ចុងចោទនៅក្នុងអំពើឧក្រិដ្ឋត្រូវបង្កើតទំនាក់ទំនងនៅក្នុងចំណងនៃហេតុនិងផល វាមិនចាំបាច់ឡើយដែលថាការចូលរួមរបស់គាត់ជាធាតុផ្សំដ៏សំខាន់ *(sine qua non)* នោះ ឬក៏ថា បទល្មើសនឹងមិនបានកើតឡើងឡើយ ប្រសិនបើគ្មានការចូលរួមរបស់គាត់នោះ"។ សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ១៩៩។ សាលដីកាបានសម្រេចទាក់ទិននឹងបញ្ហានេះថា ៖ "[តាមពិត វាអាចមានលទ្ធភាពដែលថា វា [បទល្មើសឧក្រិដ្ឋ] អាចកើតឡើងដោយគ្មានវត្តមានរបស់ជនជាប់ចោទទាំងនេះ ប៉ុន្តែនោះមិនមែនមានន័យដូចដែលរឿងកំពុងនិយាយនោះទេ [...] ថា [ជនជាប់ចោទ] មិនអាចបង្កើតទំនាក់ទំនងនៅក្នុងចំណងនៃហេតុនិងផល [...]"។ សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ១៩៩ កំណត់សម្គាល់ ២៤២ យោងទៅលើ រឿងក្តី *Ponzano* ទំព័រ ៧-៨។

[១៧៨] សហរដ្ឋអាមេរិក ទល់នឹង *Otto Ohlenforf និងអ្នកផ្សេងទៀត ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង,* United States Government Printing Office, Washington, 1951, វ៉ុល IV ("រឿងក្តី*Einsatzgruppen*") ទំព័រ ៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C. C.E.T.C.

"គោលការណ៍សំខាន់ដែលត្រូវចងចាំគឺថា គ្មាននរណាម្នាក់ ទាំងនៅក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង និងទាំងនៅក្រោមប្រព័ន្ធច្បាប់ព្រហ្មទណ្ឌណាមួយ ដែលគេដឹងថា មានត្រូវមានទោសពីបទមនុស្សឃាត ដែលបានកំណត់ចំពោះមនុស្សដែលបានបាញ់ ឬកប់សាកសពទេ។ ស្របគ្នាជាមួយនឹងគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាទូទៅចំពោះ ប្រព័ន្ធច្បាប់ទំនើប មាត្រា២ នៃកថាខណ្ឌ២ នៃច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង បញ្ជាក់យ៉ាងច្បាស់នូវប្រភេទមួយចំនួននៃការជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីកំណត់នូវពិរុទ្ធភាព។ ដូច្នេះ មិនត្រឹមតែអាទិចារីប៉ុណ្ណោះទេ ដែលមានពិរុទ្ធភាព ប៉ុន្តែអ្នកសមគំនិត ជនទាំងឡាយណាដែលទទួលយកភារកិច្ចដោយមានការយល់ព្រម ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ឬពាក់ព័ន្ធទៅនឹងផែនការ ឬសហកម្មដែលទាក់ទិនក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ជនទាំងឡាយណាដែលបានបញ្ជា និងជួយជ្រោមជ្រែងដល់បទឧក្រិដ្ឋ និងជនទាំងឡាយណាដែលជាសមាជិករបស់អង្គការ ឬក្រុមដែលចូលរួមនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ក៏មានពិរុទ្ធភាពផងដែរ។ បទប្បញ្ញត្តិទាំងនេះមិនបានបង្កប់នូវគោលការណ៍មិនល្អ ឬគោលការណ៍ថ្មីៗ នៃការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ [...]"[១៧៩]។

[១៧៩] "តុលាការនោះបានបន្តថ្លែងថា ៖

ទោះបីជាមនុស្សទាំងនេះ [Radetsky, Ruehl, Schubert and Graf] មិនបានស្ថិតក្នុងបញ្ជាក៏ដោយ ក៏ពួកគេមិនអាចគេចពីហេតុការណ៍ពិត ដែលថាពួកគេជាសមាជិកនៃអង្គភាព *Einsatz ដែលបេសកកម្មរបស់អង្គភាពបានដឹងយ៉ាងច្បាស់ទៅដល់សមាជិកទាំងអស់ គឺអនុវត្តផែនការសម្លាប់ដ៏ធំមួយ។* សមាជិកណាដែលជួយជ្រោមជ្រែងឱ្យអង្គភាពទាំងនេះដំណើរការ គឺត្រូវមានទោសពីបទឧក្រិដ្ឋដែលអង្គភាពនេះបានប្រព្រឹត្ត។ ចុងភៅនៅក្នុងនាវាចោរសមុទ្រ មិនអាចគេចផុតពីចុងក្តោង ពីព្រោះគាត់ផ្ទាល់មិនបានកាន់ដាវខ្លីឡើយ។ បុរសនោះដែលឈរនៅច្រកទ្វា ហើយពិនិត្យមើលអាកាសធាតុ ប្រហែលទំនងជាពលរដ្ឋដែលមានសុខសន្តិភាពជាងគេបំផុត ប៉ុន្តែប្រសិនបើបំណងរបស់គាត់ គឺដើម្បីប្រាប់សញ្ញាដល់ចោរប្លន់ទាំងនោះ អំពីការមកដល់របស់ប៉ូលីស នោះគាត់ពិតជាមានកំហុស។ សម្រាប់គោលបំណងនៃអំណះអំណាង ប្រសិនបើយើងសន្មតថា ជនជាប់ចោទដូចជា Schubert និង Graf បានឆ្លើយបញ្ជាក់ថា តួនាទីរបស់ពួកគេគឺជាតួនាទីបន្ទាប់បន្សំ ពួកគេនៅតែមិនមានស្ថានភាពល្អជាងចុងភៅ ឬអ្នកចាំមើលផ្លូវឱ្យពួកចោរប្លន់នោះទេ។

*ដូចសេចក្តីយោងខាងលើ ទំព័រ ៣៧៣ (សេចក្តីបញ្ជាក់បន្ថែម)។.*

ពាក់ព័ន្ធនឹងបញ្ហានេះ តុលាការក៏បានបកស្រាយអំពីសេចក្តីអះអាងដែលថា មេបញ្ជាការមួយចំនួនមិនបានចូលរួមដោយផ្ទាល់នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដោយកត់សម្គាល់ថា ៖

ទាក់ទិនទៅនឹងចុងចោទ ដូចជា Jost និង Naumann [...] ទំនងថា ជនជាប់ចោទទាំងនេះ យ៉ាងហោចណាស់ជារឿយៗ មិនបានចូលរួមដោយផ្ទាល់ក្នុងការសម្លាប់នោះទេ ហើយជាការពិត វាជាការចម្លែក ប្រសិនបើពួកគេដែល

00519452



៦៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ ដូចដែលអង្គជំនុំជម្រះតុលាកាកំពូលលើរឿងក្តី *Tadić* ផងដែរថា ក្នុងការជំនុំជម្រះទោសជាច្រើនក្រោយសង្គ្រាមលោកលើកទី២ ដែលត្រូវបានធ្វើឡើងក្នុងបណ្តាប្រទេសផ្សេងៗទៀត តុលាការបានដាក់ការទទួលខុសត្រូវរបស់ជនជាប់ចោទដែលបានចូលរួមជាមួយអ្នកដទៃទៀត ដោយមានកម្រិតខុសៗគ្នាក្នុងការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ។ "ទោះបីយ៉ាងណាក្តី តុលាការទាំងនោះមិនបានផ្អែកទៅលើសញ្ញាណនៃគោលបំណងរួម ឬផែនការរួមឡើយ ដោយចូលចិត្តសំដៅទៅលើសញ្ញាណនៃការរួមប្រព្រឹត្តទៅវិញ។ ជាពិសេស ការអនុវត្តនេះមានទៅលើរឿងក្តីជនជាតិអ៊ីតាលី[១៨០] និងរឿងក្តីជនជាតិអាល្លឺម៉ង់[១៨១]"[១៨២]។

---

មានអំណាចបានបញ្ជាឲ្យធ្វើដូច្នោះ។ [...] ការដែលមិនអាចការពារបាន ឬស្ថិតនៅក្នុងកាលៈទេសៈមិនអាចបន្ធូរបន្ថយទោសបាន ហេតុការណ៍ពិតដែលថា ចុងចោទទាំងនេះមិនបានបាញ់មនុស្សជាច្រើនដោយផ្ទាល់ ប៉ុន្តែពួកគេបានដឹកនាំប្រតិបត្តិការទូទៅលើតំបន់ *Einsatzgruppen* បង្កើតបានជាការទទួលខុសត្រូវខ្លាំងជាងគេចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងដោយមនុស្សនៅក្រោមបញ្ជារបស់ខ្លួន"។

*ដូចសេចក្តីយោងខាងលើ" ។ សាលដីកាលើរឿងក្តី* Tadić *កថាខណ្ឌ ២00 កំណត់សម្គាល់ ២៤៥។*

[១៨០] សេចក្តីសម្រេចរបស់តុលាការកំពូលអ៊ីតាលី ទាក់ទិនទៅនឹងបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងដោយកងសេនាជន ឬកងកម្លាំងនៃ "សាធារណរដ្ឋសង្គមនិយមអ៊ីតាលី" (*Repubblica Sociale Italiana*) ប្រឆាំងនឹងកងអាសាស្ម័គ្រ ឬកងកម្លាំងប្រដាប់អាវុធអ៊ីតាលី : រឿងក្តី *Annalberti* ***និងអ្នកផ្សេងទៀត*** ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៤៩ នៅក្នុង *Giustizia penale* ភាគ II, col. 732 លេខ ៤៤0។ រឿងក្តី *Rigardo* ***និងអ្នកផ្សេងទៀត ថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៤៩ ដូចឯកសារយោងខាងលើ*** cols. 733 និង 735 លេខ ៤៤៣។ រឿងក្តី *P.M.* ***ទល់នឹង*** *Castoldi* ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៤៩ ដូចឯកសារយោងខាងលើ លេខ ៤៤៤។ រឿងក្តី *Imolesi* ***និងអ្នកផ្សេងទៀត*** ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៤៩ ដូចឯកសារយោងខាងលើ col. 734 លេខ ៤៤៥។ ផងដែរសូមមើលរឿងក្តី *Ballestra* ថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៤៩ ដូចឯកសារយោងខាងលើ cols. 732-733 លេខ ៤៤២។

[១៨១] សេចក្តីសម្រេចចុះថ្ងៃទី១0 ខែសីហា ឆ្នាំ១៩៤៨ របស់តុលាការកំពូលអាល្លឺម៉ង់ សម្រាប់តំបន់អង់គ្លេសក្នុងរឿងក្តី *K.* ***និង*** *A.* នៅក្នុង *Entscheidungen des Obersten Gerichtshofes für die Britische Zone in Strafsachen* វ៉ុល I ទំព័រ ៥៣-៥៦។ សេចក្តីសម្រេចចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៤៩ ក្នុងរឿងក្តី *J.* និង *A.* ដូចសេចក្តីយោងខាងលើ ទំព័រ ៣១0-៣១៥។ សេចក្តីសម្រេចរបស់តុលាការមូលដ្ឋាន (*Landgericht*) នៃ Cologne ចុះថ្ងៃទី២២ និងទី២៣ ខែមករា ឆ្នាំ១៩៤៦ ក្នុងរឿងក្តី *Hessmer* ***និងអ្នកផ្សេងទៀត ក្នុង*** *Justiz und NS-Verbrechen* វ៉ុល I ទំព័រ ១៣-២៣ នៅទំព័រ ១៣, ២0។ សេចក្តីសម្រេចចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៦ របស់តុលាការមូលដ្ឋាន (*Landgericht*) នៃ Frankfurt am Main ក្នុងរឿងក្តី *M.* និងអ្នកផ្សេងទៀត (ដូចសេចក្តីយោង ខាងលើ ទំព័រ ១៣៥-១៦៥, ១៥៤) និងសាលដីការបស់តុលាការឧទ្ធរណ៍ (*Oberlandesgericht*) ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៧ ក្នុងរឿងក្តីដដែលនេះ (ដូចសេចក្តីយោងខាងលើ ទំព័រ ១៦៦-១៨៦, ១៨0)។ ព្រមទាំងសេចក្តីសម្រេចរបស់



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00519453



ក) *រឿងក្តីជំរំប្រមូលផ្តុំ* Dachau[១៨៣] គឺជារឿងក្តីដំបូងក្នុងចំណោមរឿងក្តីទាំងពីរនោះ ដែលត្រូវបានពិនិត្យឡើងវិញដោយរឿងក្តី *Tadić*។ រឿងក្តីនេះត្រូវបានសម្រេចដោយតុលាការសហរដ្ឋអាមេរិកដែលមានទីតាំងក្នុងប្រទេសអាល្លឺម៉ង់។ នៅក្នុងរឿងក្តីនេះ បុគ្គលជាជនជាប់ចោទ បានកាន់តួនាទីដែលមានអំណាចនៅក្នុងឋានានុក្រមនៃជំរំប្រមូលផ្តុំ។ “ជាទូទៅ [ពួកគេត្រូវបានចោទប្រកាន់ចំពោះ]ការបានប្រព្រឹត្ត អនុលោមតាមផែនការរួមដើម្បីសម្លាប់ ឬធ្វើបាបអ្នកទោស ហើយដូច្នេះ ពួកគេប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម”នៅក្នុងជំរំមួយ ដែលអ្នកទោសត្រូវបានទទួលរងនូវដំណើរការនៃការសម្លាប់ និងការធ្វើបាបជាប្រព័ន្ធ (អ្នកទោសភាគច្រើនគឺជាជនជាតិប្រទេសសម្ព័ន្ធមិត្ត)[១៨៤]។ ប្រព័ន្ធនេះត្រូវបានអនុវត្តដោយមានការដឹងពីបុគ្គលជនជាប់ចោទដែលជាបុគ្គលិក និងដោយមានការចូលរួមយ៉ាងសកម្មរបស់ពួកគេ។ ទង្វើបែបនេះដែលសម្រេចដោយតុលាការ បង្កើតជាគោលការណ៍ “ការប្រព្រឹត្តអនុលោមតាមផែនការរួម ដើម្បីរំលោភច្បាប់នានា និងការធ្វើសង្គ្រាម”។ បុគ្គលគ្រប់រូបដែលបានចូលរួមនៅក្នុងផែនការរួមបែបនេះ ត្រូវសម្រេចឲ្យជាប់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ទោះបីជាប្រភេទ និងកម្រិតនៃការចូលរួមអាចខុសគ្នាក៏ដោយ”[១៨៥]។

---

តុលាការមូលដ្ឋាន នៃ Braunschweig ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៤៧ ក្នុងរឿងក្តី *Affeldt* ដូចសេចក្តីយោងខាងលើ ទំព័រ ៣៨៣-៣៩១, ៣៨៩។

[១៨២] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០១ យោងទៅលើរឿងក្តីនានា ដែលបានបញ្ជាក់នៅក្នុងជើងទំព័រចំនួនពីរខាងក្រោមនេះ។

[១៨៣] ការជំនុំជម្រះទោស *Martin Gottfried Weiss និង៣៩នាក់ ផ្សេងទៀត* ដោយ General Military Government Court of the United States Zone ជំរំ Dachau ប្រទេសអាល្លឺម៉ង់ ថ្ងៃទី១៥ ខែវិច្ឆិកា-ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៤៥ UNWCC វ៉ុល XI (“រឿងក្តីជំរំប្រមូលផ្តុំ”) ទំព័រ ៥។

[១៨៤] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០២។

[១៨៥] រឿងក្តីជំរំប្រមូលផ្តុំ *Dachau* ទំព័រ ១៤។

ខ) *រឿងក្តី* Belsen[១៨៦] ត្រូវបានសម្រេចដោយតុលាការយោធាអង់គ្លេសមានទីតាំងក្នុងប្រទេសអាល្លឺម៉ង់។ នៅក្នុងសេចក្តីសង្ខេបរបស់គាត់ក្នុងរឿងក្តី *Belsen* មេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈបានអនុម័ត"លក្ខខណ្ឌតម្រូវបី ដែលអយ្យការបានចាត់ទុកថាជាការចាំបាច់ដើម្បីកំណត់នូវពិរុទ្ធភាពនៅក្នុងរឿងក្តីនីមួយៗ :

(i) អត្ថិភាពនៃប្រព័ន្ធដែលត្រូវបានរៀបចំដើម្បីធ្វើបាបអ្នកជាប់ឃុំឃាំង និងប្រព្រឹត្តឧក្រិដ្ឋ កម្មនានាដែលត្រូវបានចោទប្រកាន់។

(ii) ការដឹងរបស់ជនជាប់ចោទអំពីលក្ខណៈនៃប្រព័ន្ធ និង

(iii) ការពិតដែលថា ជនជាប់ចោទបានចូលរួមយ៉ាងសកម្ម តាមវិធីណាក៏ដោយក្នុងការអនុវត្តប្រព័ន្ធនោះ ឧទាហរណ៍ បានលើកទឹកចិត្ត បានជួយនិងបានជំរុញ ឬគ្រប់កាលៈទេសៈទាំងអស់បានចូលរួមក្នុងការដឹងឮអំពីផែនការឧក្រិដ្ឋរួម[១៨៧]។

រឿងក្តី *Tadić* សង្កត់ធ្ងន់ថា ការផ្តន្ទាទោសជនជាប់ចោទជាច្រើន "ទំនងជា" បានផ្អែកយ៉ាងពិតប្រាកដទៅលើលក្ខណៈវិនិច្ឆ័យទាំងនេះ។ ជាពិសេស នេះគឺជាករណីដែលពាក់ព័ន្ធនឹងជនជាប់ចោទ Kramer ដែល "មេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈ បានរំលឹកដល់តុលាការថា នៅពេលដែលពួកគាត់បានពិចារណាអំពីបញ្ហាពិរុទ្ធភាព និងការទទួលខុសត្រូវ ករណីដ៏ខ្លាំងបំផុតត្រូវតែធ្វើឡើងប្រឆាំងនឹងរូបគាត់ ដោយសារតែឋានៈជាន់ខ្ពស់របស់គាត់ ហើយបន្ទាប់មកចុះតាមលំដាប់ជាបន្តបន្ទាប់តាមតួនាទីដែលជនជាប់

---

[១៨៦] ការជំនុំជម្រះទោស *Josef Kramer និង ៤៤នាក់ ផ្សេងទៀត* តុលាការយោធាអង់គ្លេស ទីក្រុង Luneberg ចុះថ្ងៃទី១៧ ខែកញ្ញា-ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤៥, UNWCC, វ៉ុល II ("រឿងក្តី *Belsen* Case") ទំព័រ ១។

[១៨៧] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០២។ "មេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈសង្ខេប ដោយយល់ស្របទៅនឹង អំណះអំណាងរបស់រដ្ឋអាជ្ញា ដូចខាងក្រោមនេះ :

ចំពោះអយ្យការ ប្រសិនបើជនជាប់ចោទជាបុគ្គលិកនៅជំរំ Auschwitz បានដឹងថា ប្រព័ន្ធ និងអង្គើកំពុងអនុវត្តនោះ ហើយថា ក្នុងវិធីតែមួយ ឬផ្សេងគ្នាក្នុងការគាំទ្រលើកិច្ចព្រមព្រៀងរួម ដើម្បីគ្រប់គ្រងជំរំតាមរបៀបព្រៃផ្សៃ ជនទាំងអស់នោះមានឈ្មោះថា កំពុងតែចូលរួមក្នុងទង្វើរួមនោះ។ ពួកគេបានសុំតុលាការកុំឱ្យចាត់ទុកជាអំពើបុគ្គល ដោយពួកគេផ្តល់អំណះអំណាងថា អំពើរបស់ពួកគេគឺធ្វើដោយស្ម័គ្រចិត្តជាក្រុមមួយ ដើម្បីជួយឱ្យប្រព័ន្ធនោះដើរទៅមុខ។ ពួកគេបានស្នើថា ប្រសិនបើតុលាការសម្រេចថា ពួកគេកំពុងធ្វើដូច្នេះ ពួកគេម្នាក់ៗ និងគ្រប់ៗគ្នា ត្រូវតែទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើង"

សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០២ កំណត់សម្គាល់ ២៥១ យោងទៅលើរឿងក្តី *Belsen* Case ទំព័រ ១២១។

ចោទបានកាន់”[១៨៨]។ ជនជាប់ចោទ នៅពេលដែលពួកគេត្រូវបានរកឃើញពិរុទ្ធភាព ត្រូវបានចាត់ទុកថាជាសហចារីនៃឧក្រិដ្ឋកម្មធ្វើបាប ដោយសារតែ “តួនាទីដែលមានអំណាច” សត្យានុម័តរបស់ពួកគេនៅក្នុងប្រព័ន្ធជំរំប្រមូលផ្តុំ និងដោយសារតែពួកគេមាន “អំណាចមើលថែរក្សាអ្នកទោស និងបំពេញនូវតម្រូវការរបស់អ្នកទោស”[១៨៩] ប៉ុន្តែពួកគេខកខានមិនបានបំពេញតួនាទីនេះ[១៩០]។

---

[១៨៨] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០២ កំណត់សម្គាល់ ២៥២ យោងទៅលើរឿងក្តី *Belsen* Case ទំព័រ ១២១។

[១៨៩] រឿងក្តី Belsen ទំព័រ ១២១។

[១៩០] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០៣។ *Tadić* ក៏បានយោងទៅលើរឿងក្តីមួយទៀតផងដែរ (កថាខណ្ឌ ២០៣ កំណត់សម្គាល់ ២៥៤) ស្រដៀងគ្នានេះដែរ : រឿងក្តីប្រឆាំងនឹង *R .Mulka និងអ្នកផ្សេងទៀត* (“រឿងក្តីជំរំប្រមូលផ្តុំ *Auschwitz*”):

> ទោះបីជាតុលាការបានសម្រេចលទ្ធផលដូចគ្នាក៏ដោយ តុលាការមិនបានអនុវត្តនូវគោលការណ៍នៃគម្រោងរួមគ្នានោះដែរ ប៉ុន្តែផ្ទុយទៅវិញ តុលាការបានចាត់ទុកជនជាប់ចោទថាជាអ្នកជួយទំនុកបម្រុង និងអ្នកជួយជំរុញ ដរាបណាពួកគេស្ថិតនៅក្នុងក្របខណ្ឌការងារតាមការបញ្ជា ហើយចាត់ទុកជាអាទិចារី ប្រសិនបើពួកគេប្រព្រឹត្តបទល្មើសក្រៅក្របខណ្ឌការងារនេះ។ នេះមានន័យថា ប្រសិនបើគេមិនអាចបង្ហាញភស្តុតាងថា ជនជាប់ចោទពិតជាធ្វើតាមគោលបំណងរបស់របប Nazi នោះទេ អញ្ចឹងតុលាការនឹងចាត់ទុកជនជាប់ចោទ ថាជាអ្នកជួយទំនុកបម្រុង និងអ្នកជួយជំរុញ ពីព្រោះគេគ្មានចេតនាពិតប្រាកដ “ក្នុងការប្រព្រឹត្តបទល្មើស ដោយខ្លួនឯង”។

“ជាពិសេស សូមមើល រឿងក្តី *Bundesgerichtshof* ក្នុងជំរំ *Justiz und NS-Verbrechen ភាគ* XXI ទំព័រ ៨៣៨ *ff.*,និងជាពិសេស ទំព័រ ៨៨១ *ff*)។ BGH បានថ្លែង នៅទំព័រ ៨៨២ ថា :

> [ទស្សនៈ] ដែលថា នរណាក៏ដោយដែលពាក់ព័ន្ធនៅក្នុងកម្មវិធីបំផ្លិចបំផ្លាញរបស់ជំរំ [KZ] Auschwitz និងដែលបានប្រព្រឹត្តតាមលក្ខណៈណាក៏ដោយដែលជាប់ទាក់ទងនឹងនេះ បានចូលរួមក្នុងការឃាតកម្ម ហើយទទួលខុសត្រូវចំពោះអ្វីទាំងអស់ដែលកើតមានឡើង គឺជាការមិនត្រឹមត្រូវនោះទេ។ វាមានន័យថា ទោះជាអំពើនោះមិនបានគាំទ្រនូវបទល្មើសចំបងនៅក្នុងលក្ខណៈពិតប្រាកដណាមួយក៏ដោយ ក៏អំពើនោះនឹងអាចត្រូវបានផ្តន្ទាទោសបានដែរ។ ជាលទ្ធផល ទោះជាគ្រូពេទ្យដែលទទួលខុសត្រូវថែទាំបុគ្គលិកយាម និងដែលកម្រិតខ្លួនឯងធ្វើតែអំពើដូចនេះក៏ដោយ ក៏ត្រូវមានទោសក្នុងការជួយ និងជំរុញឲ្យមានសម្លាប់មនុស្សដែរ។ គោលការណ៍ដដែលនេះ នឹងអនុវត្តចំពោះគ្រូពេទ្យដែលព្យាបាលអ្នកទោសក្នុងជំរំ និងជួយសង្គ្រោះជីវិតពួកគេ។ សូម្បីតែអ្នកទាំងឡាយដែលបានរារាំងតិចតួចនៅក្នុងកន្លែងរបស់ពួកគេក្នុងកម្មវិធីសម្លាប់មនុស្ស ដែលជនទាំងនោះស្ថិតក្នុងតំណែងថ្នាក់ក្រោម ហើយមិនអាចសម្រេចការងារអ្វីបាននោះ នឹងមិនអាចគេចផុតពីទោសទណ្ឌបានឡើយ។ ទស្សនៈបែបនេះ មិនមែនជាការត្រឹមត្រូវនោះទេ។

(បកប្រែក្រៅផ្លូវការ)។” សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០៣ កំណត់សម្គាល់ ២៥៤។

៦៤. *រឿងក្តី Tadić* បានកត់សំគាល់ថា វាហាក់បីដូចជាថា ចេតនាចាំបាច់ នៅក្នុងរឿងក្តីទាំងពីរនេះ អាចត្រូវបានទាញសេចក្តីសន្និដ្ឋាន ចេញពីតួនាទីដែលមានអំណាចដែលបុគ្គលិករបស់ជំរំនោះបានកាន់។ តាមពិត វាស្ទើរតែមិនចាំបាច់ឡើយក្នុងការបង្ហាញអំពីចេតនា ដែលអំណាច ឬតួនាទីខ្ពស់របស់បុគ្គល បានចង្អុលបង្ហាញនូវការដឹងអំពីផែនការរួម និងចេតនាចូលរួមក្នុងផែនការរួមនោះ។ ជនជាប់ចោទទាំងអស់នោះ ត្រូវបានរកឃើញថាមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាមនៃការធ្វើបាបអ្នកទោស ទោះបីជាជនទាំងនេះទទួលទោសខុសគ្នា យោងទៅតាមកម្រិតនៃការចូលរួមយ៉ាងណាក៏ដោយ។

៦៥. ជាការត្រឹមត្រូវដែល ក.ស.ព បញ្ជាក់ថា មានរឿងក្តីនៅតុលាការយោធាអន្តរជាតិក្រោយសង្គ្រាមលោកលើទី២ ដែលពាក់ព័ន្ធច្រើនជាងរឿងក្តីដែលត្រូវបានដកស្រង់ពី*រឿងក្តី Tadić*[១៥១]។ អង្គបុរេជំនុំជម្រះយល់ថា រឿងក្តីពីរក្នុងចំណោមរឿងក្តី នៃច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង រឿងក្តី *Justice* និង *RuSHA* ពាក់ព័ន្ធជាពិសេសក្នុងការសម្រេចថាតើទម្រង់មូលដ្ឋាន និងទម្រង់ប្រព័ន្ធនៃ

---

[១៥១] សូមមើលចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០ កំណត់សម្គាល់ ៧២ យោងទៅលើសេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ ៤៧ ដោយបានរៀបរាប់ និងផ្តល់នូវសេចក្តីយោងរឿងក្តីចំនួន ១៦ បន្ថែមទៀតដែលត្រូវបានបោះពុម្ពផ្សាយក្នុងរបាយការណ៍គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៤៩ និងរបាយការណ៍របស់តុលាការសហរដ្ឋអាមេរិកសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមនៅ Nuremberg ។ ក.ស.ព ក៏បានយោងផងដែរទៅលើរឿងក្តីចំនួន ១០ មកពីតុលាការអាល្លឺម៉ង់ ដែលមាននៅ អ.វ.ត.ក។ យោងតាម ក.ស.ព បានឲ្យដឹងថា នៅក្នុងរឿងក្តីទាំងអស់នេះតុលាការបានអនុវត្តទស្សនទានផែនការរួម/JCE ហើយនៅក្នុង "សេចក្តីសង្ខេបយុត្តិសាស្ត្រដ៏ទូលំទូលាយនេះ និងការពន្យល់អំពីភាពខុសគ្នារវាងគ្រោងការណ៍រួម និងការរួមប្រព្រឹត្តធម្មតា របាយការណ៍គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ បញ្ជាក់ថា ៖

> ការចោទប្រកាន់ត្រូវមានការបង្ហាញឲ្យឃើញបន្ថែមអំពីអត្ថិភាពនៃផែនការរួម និងនៅពេលដែលអត្ថិភាព ត្រូវបានបង្ហាញការចោទប្រកាន់ត្រូវផ្អែកលើវិធាន ដែលមាននៅក្នុងប្រព័ន្ធជាច្រើននៃច្បាប់ ដែលជនទាំងឡាយណាដែលចូលរួមក្នុងផែនការរួមដើម្បីប្រព្រឹត្តបទល្មើសដែលប្រព្រឹត្តដោយជនម្នាក់ក្នុងចំណោមជនទាំងនោះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបទល្មើសនោះ ដោយអនុលោមតាមច្បាប់ព្រហ្មទណ្ឌ។

ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០។ ក.ស.ព ក៏បានយោងផងដែរទៅលើបណ្តឹងឧទ្ធរណ៍ស្តីពី JCE លើរឿងក្តី *Ojdanić* ដែលបានសម្រេចថា JCE និងការទទួលខុសត្រូវផែនការរួម គឺដូចគ្នា។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០ យោងទៅលើសាលដីកាស្តីពី JCE លើរឿងក្តី *Ojdanić* កថាខណ្ឌ ៣៦។



PRE-TRIAL CHAMBER · CHAMBRE PRÉLIMINAIRE · E.C.C.C · C.E.T.C

JCE (JCE I & II) បានបង្កើតជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬយ៉ាងណា នៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង០០២។ រឿងក្ដីទាំងនេះ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូល ICTR ធ្វើការពិភាក្សាយ៉ាងទូលំទូលាយ ដែលក្នុងចំណោមប្រការផ្សេងទៀត បានផ្អែកលើប្រភពទាំងនេះ ដើម្បីធ្វើការសន្និដ្ឋានថា ត្រឹមឆ្នាំ១៩៩២ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានអនុញ្ញាតឱ្យមានការដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ ទៅលើអ្នកចូលរួមក្នុងផែនការរួមក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍[១៥២]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូល ICTY ក្នុងចំណោមប្រការផ្សេងទៀត បានផ្អែកលើប្រភពដូចគ្នាដើម្បីធ្វើការសន្និដ្ឋានថា យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ បានទទួលស្គាល់ការដាក់ការទទួលខុសត្រូវទៅលើជនជាប់ចោទ ចំពោះការចូលរួមរបស់គាត់ក្នុងគោលបំណងឧក្រិដ្ឋរួមមួយ ដែលការប្រព្រឹត្តិដោយមានអំពើឧក្រិដ្ឋ *(actus reus)* ត្រូវបានប្រព្រឹត្តឡើងដោយជនទាំងឡាយដែលមិនមានគោលបំណងរួម[១៥៣]។ សាលដីកាលើរឿងក្ដី *Justice* និង *RuSHA* មិនបានប្រើពាក្យជាក់លាក់នៃ "សហឧក្រិដ្ឋកម្មរួម" ឡើយ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះយល់ឃើញថា ធាតុផ្សំផ្លូវច្បាប់ដែលតុលាការយោធាបានអនុវត្ត ដើម្បីកំណត់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទនោះ គឺស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងធាតុផ្សំនៃ JCE (ដូចបានពិណ៌នាខាងលើ) និង

---

[១៥២] សូមមើលសេចក្ដីសម្រេចលើ JCE ក្នុងរឿងក្ដី *Rwamakuba* កថាខណ្ឌ ១៤-៣១។ ក្នុងចំណោមប្រការផ្សេងទៀត សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ICTR ដកស្រង់ :

> សាលក្រម *Justice* ទំព័រ ១០៨៣ ("បានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្ត" បទល្មើស), ទំព័រ ១០៨៤ ("ជាប់ពាក់ព័ន្ធខ្លះ" ទៅនឹងការធ្វើទុកបុកម្នេញ) ទំព័រ១១២០ (សន្និដ្ឋានថា ភស្តុតាងបានកំណត់អំពីការជាប់ពាក់ព័ន្ធរបស់ចុងចោទ" ទៅនឹងនីតិវិធីផ្ទុយនឹងច្បាប់) ទំព័រ ១១២៨ (បញ្ជាក់ថា ជនជាប់ចោទ Lautz "មានជាប់ពាក់ព័ន្ធឧក្រិដ្ឋ" នៅក្នុងការដាក់ឱ្យប្រតិបត្តិនូវច្បាប់ប្រឆាំងនឹងជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វ)។ សាលក្រមលើរឿងក្ដី *RuSHA* ទំព័រ ១០៨ (បញ្ជាក់ថា ជនជាប់ចោទពីរនាក់ "ត្រូវបានជាប់ពិរុទ្ធក្នុងបទឧក្រិដ្ឋ ដែលជាប់ពាក់ព័ន្ធជាមួយនឹងការចាប់ពង្រត់កុមារបរទេស")។

ដូចសេចក្ដីយោងខាងលើ កថាខណ្ឌ ២៤ កំណត់សម្គាល់ ៥៦។

[១៥៣] នៅក្នុងសេចក្ដីវិភាគរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលយោងយ៉ាងច្រើនទៅលើការវិភាគនៃរឿងក្ដីទាំងនេះ ដែលបានធ្វើឡើងតាមរយៈយោបល់ដាច់ដោយឡែករបស់ចៅក្រម Bonomy នៅក្នុងរឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Milutinović* និង អ្នកផ្សេងទៀត ដែលអង្គជំនុំជម្រះនេះយល់ឃើញថាមានសារៈប្រយោជន៍។ យោបល់ដាច់ឡែករបស់ចៅក្រម Iain Bonomy, សេចក្ដីសម្រេចលើការរួមប្រព្រឹត្តក្នុងរឿងក្ដី *Ojdanić* ("យោបល់របស់ Bonomy សេចក្ដីសម្រេចលើការរួមប្រព្រឹត្តក្នុងរឿងក្ដី *Ojdanić*") ជាពិសេស កថាខណ្ឌ ១៨-២២។



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

00519458



បង្កើតបានជាការចង្អុលបង្ហាញ ដែលមានសុពលភាពអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទិនទៅនឹងទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធនៃ JCE (JCE I & II)។

៦៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងរឿងក្តី *Justice* ការផ្តន្ទាទោសរបស់តុលាការយោធា ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈរឿង Lautz ដោយអគ្គរដ្ឋអាជ្ញានៃតុលាការប្រជាជន និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈរឿង Rothaug ដោយអតីតប្រធានតុលាការពិសេសនៅ Nuremberg ចំពោះការចូលរួមរបស់ពួកគេនីមួយៗ នៅក្នុង "ផែនការ [ធ្វើទុក្ខបុកម្នេញ] ខាងពូជសាសន៍" ដើម្បីអនុវត្តច្បាប់ព្រហ្មទណ្ឌប្រឆាំងនឹងជនជាតិជ្វីហ្វ និងជនជាតិប៉ូឡូញ ដែលពួកគេបានដឹងឮនោះ[១៥៤] បានរក្សាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលស្រដៀងគ្នាទៅនឹង JCE។ យ៉ាងណាក៏ដោយ វាគឺយ៉ាងដូច្នេះ ដូចដែលយុត្តិសាស្ត្ររបស់តុលាការ ICTR បានគូសបញ្ជាក់យ៉ាងត្រឹមត្រូវ ក្នុងរឿងក្តី *Rwamakuba*:

> សម្ភារៈក្រោយសង្គ្រាមលោកលើកទី២ មិនតែងតែត្រូវតតម្រូវនឹងអ្វីដែលគេហៅថា "ទម្រង់ទាំងបី" នៃសហឧក្រិដ្ឋកម្មរួមនោះ ដែលត្រូវបានពិភាក្សានៅក្នុងរឿងក្តី *Tadić* ពីព្រោះ ផ្នែកខ្លះនៃសាលក្រមរបស់តុលាការ មិនតែងតែពិចារណាទៅលើទស្សនទានច្បាប់ នៃការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប៉ុន្តែគ្រាន់តែបានសន្និដ្ឋានថា ជនជាប់ចោទ "មានជាប់ទាក់ទិនជាមួយ" "ពាក់ព័ន្ធនៅក្នុង" "ជាប់ពិរុទ្ធក្នុង" ឬ "ជាប់ពាក់ព័ន្ធនៅក្នុង" ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៥៥]។

៦៧. ការចូលរួមរបស់ Lautz នៅក្នុងផែនការរួម បានជួយដល់ការចោទប្រកាន់ទៅលើជនជាតិប៉ូឡូញមួយចំនួនអំពីបទក្បត់ជាតិចំពោះ "ការចាកចេញពីកន្លែងធ្វើការរបស់ពួកគេ និងព្យាយាមរត់គេចខ្លួន

---

[១៥៤] កំណត់សម្គាល់ ៣៦ និង ៣៧ ឯកសារដើម។ សាលក្រម *Justice* ទំព័រ 1081, 1118-1128 ក្នុងរឿងក្តី Lautz។ និងកំណត់សម្គាល់ ៤២ ច្បាប់ដើម ដូចសេចក្តីយោងខាងលើ ទំព័រ1155-1156] ក្នុងរឿងក្តី Rothaug។

[១៥៥] សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Rwamakuba* កថាខណ្ឌ ២៤ ដកស្រង់ ក្នុងចំណោមប្រការផ្សេងទៀត:
សាលក្រម *Justice* ទំព័រ ១០៩៣ ("បានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្ត" បទល្មើស), ទំព័រ ១០៩៤ ("ជាប់ពាក់ព័ន្ធខ្លះ" ទៅនឹងការធ្វើទុកបុកម្នេញ) ទំព័រ១១២០ (សន្និដ្ឋានថា ភស្តុតាងបានកំណត់អំពីការជាប់ពាក់ព័ន្ធរបស់ចុងចោទ" ទៅនឹងនីតិវិធីផ្ទុយនឹងច្បាប់) ទំព័រ ១១២៨ (បញ្ជាក់ថា ជនជាប់ចោទ Lautz "មានជាប់ពាក់ព័ន្ធឧក្រិដ្ឋ" នៅក្នុងការដាក់ឱ្យប្រតិបត្តិនូវច្បាប់ប្រឆាំងនឹងជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វ)។ សាលក្រមលើរឿងក្តី *RuSHA* ទំព័រ ១០៨ (បញ្ជាក់ថា ជនជាប់ចោទពីរនាក់"ត្រូវបានជាប់ពិរុទ្ធក្នុងបទឧក្រិដ្ឋដែលជាប់ពាក់ព័ន្ធជាមួយនឹងការចាប់ពង្រត់កុមារបរទេស")។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ខ្លួន ពីប្រទេសអាល្លឺម៉ង់ដោយឆ្លងកាត់ព្រំដែនចូលទៅប្រទេសស្វីស” ដែលចុងក្រោយជនជាតិប៉ូឡូញមួយចំនួននោះត្រូវបានកាត់ទោសប្រហារជីវិត និងត្រូវបានប្រហារជីវិត[១៩៦]។ តុលាការយោធាបានរកឃើញថា ជនជាប់ចោទបានចូលរួមដោយមានចេតនា នៅក្នុងផែនការជាតិរើសអើងពូជសាសន៍ “តាមមធ្យោបាយនៃការអនុវត្តមិនត្រឹមត្រូវនៃច្បាប់ក្បត់ជាតិ”[១៩៧]។ គាត់បានអនុវត្តច្បាប់ប្រឆាំងនឹងជនជាតិជ្វីហ្វ និងជនជាតិប៉ូឡូញ ដែលត្រូវបានចាត់ទុកថាជាផ្នែកមួយនៃផែនការរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដើម្បីបំបាត់ចោលនូវពូជសាសន៍ទាំងនោះ។ គាត់គឺអ្នកសមគំនិត និងបានចូលរួមដោយស្ម័គ្រចិត្តនៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[១៩៨]។ ការចូលរួមរបស់ Rothaug ក្នុងផែនការរួម ដែលរួមមានការផ្ដន្ទាទោស និងការកាត់ទោសប្រហារជីវិតលើជនជាតិប៉ូឡូញចំនួនបីនាក់ និងបុរសជនជាតិជ្វីហ្វម្នាក់ អនុលោមទៅតាមកម្មវិធីជាតិនៃការធ្វើទុក្ខបុកម្នេញខាងពូជសាសន៍របស់រដ្ឋ Nazi[១៩៩]។ តុលាការរកឃើញថា គាត់បានចូលរួមដោយមានចេតនា នៅក្នុងផែនការនោះ ដែលខ្លួនគាត់បានគាំទ្រផែនការជាតិនេះ និងបានលះបង់ខ្លួនគាត់ ដើម្បីឱ្យផែនការនេះទទួលបានជោគជ័យ ដូច្នេះ គឺជាការចូលរួមក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[២០០]។

៦៨. អង្គបុរេជំនុំជម្រះយល់ឃើញផងដែរថា តុលាការយោធាសហរដ្ឋអាមេរិក បានអនុវត្តទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ស្រដៀងគ្នាទៅនឹង JCE ដោយមិនបានប្រើប្រាស់ពាក្យ JCE នេះឡើយ នៅពេលដែលធ្វើការសម្រេចទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ Hofmann និង Hildebrandt ដែលជាមន្ត្រីនៃការិយាល័យកណ្ដាលទទួលបន្ទុកការតាំងទីលំនៅ និងពូជសាសន៍ SS (SS Race and Resettlement Main Office) ដែលគេស្គាល់ថាជា “RuSHA” (អក្សរកាត់ជាភាសាអាល្លឺម៉ង់)។ Hofmann និង Hildebrandt ត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើមនុស្សឃាត ការសម្លាប់

---

[១៩៦] កំណត់សម្គាល់ ៣៨ ក្នុងឯកសារដើម រឿងក្តី Justice ទំព័រ ១១២០-១១២១។

[១៩៧] កំណត់សម្គាល់ ៣៩ ក្នុងឯកសារដើម ដូចឯកសារយោងខាងលើ ទំព័រ ១១២៣។

[១៩៨] កំណត់សម្គាល់ ៤១ ក្នុងឯកសារដើម ដូចឯកសារយោងមុន ទំព័រ ១១២៨។

[១៩៩] កំណត់សម្គាល់ ៤៣ ក្នុងឯកសារដើម ដូចឯកសារយោងខាងលើ ទំព័រ ១១៥៥។

[២០០] កំណត់សម្គាល់ ៤៤ ក្នុងឯកសារដើម ដូចឯកសារយោងខាងលើ ទំព័រ ១១៥៦។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

បំផុតពូជ ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការយកទៅដាក់គុក ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ ចំពោះការចូលរួមរបស់ពួកគេក្នុងការអនុវត្តផែនការរួម ដែលត្រូវបានគេស្គាល់ថា ជាផែនការ "អាល្លឺម៉ង់តូបនីយកម្ម" (Germernization)។ តុលាការយោធាបានរកឃើញថា មានអត្ថិភាពក្នុងចំណោម Hitler, Himmler (មេដឹកនាំ SS) និងមន្ត្រី Nazi ផ្សេងៗទៀត នូវគោលបំណងពីរយ៉ាងក្នុងការធ្វើឱ្យចុះខ្សោយ និងចុងក្រោយកម្ទេចបណ្ដាប្រទេសដទៃទៀត ដោយទន្ទឹមពេលគ្នានោះដែរ ពង្រីងប្រទេសអាល្លឺម៉ង់ផងដែរ ផ្នែកទឹកដី និងជីវសាស្ត្រ ដែលធ្វើឱ្យខូចខាតដល់បណ្ដាប្រទេស ដែលត្រូវស្ថិតនៅក្រោមការត្រួតត្រានោះ"[២០១]។ តុលាការនេះក៏បានរកឃើញផងដែរថា Hofmann និង Hildebrandt បានប្រកាន់ខ្ជាប់ និងបានចូលរួមក្នុងការអនុវត្តផែនការ "អាល្លឺម៉ង់តូបនីយកម្ម" ដោយក្ដីពេញចិត្តយ៉ាងខ្លាំង ដោយអនុវត្តនូវការរំលូតកូន តាមរយៈភ្នាក់ងារ RuSHA ទៅលើជនបរទេស ដែលមានផ្ទៃពោះ ដោយសារពួកជនជាតិអាល្លឺម៉ង់ ការដាក់ទណ្ឌកម្មចំពោះការរួមភេទរវាងជនជាតិអាល្លឺម៉ង់ និងអ្នកដែលមិនមែនជនជាតិអាល្លឺម៉ង់ ការធ្វើការធ្ងន់ដូចទាសកររបស់ជនប៉ូឡូញ និងជនជាតិប៉ែកខាងកើតដទៃទៀត ការធ្វើទុក្ខបុកម្នេញជនជាតិជ្វីហ្វ និងជនជាតិប៉ូឡូញ និងការចាប់ពង្រត់កុមារបរទេស[២០២]។ តុលាការនេះបានរកឃើញទៀតថា Hofmann និង Hildebrandt បានបង្កើតកម្មវិធីចាប់ពង្រត់ដើម្បីឆ្លើយតបទៅនឹងក្រឹត្យ និងអនុស្សរណៈ ដែលចេញដោយ Himmler។ យោងតាមកម្មវិធីនេះ អ្នកត្រួតពិនិត្យខាងពូជសាសន៍របស់ RuSHA បានកំណត់កុមារជនជាតិប៉ូឡូញណាដែលមានលក្ខណៈសម្បត្តិផ្នែកពូជសាសន៍ល្អគ្រប់គ្រាន់ដើម្បី "ប្រែក្លាយឱ្យទៅជាជនជាតិអាល្លឺម៉ង់"។ កុមារទាំងនេះ ត្រូវបានគេបំបែកចេញពីក្រុមគ្រួសាររបស់ពួកគេ ហើយត្រូវបានបញ្ជូនទៅប្រទេសអាល្លឺម៉ង់ ដោយដាក់ពួកគេនៅក្នុង

[២០១] កំណត់សម្គាល់ ៤៦ ក្នុងឯកសារដើម សូមមើលឯកសារយោងខាងលើ ទំព័រ 90។ ផងដែរសូមមើលឯកសារយោងខាងលើ ទំព័រ ៨៦ (រកឃើញថា "នៅដំណាក់កាលដំបូងនៃកម្មវិធីអាល្លឺម៉ង់តូបនីយកម្ម បានប្រមើលឃើញជាមុននូវវិធានការគៀបសង្កត់ និងតឹងរ៉ឹងមួយចំនួន ក្នុងចំណោមពួកគេ [...] ការបំបែកក្រុមគ្រួសារ និងការចាប់ពង្រត់កុមារក្នុងគោលបំណងបណ្ដុះបណ្ដាលពួកគេនៅក្នុងមនោគមន៍វិជ្ជា Nazi។ [...] ការបំផ្លិចបំផ្លាញជីវិតវប្បធម៌ និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋប៉ូឡូញ។ និងហាមឃាត់មិនឱ្យមានការបង្កកំណើតរបស់ប្រជាពលរដ្ឋប៉ូឡូញ")។

[២០២] កំណត់សម្គាល់ ៤៧ ក្នុងឯកសារដើម ដូចឯកសារយោងខាងលើ ទំព័រ ១០១ , ១៦០-១៦១។

វិទ្យាស្ថានពិសេសនានា[២០៣]។ នៅក្នុងពាក្យពេចន៍របស់តុលាការយោធា "អ្នកត្រួតពិនិត្យទាំងនេះបានធ្វើការដោយផ្ទាល់ក្រោមការគ្រប់គ្រង និងត្រួតពិនិត្យពី Hofmann និង Hildebrandt នៅចន្លោះពេលខុសគ្នា ដែលអ្នកទាំងពីរនេះបានដឹងអំពីសកម្មភាពរបស់ពួកគេ"[២០៤]។ ដោយផ្អែកទៅលើការចូលរួមរបស់ពួកគេនៅក្នុងកម្មវិធីចាប់ពង្រត់ និងការដឹងរបស់ពួកគេអំពីអំពើរបស់អ្នកត្រួតពិនិត្យរបស់ RuSHA ដែលបំពេញភារកិច្ចតាមការណែនាំរបស់ពួកគេ តុលាការយោធាបានសន្និដ្ឋានថា Hofmann និង Hildebrand មាន "ការទទួលខុសត្រូវពេញលេញ" ចំពោះការចាប់ពង្រត់នានា[២០៥]។ ចំពោះកម្មវិធីរំលូតកូន តុលាការយោធាបានរកឃើញថា Hofmann និង Hildebrandt បានចូលរួមនៅក្នុងកម្មវិធីនោះ ហើយបានចេញសេចក្តីណែនាំ ដោយមានរៀបរាប់លម្អិតអំពីរបៀបដែលកម្មវិធីនេះត្រូវបានដាក់ឱ្យអនុវត្ត[២០៦]។ ដោយផ្អែកទៅលើការចូលរួមរបស់ពួកគេនៅក្នុងកម្មវិធីនោះ និងការដឹងរបស់ពួកគេអំពីការអនុវត្តរបស់អ្នកត្រួតពិនិត្យខាងពូជសាសន៍របស់ RuSHA តុលាការយោធាបានសន្និដ្ឋានថា Hofmann និង Hildebrand ទទួលខុសត្រូវចំពោះការរំលូតកូនដោយបង្ខំ[២០៧]។ តុលាការយោធាបានសន្និដ្ឋានថា "ដោយបានវិនិច្ឆ័យតាមបទដ្ឋាននៃភស្តុតាង កំណត់ហេតុ

---

[២០៣] រឿងក្តី *RuSHA* ទំព័រ ១០២, ១០៦។

[២០៤] រឿងក្តី *RuSHA* ទំព័រ ១០៦។

[២០៥] រឿងក្តី *RuSHA* ទំព័រ ១០២, ១០៦។ ផងដែរ សូមមើល យោបល់របស់ Bonomy សេចក្តីសម្រេចលើការរួមប្រព្រឹត្តក្នុងរឿងក្តី *Ojdanić* កថាខណ្ឌ ២៤។

[២០៦] រឿងក្តី *RuSHA* ទំព័រ ១១០-១១១។

> តួនាទីដែល RuSHA គឺសំខាន់ណាស់ក្នុងការអនុវត្តនូវការពិនិត្យមើលខាងជាតិសាសន៍របស់កម្មការិនីដែលមានគភ៌ ព្រមទាំងបុរសដែលនឹងក្លាយជាឪពុក ដើម្បីកំណត់ថាតើ គេអាចរំពឹងថានឹងបានទារកមួយដែលមិនមានលក្ខណៈសម្បត្តិល្អខាងជាតិសាសន៍ ឬទារកមួយដែលជាទីពេញចិត្ត។ និងដោយផ្អែកទៅលើការត្រួតពិនិត្យនេះ នឹងមានការសម្រេចថាតើការរំលូតកូន គួរតែឬអាចត្រូវបានធ្វើឡើងដោយមានបទបញ្ជាថា ពុំអនុញ្ញាតិឱ្យមានការរំលូតកូនឡើយ នៅពេលដែលគេរំពឹងថាទារកនោះនឹងមានលក្ខណៈសម្បត្តិល្អខាងជាតិសាសន៍ ហើយថា ការរំលូតកូនគួរត្រូវបានធ្វើឡើងនៅពេល ដែលទារកនោះមានលក្ខណៈមិនច្បាស់លាស់។

រឿងក្តី *RuSHA* ទំព័រ ១១០។

[២០៧] រឿងក្តី *RuSHA* ទំព័រ ១១១-១១២, ១៦០-១៦១។ នៅក្នុងអនុស្សរណៈសម្ងាត់មួយ Hildebrandt បានពណ៌នាអំពីទិសដៅជាសារវន្តនៃកម្មវិធីរំលូតកូន : "ដើម្បី [...] ជំរុញនូវការបង្កាត់ពូជសាសន៍ដែលមានលក្ខណៈល្អ សម្រាប់ពង្រឹងប្រជាជន



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00519462



ក្នុងរឿងក្តីនេះ កំណត់បានយ៉ាងច្បាស់នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមយ៉ាងពេញលេញ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[២០៨]។ តុលាការយោធានេះបានសម្រេចថា "ភស្តុតាងបង្ហាញហួសពីវិមតិសង្ស័យនូវការទទួលខុសត្រូវព្រហ្មទណ្ឌ និងពិរុទ្ធភាព [របស់ជនជាប់ចោទ] ចំពោះ... អំពើឧក្រិដ្ឋនានា" រួមទាំង ការចាប់ពង្រត់កុមារ ការរំលូតកូនដោយបង្ខំ ការលួចយកកុមារ ការដាក់ទណ្ឌកម្មចំពោះការរួមភេទជាមួយជនជាតិអាល្លឺម៉ង់ និងការទប់ស្កាត់មិនឱ្យមានការបន្តពូជរបស់ប្រជាពលរដ្ឋដែលជាសត្រូវ[២០៩]។

៦៩. ចំពោះធម្មនុញ្ញ London ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង រឿងក្តីអន្តរជាតិ និងការប្រកាសរបស់អាជ្ញាធរអន្តរជាតិនានា[២១០] អង្គបុរេជំនុំជម្រះមិនមានមន្ទិលឡើយ ដែល JCE I និង JCE II គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធ សម្រាប់សំណុំរឿង០០២។ នេះគឺជាស្ថានភាព ដោយមិនគិតអំពីថាតើវាជាការត្រឹមត្រូវដែរឬទេចំពោះ *Tadić* ក្នុងការផ្អែកទៅលើសេចក្តីព្រាងលក្ខន្តិកៈតុលាការ ICC និងផ្អែកទៅលើអនុសញ្ញាអន្តរជាតិ ចំពោះការបង្ក្រាបទៅលើការបំផ្ទុះគ្រាប់បែករបស់ភេរវជន។

៧០. បណ្តឹងឧទ្ធរណ៍លើកឡើងនូវទឡ្ហីករណ៍បន្ថែមថា *រឿងក្តី Tadić* បានផ្អែកដោយមិនត្រឹមត្រូវលើច្បាប់ជាតិ និងយុត្តិសាស្ត្រជាតិ ដើម្បីកំណត់អំពីលក្ខណៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទោះបីជាការរកឃើញរបស់ខ្លួន៖

> នៅក្នុងផ្នែកកំពុងពិភាក្សានេះ ច្បាប់ជាតិ និងយុត្តិសាស្ត្រជាតិ មិនអាចត្រូវបានយកមកធ្វើជាសំអាងថាជាប្រភពនៃគោលការណ៍ ឬវិធានអន្តរជាតិឡើយ ផ្អែកតាមទ្រឹស្តីទូទៅនៃគោល

---

របស់យើង និងដើម្បីសម្រេចឱ្យបាននូវការបំបាត់ចោលទាំងស្រុងនូវ អ្វីគ្រប់យ៉ាងដែលមានលក្ខណៈសម្បត្តិមិនល្អខាងជាតិសាសន៍" ដូចឯកសារយោងខាងលើ ទំព័រ ១១១-១១២។

[២០៨] រឿងក្តី *RuSHA* ទំព័រ ១៥២-១៥៣។

[២០៩] រឿងក្តី *RuSHA* ទំព័រ ១៦០ (សំអាងហេតុទាក់ទិននឹង Hofmann)។ ផងដែរ សូមមើលឯកសារយោងខាងលើ ទំព័រ ១៦០-១៦១ (ផ្តល់សំអាងហេតុដូចគ្នា ទាក់ទិននឹង Hildebrand)។ តុលាការបានកាត់ទោសបុរសទាំងពីរនាក់ឱ្យជាប់គុក ២៥ឆ្នាំ ចំពោះអំពើរបស់ពួកគាត់។ រឿងក្តី *RuSHA* ទំព័រ ១៦៦។

[២១០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២-៣៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

00519463



ការណ៍ច្បាប់ទូទៅ ដែលត្រូវបានទទួលស្គាល់ដោយបណ្តាប្រជាជាតិនៅលើពិភពលោក។ ដើម្បីអាចទទួលយកច្បាប់ជាតិ និងយុត្តិសាស្ត្រជាតិនេះ វាចាំបាច់ត្រូវបង្ហាញថា ប្រទេសភាគច្រើនអនុម័តយកនូវទ្រឹស្តីដូចគ្នានៃគោលបំណងរួមនេះ[២១១]។

តាមរយៈការស្ទង់មតិការលើកឡើងបែបនេះ មិនបានទទួលនូវការគាំទ្រនោះទេ។ ដោយពិចារណាអំពីមូលហេតុដែលបានបញ្ជាក់ខាងលើ អង្គបុរេជំនុំជម្រះមិនចាំបាច់ឆ្លើយតបនឹងទឡ្ហីករណ៍នេះឡើយ។

៧១. មុននឹងពិនិត្យទៅលើទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) អង្គបុរេជំនុំជម្រះឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងដោយ អៀង ធីរិទ្ធ ដែលផ្អែកទៅលើសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី Kai Ambos[២១២] ថា មូលដ្ឋានសម្រាប់ទម្រង់ទីពីរនៃសហឧក្រិដ្ឋកម្មរួម ("JCE II") មានលក្ខណៈមិនច្បាស់លាស់[២១៣]។ ទឡ្ហីករណ៍នេះត្រូវផ្អែកលើការពិចារណាថា JCE II អាចត្រូវបានចាត់ទុកថាជាប្រភេទរងនៃ JCE I ប្រសិនបើវាត្រូវបានបកស្រាយក្នុងលក្ខណៈមានកម្រិត ឬជាការលាតសន្ធឹងនៃការទទួលខុសត្រូវ ប្រសិនបើវាត្រូវបានបកស្រាយក្នុងលក្ខណៈទូលំទូលាយ[២១៤]។ JCE II ក៏មានលក្ខណៈស្រដៀងទៅនឹង JCE III ហើយដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខណៈមិនច្បាស់លាស់នេះមិនមានអត្ថិភាពឡើយ ហើយការយោងនៅក្នុង *រឿងក្តី Tadić* ទៅលើលក្ខខណ្ឌតម្រូវនៃចេតនាពិរុទ្ធ (*mens rea*) ដើម្បីបង្ហាញនូវការដឹងរបស់ជនជាប់ចោទអំពីលក្ខណៈនៃប្រព័ន្ធ[២១៥] មិនមែនមានន័យថា ការដឹង គឺវាគ្រប់គ្រាន់នោះទេ។ *Tadić* ក៏តម្រូវឱ្យមាន "ចេតនាផងដែរ ក្នុងការជួយឱ្យសម្រេចបាននូវផែនការដែលត្រូវបានធ្វើឡើងរួម ដើម្បីធ្វើ

---

[២១១] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២២៥។

[២១២] សារណារបស់អ្នកមិនមែនភាគីនៃរឿងក្តី Kai Ambos ផ្នែក II ៤។

[២១៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ស្តីពី JCE មូលហេតុ ៤ និង ៥ កថាខណ្ឌ ៣៨, ៤៤ និង ៥០។

[២១៤] សារណារបស់អ្នកមិនមែនភាគីនៃរឿងក្តី Kai Ambos កថាខណ្ឌ ១៩ និង ២២ យោងទៅលើ V. Haan សហឧក្រិដ្ឋកម្មរួម។ *Die Entwicklung einer mittäterschaftlichen Zurechnungsfigur im Völkerstrafrecht* (2008), 200, 274 et seq

[២១៥] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០៣។

00519464



បាបអ្នកទោស"[២១៦]។ ចៅក្រម Hunt បានកត់សម្គាល់យ៉ាងត្រឹមត្រូវនៅក្នុងយោបល់ដាច់ដោយឡែករបស់គាត់ចំពោះសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពី JCE របស់ *Ojdanić* ថា ៖

> "ប្រភេទទីពីរ មិនខុសគ្នាច្រើនពីប្រភេទទីមួយឡើយ។ តួនាទីរបស់ជនជាប់ចោទនៅក្នុងប្រភេទទីពីរ គឺពិតជាដូចគ្នាទៅនឹងជនជាប់ចោទនៅក្នុងប្រភេទទីមួយ។ ជនជាប់ចោទទាំងពីរនេះអនុវត្តតួនាទីមួយនៅក្នុង JCE ដើម្បីធ្វើឱ្យសម្រេចបាននូវកម្មវត្ថុនៃសហកម្មនោះ ដែលខុសគ្នាទៅនឹងតួនាទីរបស់បុគ្គលដែលប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដោយផ្ទាល់។ ពួកគេទាំងពីរនាក់នេះប្រាកដជាដឹងថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នឹងកើតមានឡើង។ ការទទួលស្គាល់នូវអ្វីដែលមានលក្ខណៈមិនគ្រប់គ្រាន់ នឹងបដិសេធនូវអត្ថិភាពនៃ 'គោលបំណងរួម'"[២១៧]។

៧២. ចំពោះការរកឃើញរបស់ខ្លួនថា JCE I និង JCE II គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិតាំងពីលិខិតុបករណ៍អន្តរជាតិ ក្រោយសង្គ្រាមលោកលើកទី២ ដូចដែលបានពិភាក្សាខាងលើ ព្រមទាំងការរកឃើញពីមុនៗរបស់ខ្លួនថា ទម្រង់នៃការទទួលខុសត្រូវទាំងនេះ មានមូលដ្ឋាននៅក្នុងទស្សនាទានច្បាប់កម្ពុជាអំពីការប្រព្រឹត្តិរួម ដែលអាចអនុវត្តបាននៅពេលនោះ អង្គបុរេជំនុំជម្រះមិនមានមន្ទិលឡើយថា ការទទួលខុសត្រូវ ដែលផ្អែកលើគោលបំណង គម្រោងការណ៍ ឬផែនការរួម គឺអាចរកបាន និងអាចព្យាករណ៍បានយ៉ាងគ្រប់គ្រាន់ចំពោះចុងចោទ។

៧៣. ចំពោះការចោទប្រកាន់ថា ដីកាដែលត្រូវបានជំទាស់ ខកខានមិនបានសន្និដ្ឋានថា ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួម បានបង្កើតជាផ្នែក នៃច្បាប់ទំនៀមទម្លាប់អន្តជាតិនៅពេលវេលាដែលពាក់ព័ន្ធ[២១៨] អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់នេះគឺមិនមានភស្តុតាងបញ្ជាក់ឡើយ ហើយថា

---

[២១៦] ដូចសេចក្តីយោងខាងលើ។

[២១៧] យោបល់ដាច់ដោយឡែករបស់ចៅក្រម David Hunt សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Ojdanić* (យោបល់ដាច់ដោយឡែក សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Ojdanić*) កថាខណ្ឌ ៨ (សេចក្តីបញ្ជាក់បន្ថែម)។ សូមមើលផងដែរ សាលដីកាលើរឿងក្តី *Vasiljević* កថាខណ្ឌ ១០១។ សាលដីកាលើរឿងក្តី *Krnojelac* កថាខណ្ឌ ៨៤ បញ្ជាក់ថា "ក្រៅពីករណីជាក់លាក់នៃទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម ទស្សនទានតែមួយគត់នៃ JCE សន្និដ្ឋានជាមុនថា អ្នកចូលរួមក្នុង JCE ក្រៅពីអាទិចារីនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត មានចំណែកចេតនាឧក្រិដ្ឋរួមរបស់ចារី"។

[២១៨] បណ្តឹងឧទ្ធរណ៍ របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៥២។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

ដីកាដែលត្រូវបានជំទាស់ បានបញ្ជាក់នូវការរកឃើញដ៏ត្រឹមត្រូវយ៉ាងច្បាស់។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់នេះគ្មានមូលដ្ឋានទេ ចំពោះការចោទប្រកាន់ដែលថា ដោយសារតែយុត្តិសាស្ត្រអន្តរជាតិដែលត្រូវបានយកមកធ្វើជាសំអាងនៅក្នុង *រឿងក្តី Tadić* សំដៅជាសំខាន់ទៅលើបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុង សង្គ្រាមលោកលើកទី២ និងត្រូវបានផ្អែកទៅលើយុត្តិសាស្ត្រយោធាពីតុលាការអឺរ៉ុប និងតុលាការអាមេរិកខាងជើង និងផ្អែកទៅលើប្រព័ន្ធច្បាប់របស់ប្រទេសអូស្ត្រាលី និងហ្សំប៊ី ដូច្នេះវាមិនអាចផ្ទេរមកដែនដីអាស៊ីបានទេ និងមិនអាចយកមកអនុវត្តតាមការកែប្រែចាំបាច់ (*mutadis mutandis)* នៅ អ.វ.ត.ក និងនៅក្នុងបរិបទកម្ពុជាបានទេ[២១៩]។ ដរាបណាវាទាក់ទិនទៅនឹង JCE I និង II ទឡ្ហីករណ៍បន្ថែមទៀតដែលថា ដីកាដែលត្រូវបានជំទាស់ខកខានមិនបានផ្តល់នូវហេតុផលថា ហេតុអ្វីបានជាដីកានេះបដិសេធនូវទឡ្ហីករណ៍ដែលថា *រឿងក្តី Tadić* បង្កើតនូវករណីយុត្តិសាស្ត្រមិនគ្រប់គ្រាន់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងការផ្អែកទៅលើ JCE[២២០] នោះ គឺមានភស្តុតាងបញ្ជាក់ត្រឹមត្រូវ ហើយតាមពិត ដីកាដែលត្រូវបានជំទាស់បានបង្ហាញហេតុផលមិនគ្រប់គ្រាន់ទាក់ទិននឹងបញ្ហានេះ។ ប៉ុន្តែ កង្វះខាតនេះគឺមិនអាចធ្វើឲ្យមានការបដិសេធនូវការរកឃើញបានឡើយថា JCE I និង II អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដោយមានហេតុផលដូចបានបញ្ជាក់ខាងលើ។

៧៤. នៅពេលនេះ អង្គបុរេជំនុំជម្រះបែរពិនិត្យទៅលើទម្រង់ទីបី នៃសហឧក្រិដ្ឋកម្មរួម ដែលទម្រង់នេះមានភាពចម្រូងចម្រាសច្រើន និងមិនអាចបដិសេធបានឡើយ ដែលជាទម្រង់ទូលាយ (JCE III)។

## (iii) JCE III ទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម

៧៥. បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Tadić* ដែល JCE III មានមូលដ្ឋានយ៉ាងរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺមិនត្រូវបានគាំទ្រឡើយ និងមិនអនុលោមតាមលក្ខខណ្ឌតម្រូវ ដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបានកំណត់ត្រឹមតែ ទាក់ទិនទៅនឹងទស្សនៈច្បាប់ និងការអនុវត្តរបស់រដ្ឋ ដែលមានលក្ខណៈទូលំទូលាយ

---

[២១៩] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ៦៦។

[២២០] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ២២ និង២៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.

និងស៊ីគ្នាប៉ុណ្ណោះ[២២១]។ ជាលទ្ធផល ការអនុវត្តទម្រង់នេះនៅចំពោះមុខ អ.វ.ត.ក នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព[២២២]។ អ្នកដាក់បណ្តឹងឧទ្ធរណ៍សង្កត់ធ្ងន់ថា ដើម្បីឈានទៅដល់សេចក្តីសន្និដ្ឋានខាងលើ *រឿងក្តី* *Tadić* បានផ្អែកលើរឿងក្តីនានា ដូចជារឿងក្តី *Borkum Island* និងរឿងក្តី *Essen Lynching*។ នៅក្នុងរឿងក្តីទាំងនេះ តុលាការយោធាបានចេញត្រឹមតែសាលក្រមបញ្ជាក់ពិរុទ្ធភាពដ៏សាមញ្ញធម្មតាមួយប៉ុណ្ណោះ ដោយមិនបានផ្តល់សំអាងហេតុតាមទិដ្ឋភាពច្បាប់ឱ្យបានទូលំទូលាយ ស្តីពីបញ្ហានៃផែនការឧក្រិដ្ឋរួម ឬការវាយដំពីសំណាក់ហ្វូងមនុស្សឡើយ។ ដូច្នេះ *រឿងក្តី* *Tadić* បានត្រឹមតែដកស្រង់ពាក្យពេចន៍ផ្ទាល់ពីរដ្ឋអាជ្ញាយោធា [...] និងទាញសេចក្តីសន្និដ្ឋានថា ចៅក្រមបានប្រើប្រាស់សំអាងហេតុ [របស់រដ្ឋអាជ្ញា]”[២២៣]។ លើសពីនេះទៀត *រឿងក្តី*

---

[២២១] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ៤០ និងជើងទំព័រ ១០៥ ដែលដើមបណ្តឹងឧទ្ធរណ៍យោងទៅលើ Shane Darcy, *Imputed Criminal Liability and the Goals of International Justice,* 20 LEIDEN J. INT'L L. 377, 384-85 (2007), យោងទៅលើប្រភពនោះ សម្រាប់ប្រភេទទីបីនៃJCE:

> អង្គជំនុំជម្រះតុលាការកំពូលបានសំអាងលើសេចក្តីសម្រេចរបស់តុលាការអ៊ីតាលីមួយចំនួនតូច និងការជំនុំជម្រះក្តីមួយចំនួនតូចនៅចំពោះមុខតុលាការយោធាសម្ព័ន្ធមិត្ត ដែលភាគច្រើនទាក់ទិននឹងអំពើហិង្សាដោយហ្វូងមនុស្សដែលផ្អែកការសំអាងតាមគោលការណ៍នេះ។ គេមិនទាន់ប្រាកដនៅឡើយថាតើការប្រើប្រាស់ទម្រង់ទូលាយនៃការទទួលខុសត្រូវផែនការរួម ដោយរដ្ឋមួយចំនួនតូចនេះ វាបានផ្តល់ជាច្បាប់ទំនៀមទម្លាប់ ដែរឬយ៉ាងណា ជាពិសេស ដោយយល់ឃើញថា គ្មានសន្និសញ្ញាណាមួយដែលត្រូវបានគេប្រើប្រាស់កាល សម័យក្រោយសង្គ្រាមនោះ បានទទួលស្គាល់ទស្សនទាននៃការទទួលខុសត្រូវ តាមទម្រង់ JCE III នេះឡើយ។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាមានការគាំទ្រតិចតួចចំពោះ JCE ប្រភេទទីបី នៅក្នុងច្បាប់ព្រហ្មទណ្ឌក្នុងស្រុក ប៉ុន្តែកត់សម្គាល់ថា ប្រព័ន្ធគតិយុត្តិភាគច្រើនពុំចាត់ទុកសញ្ញាណនេះដូចៗ គ្នាឡើយ។ អ្នករិះគន់បានលើកអំណះអំណាងថា យុត្តាធិការមួយចំនួនធំ មិនគាំទ្រការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនានា ដែលពុំស្ថិតនៅក្នុងវិសាលភាពនៃគោលបំណងរបស់ជនទាំងនោះ ដែលបានចូលរួមក្នុងផែនការឧក្រិដ្ឋរួមឡើយ។ មើលផងដែរ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ កថាខណ្ឌ ៣៨ ដែលចោទប្រកាន់ថា “មិនមានមូលដ្ឋានសម្រាប់ JCE III ក្នុងច្បាប់កម្ពុជាក្នុងឆ្នាំ ១៩៧៥-១៩៧៩ ឡើយ” ព្រមទាំងកថាខណ្ឌ ៤៤ ចោទប្រកាន់ថា ដីកាដែលត្រូវបានជំទាស់ បានយល់ឃើញដោយមិនត្រឹមត្រូវថា JCE III អនុវត្តនៅចំពោះ មុខ អ.វ.ត.ក ពីព្រោះ “JCE III មិនត្រូវបានដាក់បញ្ចូលក្នុងច្បាប់កម្ពុជាចន្លោះឆ្នាំ១៩៧៥-១៩៧៩”។

[២២២] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ២ ង)

[២២៣] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ៤៤-៤៥ យោងទៅលើ Jens David Ohlin, *Three Conceptual Problems with the Doctrine of Joint Criminal Enterprise,* 5 J. INT'L CRIM. JUST. 69, 75, n.10 (2007) ។ ដើមបណ្តឹងឧទ្ធរណ៍ក៏បាន យោងទៅលើ Powles ផងដែរ យោងទៅលើប្រភពនោះ រឿងក្តី *Essen Lynching* និង *Borkum Island*



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

*Tadić* បានផ្អែកមួយផ្នែកធំលើរឿងក្តីមួយចំនួនដែលពុំត្រូវបានបោះពុម្ពផ្សាយ ដែលមួយភាគធំមានប្រភពមកពីប្រទេសអ៊ីតាលី [...] ដែលបានប្រើប្រាស់ប្រព័ន្ធមួយ ដែលក្នុងនោះជនណាដែលជួយធ្វើអន្តរាគមន៍ក្នុងការប្រព្រឹត្តិបទល្មើស ត្រូវមានភារៈទទួលខុសត្រូវជាចារី រីឯប្រព័ន្ធច្បាប់ព្រហ្មទណ្ឌជាតិភាគច្រើនបានប្រើប្រាស់វិធីសាស្ត្រមួយដែលបែងចែកដាច់ពីគ្នារវាងចារី ឬជនដែលនៃបទល្មើស និងអ្នកសមគំនិតក្នុងបទល្មើស ឬភាគីទីពីរ។ លើសពីនេះទៀត ក្នុងចំណោមសេចក្តីសម្រេចលើរឿងក្តីនៅអ៊ីតាលីទាំងអស់នោះ មានតែមួយករណីគត់ (D'Ottavio et al.) អាចផ្តល់នូវការគាំទ្រដល់ JCE III"[២២៤]។ ដើមបណ្តឹងឧទ្ធរណ៍បានកត់សម្គាល់ទឡ្ហីករណ៍របស់ Ambos ស្តីពីរឿងក្តីអ៊ីតាលីនានា ដូចខាងក្រោមនេះ ៖

> នៅក្នុងការជំនុំជម្រះរឿងក្តីនេះ ដែលផ្ទុយទៅនឹងការជំនុំជម្រះក្តីនៅចំពោះមុខតុលាការយោធាសហរដ្ឋអាមេរិក និងអង់គ្លេស មិនមានការផ្អែកទៅច្បាប់អន្តរជាតិឡើយ ប៉ុន្តែច្បាប់ជាតិត្រូវបានអនុវត្តទាំងស្រុង។ លើសពីនេះទៀត យុត្តិសាស្ត្រដែលចោទឡើងនេះ គឺពុំមានសង្គតិភាពឡើយ ពីព្រោះតុលាការកំពូលរបស់ប្រទេសអ៊ីតាលី [...] បានអនុម័តសេចក្តីសម្រេចពីរផ្ទុយគ្នា[២២៥]។

៧៦. ក.ស.ព ឆ្លើយតបថា "យុត្តាធិការរីកចំរើនជាច្រើនបានទទួលស្គាល់ទម្រង់នៃការរួមប្រព្រឹត្តប្រហាក់ប្រហែលទៅនឹង JCE III រួមទាំងការសមគំនិត ទ្រឹស្តីនៃឃាតកម្មជាយថាហេតុ និងទស្សនៈនៃការជាប់ពាក់ព័ន្ធផ្នែកព្រហ្មទណ្ឌ (*association de malfaiteurs*) ព្រមទាំងទ្រឹស្តីនៃការរួមប្រព្រឹត្តជា

---

ដែលរឿងក្តី *Tadić* បានសំអាងទៅលើនោះ មិនបាន "ផ្តល់នូវការគាំទ្រឲ្យបានច្បាស់លាស់ចំពោះការទទួលខុសត្រូវអនុលោមតាមទម្រង់ទូលាយនៃ JCE"។ ហើយជាពិសេសនៅក្នុងរឿងក្តីទីមួយ "ប្រហែលជាមានសញ្ញាសួរអំពីថាតើតុលាការនៅក្នុងរឿងក្តី *Essen Lynching* ពិតជាសម្រេចឲ្យជនដែលពុំមានចេតនាក្នុងការសម្លាប់ពិតប្រាកដមានទោសពីបទមនុស្សឃាតមែន ឬយ៉ាងណា" ពីព្រោះអយ្យការបានសន្និដ្ឋានថា ជនជាប់ចោទគួរតែត្រូវបានគេរកឃើញថាមានពិរុទ្ធ ដោយសារពួកគេមានចេតនាសម្លាប់ ហើយពិតណាស់ពួកគេត្រូវបានផ្តន្ទាទោសអំពីបទមនុស្សឃាត។ បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ៤០ ជើងទំព័រ ១០៥ ដោយយោងទៅលើ Steven Powles, *Joint Criminal Enterprise: Criminal Liability by Prosecutorial Ingenuity and Judicial Creativity?*, 2 J. INT'L CRIM. JUST. 606, 615-616 (2004)។

[២២៤] បណ្តឹងឧទ្ធរណ៍ អៀង សារី កថាខណ្ឌ ៤០។

[២២៥] ដូចសេចក្តីយោងខាងលើ ដែលយោងទៅលើសារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី Kai Ambos ទំព័រ ២៩។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ច្រើនផ្សេងៗទៀត"[២២៦]។ យោងតាម ក.ស.ព បានឱ្យដឹងថា ទឡ្ហីករណ៍ដែលថាការរកឃើញក្នុងរឿងក្តី *Tadić* ស្តីពី JCE ដែលបង្កើតជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានផ្អែកទៅលើរឿងក្តីតិចតួចបំផុត ដែលដកចេញពីយុត្តាធិការមួយចំនួនតូច មិនបានយកចិត្តទុកដាក់ចំពោះភស្តុតាងដ៏រឹងមាំ ដែលគាំទ្រការរកឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY ។

៧៧. ដោយបានពិនិត្យមើលទៅលើអាជ្ញាធរដែល *រឿងក្តី Tadić* បានផ្អែកទៅលើនោះ ទាក់ទិនទៅនឹងទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (JCE III) អង្គបុរេជំនុំជម្រះមានទស្សនថា ពួកគាត់មិនបានផ្តល់នូវភស្តុតាងគ្រប់គ្រាន់អំពីទស្សនៈច្បាប់ និងការអនុវត្តរបស់រដ្ឋ ដែលមានលក្ខណៈទូលំទូលាយ និងស៊ីគ្នាឡើយ នៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង០០២។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា JCE III មិនត្រូវបានទទួលស្គាល់ជាទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបានចំពោះការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ ដោយមានហេតុផលដូចខាងក្រោម។

៧៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ធម្មនុញ្ញ Nuremberg និងច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ មិនបានផ្តល់នូវការគាំទ្រជាក់លាក់ចំពោះទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (JCE III) ឡើយ។ អង្គបុរេជំនុំជម្រះមិនបានយល់ឃើញថា លិខិតុបករណ៍អន្តរជាតិបន្ថែមពីរទៀត ដែលត្រូវបានយោងដោយ*រឿងក្តី Tadić* ដែលមិនមានអត្ថិភាពនៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង០០២ អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់បង្កើតនូវឋានៈច្បាប់ទំនៀមទម្លាប់នៃ JCE III ក្នុងឆ្នាំ១៩៧៥-១៩៧៩ ឡើយ។

៧៩. ចំពោះយុត្តិសាស្ត្រអន្តរជាតិដែល *រឿងក្តី Tadić* បានផ្អែកលើនោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គហេតុនៃរឿងក្តី *Borkum Island* និងរឿងក្តី *Essen Lynching* ពិតណាស់អាចពាក់ព័ន្ធដោយផ្ទាល់ទៅនឹង JCE III។ ទោះបីជាយ៉ាងណាក៏ដោយ ដោយមិនមានសាលក្រមសំអាងហេតុ នៅក្នុងរឿងក្តីទាំងនេះ គេមិនអាចដឹងប្រាកដអំពីមូលដ្ឋាននៃការទទួលខុសត្រូវ ដែលសម្រេចដោយ

[២២៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣ ដោយយោងទៅលើសេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០ ជើងទំព័រ ២២-២៦។

តុលាការយោធាឡើយ។ នៅក្នុងរឿងក្តីទីមួយ[២២៧] ជនជាប់ចោទ រួមមានមន្ត្រីជាន់ខ្ពស់មួយចំនួន កូនទាហានមួយចំនួន ចៅហ្វាយក្រុង Borkum ប៉ូលីសមួយចំនួន ជនស៊ីវិលម្នាក់ និងមេដឹកនាំក្រុមពលកររីច (Reich Labour Corps)។ ជនជាប់ចោទទាំងអស់ "ត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មសង្គ្រាម ជាពិសេសទាំងបទ "លើកទឹកចិត្ត ជួយផ្តល់មធ្យោបាយ ជំរុញ និងចូលរួមនៅក្នុងការសម្លាប់ដោយព្រៃផ្សៃ ដោយចេតនា និងខុសច្បាប់" ទៅលើទ័ពអាកាស និងពីបទ "លើកទឹកចិត្ត ជួយផ្តល់មធ្យោបាយ ជំរុញ និងចូលរួមក្នុងការវាយប្រហារដោយព្រៃផ្សៃ ដោយចេតនា និងខុសច្បាប់ទៅលើ" ទ័ពអាកាស"[២២៨]។ ផ្អែកលើការពិនិត្យឡើងវិញរបស់ខ្លួនលើសេចក្តីសន្និដ្ឋានរបស់អយ្យការ *Tadić* ពិចារណាថា រដ្ឋអាជ្ញាបានដាក់ឲ្យពិចារណានូវទ្រឹស្តីនៃគោលបំណងរួម ដែលសន្មតទុកជាមុនថា អ្នកចូលរួមទាំងអស់នៅក្នុងគោលបំណងរួម មានចំណែកចេតនាឧក្រិដ្ឋដូចគ្នា ពោលគឺប្រព្រឹត្តអំពើមនុស្សឃាត[២២៩]។ បន្ទាប់មក ដោយមិនមានសាលក្រមសំអាងហេតុ វាអាចសន្មតបានថា តុលាការ "បានគាំទ្រទ្រឹស្តីនៃគម្រោងការណ៍រួម ប៉ុន្តែស្ថិតក្នុងទម្រង់ផ្សេងគ្នាមួយ ពីព្រោះតុលាការបានរកឃើញថា ជនជាប់ចោទខ្លះមានទោសទាំងបទបំពារបំពានលើរាងកាយ និងការ

---

[២២៧] នៅក្នុងរឿងក្តីនេះ សមាជិកនាវិករបស់យន្តហោះ Flying Fortress សហរដ្ឋអាមេរិក ដែលត្រូវបានបង្ខំឲ្យចុះចតនៅលើកោះ Borkum ប្រទេសអាល្លឺម៉ង់ ត្រូវបានគេចាប់ជាឈ្លើយសឹក និងបង្ខំឲ្យដើរជាក្បួន និងត្រូវបានវាយដំដោយសមាជិករបស់ក្រុមពលករ Reich Labour Corps បន្ទាប់មកជនស៊ីវិលនៅតាមផ្លូវក៏បានវាយដំពួកគេ ហើយក្រោយមកទៀតជនស៊ីវិលបានវាយប្រហារពួកគេ ដោយក្នុងខណៈនោះទាហានដែលបណើរពួកគេក៏បានចូលរួមក្នុងការវាយដំពួកគេដែរ។ ព្រឹត្តការណ៍នេះបានកើតឡើងក្រោយពីចៅហ្វាយក្រុង Borkum បានស្រែកញុះញង់ឲ្យហ្វូងមនុស្សសម្លាប់ពួកគេ និងនៅមុនពេលដែលទ័ពអាកាសទាំងនោះត្រូវបានបាញ់ និងសម្លាប់ដោយទាហានអាល្លឺម៉ង់នៅពេលដែលមកដល់សាលាក្រុង។

[២២៨] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២១០ ដោយយោងទៅលើ លិខិតចោទប្រកាន់ នៅក្នុងការចុះផ្សាយតាមមីក្រូហ្វីមបណ្ណសារជាតិរបស់សហរដ្ឋអាមេរិក I ("លិខិតចោទប្រកាន់")។

[២២៩] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២១១។

សម្លាប់មនុស្ស[២៣០] ចំណែកអ្នកផ្សេងទៀត ត្រូវបានរកឃើញថាមានទោសពីបទបំពារបំពានលើរាងកាយតែប៉ុណ្ណោះ[២៣១]។ លើសពីនេះទៀត តុលាការទាញសេចក្តីសន្និដ្ឋានថា ៖

> "ជនជាប់ចោទទាំងអស់ដែលរកឃើញថាមានទោស ត្រូវតែទទួលខុសត្រូវចំពោះការអនុវត្តតាមគម្រោងការណ៍ឧក្រិដ្ឋរួម ចេតនាក្នុងវាយប្រហារលើឈ្លើយសឹក។ ប៉ុន្តែ ពួកគេខ្លះក៏ត្រូវបានរកឃើញថាមានទោសពីបទមនុស្សឃាតផងដែរ ទោះបីជាមិនមានភស្តុតាងបង្ហាញថាពួកគេបានសម្លាប់អ្នកទោសជាក់ស្តែងក៏ដោយ។ តាមសេចក្តីសន្និដ្ឋាន ការសម្រេចនេះផ្អែកទៅលើមូលដ្ឋានដែលថា ជនជាប់ចោទដោយសារតែឋានៈ តួនាទី ឬទង្វើរបស់ពួកគេ គឺស្ថិតនៅក្នុងតួនាទីមួយដែលគេអាចព្យាករណ៍បានថា ការបំពារបំពានលើរាងកាយ នឹងអាចនាំឱ្យជនរងគ្រោះស្លាប់ ដោយសារតែការចូលរួមរបស់ពួកគេខ្លះក្នុងចំណោមពួកគេទាំងអស់នោះក្នុងការវាយប្រហារនេះ"[២៣២]។

៨០. អង្គបុរេជំនុំជម្រះមិនបានទាញសេចក្តីសន្និដ្ឋានចេញពីកាលៈទេសៈទាំងនេះថា ទម្រង់នៃការទទួលខុសត្រូវ ដែលតុលាការយោធាបានផ្អែកទៅលើ ដើម្បីផ្តន្ទាទោស Akkerman, Krolikovski, Schmitz, Wentzel, Seiler និង Goebbel ពីបទអំពើមនុស្សឃាតនោះ គឺជាទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (JCE III) ឡើយ។ តាមពិត ដោយពិចារណាទៅលើការពិតដែលថាអយ្យការបានថ្លែងសំអាងថា ជនជាប់ចោទទាំងអស់មានចំណែកចេតនាសម្លាប់ទ័ពអាកាស តុលាការក៏អាចទទួលយកបានផងដែរថា បុគ្គលទាំងប្រាំមួយនាក់នេះ មានចេតនាបែបនេះ ជាជាងថាគ្រាន់តែបានព្យាករណ៍អំពីលទ្ធផលដែលអាចកើតមានឡើងយ៉ាងដូច្នេះ។

---

[២៣០] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២១២ ដោយយោងទៅលើ លិខិតចោទប្រកាន់ ទំព័រ ១២៨០-១២៨៦ ជើងទំព័រ ២៦៨ ដែល "ជនជាប់ចោទ Akkerman, Krolikovski, Schmitz, Wentzel, Seiler និង Goebbel ទាំងអស់ត្រូវបានរកឃើញថាមានពិរុទ្ធពីបទមនុស្សឃាត និងបង្ករបួសស្នាម ហើយត្រូវបានកាត់ទោសប្រហារជីវិត លើកលែងតែ Krolikovski ប៉ុណ្ណោះ ដែលត្រូវបានកាត់ ទោសដាក់គុកមួយជីវិត។

[២៣១] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២១២ ដោយយោងទៅលើលិខិតចោទប្រកាន់ ទំព័រ ១២៨០-១២៨៦ ជើងទំព័រ ២៦៩ ដែល "ជនជាប់ចោទ Pointner, Witzke, Geyer, Albrecht, Weber, Rommel, Mammenga និង Heinemann ត្រូវបានរកឃើញថាមានពិរុទ្ធអំពីបទបង្ករបួសស្នាម ហើយជាប់គុកពី ២-២៥ឆ្នាំ។

[២៣២] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២១៣។

00519471



៨១. នៅក្នុងរឿងក្តីទីពីរ[២៣៣] *រឿងក្តី Tadić* 'បានសន្មត'[២៣៤] ថា តុលាការបានទទួលយកគោលជំហររបស់អយ្យការ។ អង្គជំនុំជម្រះតុលាការកំពូលបានទាញសេចក្តីសន្និដ្ឋាន[២៣៥] ចេញពីទឡ្ហីករណ៍របស់ភាគីនានា និងសាលក្រមបញ្ជាក់ពីពិរុទ្ធភាព"ថាតុលាការបានប្រកាន់យកនូវសញ្ញាណដែលជនជាប់ចោទគ្រប់រូបត្រូវបានរកឃើញថា មានទោសបានចូលរួមក្នុងកម្រិតផ្សេងៗគ្នាក្នុងការសម្លាប់មនុស្ស ហើយថា មិនមែនពួកគេទាំងអស់មានចេតនាសម្លាប់មនុស្សឡើយ ប៉ុន្តែពួកគេទាំងអស់មានចេតនាចូលរួមក្នុងធ្វើបាបឈ្លើយសឹកដោយខុសច្បាប់ ហើយត្រូវបានរកឃើញថា មានទោសពីបទមនុស្សឃាត ពីព្រោះពួកគេ "បានពាក់ព័ន្ធក្នុងការសម្លាប់មនុស្ស""[២៣៦]។ វាក៏ត្រូវបានគេទាញសេចក្តីសន្និដ្ឋានផងដែរថា "តុលាការបានសន្មតថា ទណ្ឌិតទាំងនោះដែលគ្រាន់តែបានធ្វើការវាយប្រហារ ឬបានញុះញង់ឱ្យមានអំពើមនុស្សឃាត អាចព្យាករណ៍ជាមុនបានថា អ្នកផ្សេងទៀតនឹងសម្លាប់អ្នកទោស"[២៣៧]។ សេចក្តីសំអាងចុងក្រោយនេះ ហាក់បីដូចជាមានសុវត្ថិភាពជាងសេចក្តីសំអាងលើកមុន ទោះបីជាមិនមានការចង្អុលបង្ហាញក្នុងករណីដែលថា រដ្ឋអាជ្ញាថែមទាំងបានផ្អែកយ៉ាងច្បាស់ទៅលើទស្សនាទាននៃគម្រោងការណ៍រួមក៏ដោយ ហើយករណីនេះតែមួយនឹងមិនផ្តល់នូវយុត្តិកម្មដល់ការរកឃើញថា JCE III មានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ។

៨២. *រឿងក្តី* *Tadić* ក៏បានផ្អែកផងដែរទៅលើរឿងក្តីជាច្រើនដែលយកមកជំនុំជម្រះនៅចំពោះមុខតុលាការអ៊ីតាលី ក្រោយសង្គ្រាមលោកលើកទី២ ទាក់ទិនទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ១៩៤៣ និងឆ្នាំ១៩៤៥។ បទឧក្រិដ្ឋទាំងនេះ ត្រូវបានប្រព្រឹត្តឡើងដោយជនស៊ីវិល ឬមន្ត្រីយោធា ដែលជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៃក្រុមដែលគេហៅថា "*Repubblica Sociale Italiana*" ("RSI")។ RSI គឺជារដ្ឋាភិបាលមួយ *ពិតប្រាកដ* ក្រោមការត្រួត

---

[២៣៣] នៅក្នុងរឿងក្តីនេះ មនុស្សមួយក្រុមបានចូលរួមក្នុងការវាយដំទ័ពអាកាសបីនាក់ដែលបណ្តាលឱ្យពួកគេស្លាប់ ហើយវាមិនអាចកំណត់បានឡើយថា នរណាបានវាយបណ្តាលឱ្យស្លាប់ នៅក្នុងករណីនីមួយៗ។

[២៣៤] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០៨។

[២៣៥] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២០៩។

[២៣៦] ដូចសេចក្តីយោងខាងលើ។

[២៣៧] ដូចសេចក្តីយោងខាងលើ។

ត្រារបស់អាល្លឺម៉ង់ ដែលត្រូវបានបង្កើតឡើងដោយអ្នកដឹកនាំកាន់លទ្ធិហ្វាស៊ីស នៅប្រទេសអ៊ីតាលីប៉ែកកណ្តាល និងប៉ែកខាងជើង បន្ទាប់ពីប្រទេសអ៊ីតាលីបានប្រកាសសង្គ្រាមប្រឆាំងនឹងប្រទេសអាល្លឺម៉ង់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៤៣។ បទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងឈ្លើយសឹក អ្នកគាំទ្រអ៊ីតាលី ឬសមាជិកនៃកងទ័ពអ៊ីតាលី ដែលវាយប្រយុទ្ធប្រឆាំងនឹងអាល្លឺម៉ង់ និង RSI។ ករណីទាំងនេះ ដែលតុលាការក្នុងស្រុកនានាបានអនុវត្តច្បាប់ក្នុងស្រុក មិនចាត់ទុកជាយុត្តិសាស្ត្រអន្តរជាតិឡើយ ហើយអង្គបុរេជំនុំជម្រះមិនចាត់ទុកករណីទាំងនេះជាករណីយុត្តិសាស្ត្រដ៏ត្រឹមត្រូវសម្រាប់គោលបំណង ក្នុងការសម្រេចអំពីឋានៈនៃច្បាប់ទំនៀមទម្លាប់នៅក្នុងផ្នែកនេះឡើយ។

៨៣. ចំពោះហេតុផលដែលបានបញ្ជាក់ខាងលើ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា បញ្ជីសំអាងផ្លូវច្បាប់ដែលត្រូវបានគេយកមកធ្វើជាសំអាងក្នុង *រឿងក្តី Tadić* ហើយជាលទ្ធផលបញ្ជីសំអាងផ្លូវច្បាប់ទាំងនោះ ត្រូវបានគេយកមកធ្វើជាសំអាងក្នុងដីកាដែលត្រូវបានជំទាស់ បង្កើតបានជាមូលដ្ឋានដ៏រឹងមាំគ្រប់គ្រាន់ដើម្បីធ្វើសេចក្តីសន្និដ្ឋានថា JCE III ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ នៅពេលវេលាដែលពាក់ព័ន្ធចំពោះសំណុំរឿង០០២។

៨៤. ឋានៈពិតប្រាកដនៃគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌជាប្រភពជំនួយ ឬប្រភពសំខាន់នៃច្បាប់អន្តរជាតិ គឺមានលក្ខណៈមិនច្បាស់។ ទោះបីជាយ៉ាងណាក៏ដោយ សាលដីកាមួយចំនួនលើបណ្តឹងឧទ្ធរណ៍របស់តុលាការ ICTY បញ្ជាក់ ឬលើកឡើងថា វាអាចទទួលយកបានក្នុងការមានដំណោះស្រាយចំពោះគោលការណ៍បែបនោះក្នុងការកំណត់ មិនត្រឹមតែធាតុផ្សំនៃបទឧក្រិដ្ឋអន្តរជាតិប៉ុណ្ណោះទេ[២៣៨] ប៉ុន្តែថែមទាំងអំពីវិសាលភាពនៃទម្រង់នៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋអន្តរជាតិ[២៣៩] ទៀតផង។ ក្នុងរឿងក្តី *Tadić* ក្នុងខណៈដែលមានការពិចារណាថា ច្បាប់ជាតិ និងយុត្តិសាស្ត្រជាតិ

---

[២៣៨] ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Furundžija* បានសម្រេចថា “ដើម្បីឈានមកដល់និយមន័យដ៏ត្រឹមត្រូវអំពីការរំលោភសេពសន្ថវៈ ដែលផ្អែកលើគោលការណ៍នៃភាពជាក់លាក់នៃច្បាប់ព្រហ្មទណ្ឌ [...] វាចាំបាច់ត្រូវរកមើលគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ ដែលមាននៅក្នុងប្រព័ន្ធគតិយុត្តិសំខាន់ៗនៅលើពិភពលោក។ គោលការណ៍ទាំងនេះ អាចត្រូវបានទាញចេញពីច្បាប់ជាតិ ដោយមានការប្រុងប្រយ័ត្នយ៉ាងត្រឹមត្រូវ”។ សាលក្រមលើរឿងក្តី *Furundžija* កថាខណ្ឌ ១៧៧។

[២៣៩] សូមមើលសាលដីកាលើរឿងក្តី *Blaškić* កថាខណ្ឌ ៣៤-៤២។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

មិនអាចត្រូវបានគេយកមកសំអាងជាប្រភពនៃវិធាន ឬគោលការណ៍អន្តរជាតិដើម្បីបង្កើតនូវឋានៈច្បាប់ទំនៀមទម្លាប់នៃ JCE នោះ[២៤០] អង្គជំនុំជម្រះតុលាការកំពូល បានផ្អែកលើច្បាប់ជាតិ និងយុត្តិសាស្ត្រជាតិដើម្បីធ្វើការសន្និដ្ឋានថា ទ្រឹស្តីនៃJCE មានឫសគល់នៅក្នុងច្បាប់ជាតិរបស់បណ្តារដ្ឋជាច្រើន[២៤១]។ ភាពខុសគ្នាក្នុងចំណោមប្រព័ន្ធច្បាប់នានា ទាក់ទិននឹងចេតនាពិរុទ្ធ ដែលតម្រូវឱ្យភ្ជាប់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើជនជាប់ចោទចំពោះបទឧក្រិដ្ឋ ដែលត្រូវបានអនុវត្តដោយបុគ្គលផ្សេងទៀត ដែលបំពេញកិច្ចការជាមួយគ្នា ប៉ុន្តែនោះហួសពីអ្វីដែលជនជាប់ចោទមានចេតនា។ នេះអាចពន្យល់បានថាហេតុអ្វីបានជាក្នុងរឿងក្តី *Tadić* ប្រើប្រាស់ពាក្យពេចន៍ជាច្រើនដែលមានប្រភេទអត្ថន័យខុសគ្នា នៅពេលដែលកំណត់អំពីសភាពចិត្តដែលតម្រូវសម្រាប់ JCE III[២៤២]។

---

[២៤០] ដើម្បីឱ្យការសំអាងនេះអាចទទួលយកបាន "វាចាំបាច់ត្រូវបង្ហាញថា [...] ប្រព័ន្ធគតិយុត្តិសំខាន់ៗ របស់ពិភពលោក អនុវត្តវិធីសាស្ត្រដូចគ្នាចំពោះសញ្ញាណនេះ" ដែលតុលាការយល់ឃើញថា នេះមិនអាចទៅរួចឡើយ។ សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២២៥។

[២៤១] សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២២៥។ ជាពិសេស អំពីសេណារីយ៉ូដែលអ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមផ្សេងទៀតក្នុង JCE ប្រព្រឹត្តបទឧក្រិដ្ឋដែលមិនត្រូវបានគេប្រមើលឃើញមាននៅក្នុងគោលបំណងរួម ឬគ្រោងការណ៍រួម (ទាក់ទិនទៅនឹង JCE III) នៅក្នុងប្រទេសខ្លះ ជននោះតែម្នាក់ឯងប៉ុណ្ណោះនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋនោះ។ សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២២៤ ជើងទំព័រ ២៨៣-២៨៤ ដោយយោងទៅលើប្រទេសអាល្លឺម៉ង់ និងប្រទេសហូឡង់។ ផងដែរសូមមើល Sassoli & Olson ទំព័រ ៧ (loc. cit. 47) ដោយយោងទៅលើរឿងក្តីនោះ "អង្គជំនុំជម្រះអាចបានដាក់បន្ថែមប្រទេសស្វីសនៅក្នុងបញ្ជី"។ នៅក្នុងប្រទេសដទៃទៀត ប្រសិនបើបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត "មិនស្ថិតនៅក្នុងផែនការរួម ប៉ុន្តែអាចព្យាករណ៍ទុកជាមុនបាន" ជនទាំងអស់ដែលមានចេតនានៅក្នុងគោលបំណងរួម ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបទឧក្រិដ្ឋនោះផងដែរ។ សាលដីកាលើរឿងក្តី *Tadić* កថាខណ្ឌ ២២៤ ជើងទំព័រ ២៨៥-២៨១ ដោយយោងទៅលើប្រទេសបារាំង និងប្រទេសអ៊ីតាលី ព្រមទាំងយុត្តាធិការច្បាប់ common law ប្រទេសអង់គ្លេស វេល កាណាដា សហរដ្ឋអាមេរិក អូស្ត្រាលី និង ហ្សំប៊ី។

[២៤២] "ហានិភ័យនៃការស្លាប់ ដែលបានកើតឡើង គឺជាផលវិបាកដែលអាចព្យាករណ៍បានអំពីការអនុវត្តផែនការរួម ហើយជនជាប់ចោទធ្វេសប្រហែស ឬមិនពាក់ព័ន្ធទៅនឹងផែនការនោះ"។ សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić*កថាខណ្ឌ ២០៤។ "មនុស្ស [...] បានដឹងថាអំពើរបស់ក្រុមនោះគឺទំនងជានាំឱ្យមានលទ្ធផលនោះ ប៉ុន្តែនៅតែមានឆន្ទៈប្រថុយនឹងហានិភ័យនោះ។ម្យ៉ាងទៀត គេតម្រូវឱ្យមានជាចាំបាច់នូវអ្វីដែលគេហៅថា ចេតនាប្រយោល *dolus eventualis* ( ឬ "ភាពធ្វេសប្រហែសដោយភាពប្រយ័ត្នប្រយែង" ក្នុងប្រព័ន្ធគតិយុត្តិជាតិមួយចំនួន)"។ ដូចឯកសារយោងខាងលើ កថាខណ្ឌ ២២០។ "ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រៅពីឧក្រិដ្ឋកម្មដែលត្រូវបានឯកភាពនៅក្នុងផែនការរួម កើតមានតែនៅពេល [...] (i) *គេអាចមើលឃើញថា* ឧក្រិដ្ឋកម្មនោះ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00519474



៨៥. *រឿងក្តី Tadić* បានសង្កត់ធ្ងន់ទៀតថា សាលដីកាយោងតែទៅលើយុត្តិសាស្ត្រ និងច្បាប់ជាតិប៉ុណ្ណោះ ដើម្បីបង្ហាញថា សញ្ញាណនៃគោលបំណងរួម ដែលត្រូវបានគាំទ្រនៅក្នុងច្បាប់អន្តរជាតិ មានមូលដ្ឋាននៅក្នុងប្រព័ន្ធជាតិជាច្រើន។ ប៉ុន្តែ នៅក្នុងផ្នែកកំពុងពិភាក្សានេះ ប្រភពក្នុងស្រុកទាំងនេះមិនអាចត្រូវបានយកមកធ្វើជាសំអាងថា ជាភស្តុតាងដែលមិនអាចបដិសេធបាននៃគោលការណ៍ ឬវិធានអន្តរជាតិឡើយ តាមទ្រឹស្តីដែលគោលការណ៍ច្បាប់ទូទៅត្រូវបានទទួលស្គាល់ ដោយបណ្តាប្រជា

---

អាចត្រូវបានប្រព្រឹត្តដោយសមាជិកម្នាក់ ឬសមាជិកផ្សេងៗ នៃក្រុមនោះ និង (ii) ជនត្រូវចោទ *មានឆន្ទៈប្រថុយនឹងហានិភ័យនោះ*។ ដូចឯកសារយោងខាងលើ, កថាខណ្ឌ ២២៨។ ដូចដែលត្រូវបានកត់សម្គាល់ដោយចៅក្រម Hunt នៅក្នុងគំនិតដោយឡែកនៅសាលក្រម JCE *Ojdanić*៖

មានភាពខុសគ្នាច្បាស់មួយរវាងការយល់ឃើញថាហេតុការណ៍មួយអាចកើតឡើង និងការយល់ឃើញថា ហេតុការណ៍នោះទំនងជាអាចកើតឡើង (វេវចនៈនៃពាក្យថាប្រហែល)។ ហេតុការណ៍ទំនងជាអាចកើតឡើង ដាក់បន្ទុកធំទៅលើភាគីរដ្ឋអាជ្ញា ជាងហេតុការណ៍មួយអាចកើតឡើង។ ពាក្យថា ហានិភ័យ មិនមានន័យច្បាស់លាស់ ដោយយកអត្ថន័យរបស់វាពីបរិបទរបស់វា [...និងនៅក្នុងកន្សោម] "ហានិភ័យនៃការស្លាប់ដែលបានកើតឡើង" វាហាក់ដូចជាពាក្យនេះប្រើប្រាស់ក្នុងន័យបញ្ជាក់អំពីលទ្ធភាព។ នៅក្នុងចំណុចទី២ ពាក្យថា "ទំនងបំផុត" មានន័យថាយ៉ាងហោចណាស់ក៏ប្រហែល (ប្រសិនបើមិនលើសពីនេះ) ប៉ុន្តែភាពសមមូលរបស់វា ទៅនឹងសញ្ញាណស៊ីវិលនៃចេតនាប្រយោល ហាក់ដូចជាកាត់បន្ថយវាមួយកម្រិតមកនៅត្រឹមជាលទ្ធភាពមួយ។

Hunt Opinion, សាលក្រម JCE *Ojdanić* កថាខណ្ឌ ១០។ គេអាចលើកទឡ្ហីករណ៍ថាយុត្តិសាស្ត្ររបស់តុលាការ ICTY បច្ចុប្បន្ន គឺមានលក្ខណៈមិនប្រែប្រួល និងរក្សានូវការបញ្ជាក់លើកទី៣អំពីលក្ខខណ្ឌតម្រូវនៃចេតនាឧក្រិដ្ឋ ពាក្យថា "អាច" នៅក្នុងចំណុចទី៣នេះ បង្ហាញជាថ្មីអំពីលទ្ធភាព" ដូចឯកសារយោងខាងលើ។ ដូចចៅក្រម Hunt បានបញ្ជាក់៖

"នៅក្នុងយុត្តាធិការច្បាប់ខមម៉ិនឡជាច្រើន ដែលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ឈានហួសពីអ្វីដែលគេបានឯកភាពនៅក្នុង [JCE] ភាគីរដ្ឋអាជ្ញាត្រូវបញ្ជាក់ថាអ្នកចូលរួមដែលពុំ បានប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ បើទោះជាបានចូលរួមក្នុងផែនការជាមួយការសញ្ជឹងគិតអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ ជាឧប្បត្តិហេតុ *ដែលអាចកើតឡើងបាន* នៅក្នុងការអនុវត្តផែនការនោះ។ យោងតាមចៅក្រមរូបនេះ លក្ខណៈនេះប្រហាក់ប្រហែលគ្នានឹងសញ្ញាណច្បាប់ស៊ីវិលនៃ *ចេតនាប្រយោល* ឬ ការធ្វេសប្រហែសដោយភាពប្រយ័ត្នប្រយែង។

*ដូចឯកសារយោងខាងលើ*។ ចេតនាប្រយោលនេះ "តម្រូវឲ្យមានភាពប្រយ័ត្នប្រយែងក្នុងលទ្ធភាព ដែលថាផលវិបាកជាក់លាក់មួយនឹងកើតឡើង និងដោយប្រព្រឹត្តទៅដោយពុំមានការប្រុងប្រយ័ត្ន ឬ សម្របទៅតាមលទ្ធភាពនោះ (ក្នុងន័យជាការរៀបចំខ្លួនដើម្បីប្រឈមនឹងហានិភ័យនោះ)។ វិសាលភាពដែលគេយល់ឃើញអំពីលទ្ធភាពនោះ មានលក្ខណៈមិនដូចគ្នាទេ យោងតាមប្រទេសនីមួយៗដែលប្រកាន់យកច្បាប់ស៊ីវិល ប៉ុន្តែលទ្ធភាពខ្ពស់បំផុតហាក់ដូចជាថា ត្រូវតែមានមូលដ្ឋានជាក់ស្តែងមួយដើម្បីសន្មតថាផលវិបាកណាមួយនឹងកើតឡើង" ដូចឯកសារយោងខាងលើ n. 44។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ជាតិនៅលើពិភពលោក។ ដើម្បីអាចទទួលយកប្រភពនេះបាន ប្រទេសភាគច្រើន ប្រសិនបើមិនបានទាំងអស់ទេ ត្រូវតែអនុម័តយកនូវទ្រឹស្តីដូចគ្នានៃគោលបំណងរួមនេះ។ ក្នុងរឿងក្តី *Tadić* តុលាការបានសន្និដ្ឋានថា នេះមិនអាចទៅរួចឡើយ[២៤៣]។

៨៦. ដំណើរការដ៏ត្រឹមត្រូវក្នុងការអនុវត្ត ដើម្បីវាយតម្លៃអំពីអត្ថិភាពនៃគោលការណ៍ច្បាប់ទូទៅត្រូវបានចង្អុលបង្ហាញនៅក្នុងសាលក្រមលើរឿងក្តី *Furundžija* និង *Kunarac*។ ការយោងមិនត្រូវសំអាងទៅលើប្រព័ន្ធច្បាប់ជាតិតែមួយប៉ុណ្ណោះ ដូចជាច្បាប់កុំមិនឡ ឬច្បាប់ស៊ីវិលរហូតដល់ទាត់ចោលប្រព័ន្ធច្បាប់ដទៃទៀតនោះទេ[២៤៤] ទោះបីជាខ្លឹមសារនៃគោលការណ៍ទូទៅមិនតម្រូវឱ្យមានការអង្កេតឱ្យបានទូលំទូលាយទៅលើប្រព័ន្ធច្បាប់ទាំងអស់នៅលើពិភពលោកក៏ដោយ[២៤៥]។ វាក៏មានសារៈសំខាន់ផងដែរក្នុងការបញ្ចៀសនូវ "លំនាំចូល ឬការផ្ទេរ ដោយមិនបានពិចារណា ពីច្បាប់ជាតិ ទៅដាក់បញ្ចូលក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ"[២៤៦]។ ឧទាហរណ៍ នៅពេលដែលប្រឈម

---

[២៤៣] សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ២២៥។ ឯកសារសំអាងមួយ ដែលបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ លើកយកសំអាង លើកបញ្ហាដែលមានអង្គហេតុដែលថា "សង្គតិភាព និងសុពលភាពនៃច្បាប់យុត្តិសាស្ត្រ និងសន្ធិសញ្ញានានាដែលខ្លួនបាននិយាយយោងទៅដល់ព្រមទាំងភាពស្របគ្នាជាមួយគោលការណ៍ទូទៅស្តីពីការទទួលខុសត្រូវឧក្រិដ្ឋកម្ម ដែលបានចែងនៅក្នុងលក្ខន្តិកៈ និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិទូទៅ និងនៅក្នុងបញ្ញត្តិជាតិ នាំឱ្យមានការ សន្និដ្ឋានថាច្បាប់យុត្តិសាស្ត្រពិតជាឆ្លុះបញ្ចាំងនូវវិធានទំនៀមទម្លាប់នៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ។ សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ២២៦។ *មើល* Sassoli & Olson, ទំព័រ ៧ (loc. cit. 58)។

[២៤៤] *មើលសាលក្រមជំនុំជម្រះ* Furundžija កថាខណ្ឌ ១៧៨, សាលក្រមជំនុំជម្រះ *Kunarac* កថាខណ្ឌ ៤៣៩។ *សូមមើលផងដែរ* ទស្សនៈរបស់ Bonomy សេចក្តីសម្រេចស្តីពីសហចារីកម្ម *Ojdanić* កថាខណ្ឌ ២៧។

[២៤៥] មើលរដ្ឋអាជ្ញា ទល់នឹង *Erdemović* សំណុំរឿងលេខ IT-96-22-A សាលដីកា អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៩៧, ទស្សនៈដោយឡែករបស់ចៅក្រម McDonald និង Vohrah ("សេចក្តីសម្រេចរបស់ McDonald និង Vohrah, សាលដីកា *Erdemović* កថាខណ្ឌ ៥៧ ("គេបានទទួលស្គាល់ជាទូទៅថាការធ្វើអង្កេតលម្អិតអំពីប្រព័ន្ធគតិយុត្តិទាំងអស់ក្នុងពិភពលោក [ពុំមានលក្ខណៈចាំបាច់ឡើយ] ដោយហេតុថាបញ្ហានេះនឹងពាក់ព័ន្ធទៅដល់លទ្ធភាព ដែលមិនអាចទៅធ្វើបាន និងពុំដែលធ្លាប់ជាទម្លាប់អនុវត្តន៍របស់តុលាការយុត្តិធម៌អន្តរជាតិ ឬសាលា ក្តី អន្តរជាតិផ្សេងៗ ដែលបានជ្រើសរើសយកមាត្រា ៣៨(១)(គ) នៃលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ")។ *ដូចឯកសារយោងខាងលើ,* ទស្សនៈដោយឡែករបស់ចៅក្រម Stephen ("ទស្សនៈ Stephen សាលដីកា *Erdemović*) កថាខណ្ឌ ២៥ ("ពុំមានការទទួលស្គាល់ជាសាកលណាមួយ ទៅលើគោលការណ៍ណាមួយជាក់លាក់របស់ប្រទេសណាមួយនៅក្នុងប្រព័ន្ធច្បាប់សំខាន់ មានភាពចាំបាច់មុនពេលគេបំពេញចន្លោះប្រហោង")។

[២៤៦] មើលសាលក្រមជំនុំជម្រះ *Furundžija* កថាខណ្ឌ ១៧៨, សាលក្រមជំនុំជម្រះ *Kunarac* កថាខណ្ឌ ៤៣៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

នឹងភារកិច្ចក្នុងការស្វែងរកការពិត ថាតើបទដ្ឋាននៃចេតនាឧក្រិដ្ឋ ដែលមានកម្រិតទាបជាងចេតនាផ្ទាល់ អាចអនុវត្តបានឬយ៉ាងណា ទាក់ទិននឹងការចេញបញ្ជា តាមមាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈ ហើយប្រសិនបើដូច្នេះមែន វាគួរត្រូវបានកំណត់និយមន័យបែបណានោះ អង្គជំនុំជម្រះតុលាការកំពូល ICTY ក្នុងរឿងក្តី *Blaškić* បានពិនិត្យឡើងវិញនូវច្បាប់ជាតិស្តីពីការធ្វេសប្រហែស និងការធ្វេសប្រហែសធ្ងន់ធ្ងរ (*dolus eventualis*)។ អង្គជំនុំជម្រះនេះបានពិនិត្យឡើងវិញនូវយុត្តាធិការរបស់សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អូស្ត្រាលី បារាំង អ៊ីតាលី និងអាល្លឺម៉ង់ ដើម្បីកំណត់អំពីធាតុផ្សំអត្តនោម័តនៃ "ការចេញបញ្ជា" ក្រោមមាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈ[២៤៧]។ ដោយបានពិនិត្យលើវិធីសាស្ត្រ ដែលយកមកពីប្រព័ន្ធជាតិប្រទេសទាំងនេះ ព្រមទាំងករណីយុត្តិសាស្ត្រមកពីតុលាការអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា "ការដឹងអំពីហានិភ័យប្រភេទណាក៏ដោយ ប៉ុន្តែកម្រិតទាប មិនគ្រប់គ្រាន់សម្រាប់ការដាក់នូវការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ"[២៤៨]។ លើសពីនេះទៀត អង្គជំនុំជម្រះនេះរកឃើញថា "ការដឹងអំពីភវនីយហេតុនៃហានិភ័យកម្រិតខ្ពស់ និងធាតុផ្សំដោយចេតនា ត្រូវតែដាក់បញ្ចូលទៅក្នុងបទដ្ឋានគតិយុត្ត"[២៤៩]។

៨៧. អង្គបុរេជំនុំជម្រះមានទស្សនៈថា ខ្លួនមិនចាំបាច់ធ្វើការសម្រេចឡើយថាតើប្រព័ន្ធច្បាប់ជាតិមួយចំនួន ដែលអាចត្រូវបានចាត់ទុកថាតំណាងឱ្យប្រព័ន្ធច្បាប់សំខាន់ៗរបស់ពិភពលោក ទទួលស្គាល់ថាបទដ្ឋាននៃ*ចេតនាឧក្រិដ្ឋ* ទាបជាងចេតនាផ្ទាល់ អាចអនុវត្តបានឬយ៉ាងណា ទាក់ទិននឹងបទឧក្រិដ្ឋនានា ដែលត្រូវបានប្រព្រឹត្តឡើងខាងក្រៅគោលបំណងឧក្រិដ្ឋរួម និងចាត់ទុកថាជាការប្រព្រឹត្ត។ តាមពិត ទោះបីជាបែបនេះក៏ដោយ អង្គជំនុំជម្រះបានរកឃើញថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមគឺអាចផ្តន្ទាទោសបាន ទាក់ទិនទៅនឹងបទឧក្រិដ្ឋអន្តរជាតិ អង្គបុរេជំនុំជម្រះមិនពេញចិត្តឡើយថា

---

[២៤៧] មើលសាលដីកាបណ្តឹងឧទ្ធរណ៍ *Blaškić* កថាខណ្ឌ ៣៤-៤២។

[២៤៨] សាលដីកាបណ្តឹងឧទ្ធរណ៍ *Blaškić* កថាខណ្ឌ ៤១។

[២៤៩] *ដូចឯកសារយោងខាងលើ*។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានសន្និដ្ឋាននៅកថាខណ្ឌ ៤២ ថា "មនុស្សដែលបញ្ជាអំពើ ឬការខកខាន ដោយបានដឹងអំពីភាពប្រាកដទំនងដែលថា ឧក្រិដ្ឋកម្មមួយនឹងត្រូវបានប្រព្រឹត្តនៅក្នុងការអនុវត្តតាមបញ្ជានោះ មាន*ចេតនាឧក្រិដ្ឋ*ចាំបាច់ សម្រាប់បង្កើតឱ្យមានការទទួលខុសត្រូវ តាមវិធាន ៧(១) អនុលោមតាមការបញ្ជា។ ការបញ្ជាដោយដឹងអំពីផលវិបាកនេះ ត្រូវចាត់ទុកថាជាការទទួលយកឧក្រិដ្ឋកម្មនោះ"។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00519477



ការទទួលខុសត្រូវបែបនេះអាចព្យាករណ៍ជាមុនបានចំពោះជនត្រូវចោទក្នុងឆ្នាំ ១៩៧៥-១៩៧៩ មានន័យថា បទឧក្រិដ្ឋដែលស្ថិតនៅខាងក្រៅគោលបំណងឧក្រិដ្ឋរួម ប៉ុន្តែជាបច្ច័យដែលមានលក្ខណៈធម្មជាតិនៃការដឹងអំពីគោលបំណងនោះ និងអាចព្យាករណ៍ជាមុនបានចំពោះពួកគេអាចធ្វើឱ្យការទទួលខុសត្រូវរបស់ពួកគេក្លាយជាសហចារីនោះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់នៅក្នុងបញ្ហានេះថា ទោះបីជាអង្គបុរេជំនុំជម្រះបានរកឃើញថា ទម្រង់មូលដ្ឋាន និងទម្រង់ប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម (JCE I & II) មានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជានៅពេលវេលាដែលពាក់ព័ន្ធចំពោះសំណុំរឿង ០០២ ក៏ដោយ សារៈសំខាន់នៃទ្រឹស្តីនេះ គឺជាចេតនា និងគោលបំណងឧក្រិដ្ឋរួម ដែលរួមចំណែកដោយសមាជិកនៃ JCE ដែលបទឧក្រិដ្ឋនានា ដែលបង្កើតបានជាផ្នែកនៃ JCE នោះ ត្រូវបានគេប្រព្រឹត្តឡើង។ JCE III មានបំណងភ្ជាប់ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនានា ដែលស្ថិតនៅខាងក្រៅគោលបំណងឧក្រិដ្ឋរួម ប៉ុន្តែជាបច្ច័យដែលមានលក្ខណៈធម្មជាតិនៃការដឹងអំពីគោលបំណងនោះ និងអាចព្យាករណ៍ជាមុនបានចំពោះជនជាប់ចោទ។ អង្គបុរេជំនុំជម្រះមិនទាន់អាចកំណត់បាននៅឡើយទេ នៅក្នុងច្បាប់កម្ពុជា ដែលអាចអនុវត្តបាននៅពេលវេលាដែលពាក់ព័ន្ធនូវបទប្បញ្ញត្តិណាមួយដែលអាចផ្តល់ជាការជូនដំណឹងដល់ជនត្រូវចោទថា ទម្រង់ទូលាយនៃការទទួលខុសត្រូវ ក៏អាចផ្តន្ទាទោសផងដែរ។ ក្នុងកាលៈទេសៈបែបនេះ គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យ អ.វ.ត.ក មិនផ្អែកទៅលើទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម នៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក[២៥០]។

៨៨. ដូច្នេះ អង្គបុរេជំនុំជម្រះ គាំទ្របណ្តឹងឧទ្ធរណ៍ក្នុងវិសាលភាពដែលពាក់ព័ន្ធនឹងការអនុវត្ត JCE III នៅចំពោះមុខ អ.វ.ត.ក[២៥១]។

[២៥០] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា ក.ស.ច.ស ខកខានពុំបានបញ្ជាក់ទឡ្ហីករណ៍ជាក់លាក់ពាក់ព័ន្ធណាមួយ ដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងសំណើរបស់ខ្លួន និងសេចក្តីសន្និដ្ឋានជាបន្តបន្ទាប់ ហើយនៅត្រង់ប្រការនេះ វិការៈដែលការសមគំនិត និងទស្សនាទាននៃការជាប់ពាក់ព័ន្ធផ្នែកព្រហ្មទណ្ឌ ដែល ក.ស.ព និយាយយោងទៅដល់ គឺជាបទល្មើស *មិនពេញលេញ* ពុំមែនជាទម្រង់នៃការទទួលខុសត្រូវឡើយ ហើយពុំសូវមានប្រយោជន៍ដល់ការកំណត់បញ្ហានេះឡើយ។

[២៥១] ទឡ្ហីករណ៍បន្ថែមរបស់ អៀង ធីរិទ្ធ ដែលថាពេលគ្មានមូលដ្ឋានគតិយុត្តិសម្រាប់ JCE III ក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំអាចបំពេញគម្លាតបាននោះ គឺពុំមានសុពលភាពឡើយ។

៨៩. ជាលទ្ធផលនៃការរកឃើញខាងលើ មូលហេតុទី១ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលចោទប្រកាន់ថា ដីកាដែលត្រូវបានជំទាស់ មានភាពមិនច្បាស់លាស់ និងស្រពិចស្រពិលក្នុងការជជែកសំអាងរបស់ដីកានោះអំពីទម្រង់ទីបីនៃ JCE[២៥២] គឺមិនសំខាន់ឡើយ។ ដូច្នេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យទៅលើមូលហេតុទី៣ នៃបណ្តឹងឧទ្ធរណ៍ ដែលចោទប្រកាន់ថា ដីកាដែលត្រូវបានជំទាស់ មិនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់លោកស្រីដែលថា JCE មិនត្រូវបានជជែកការពារឲ្យបានត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឡើយ[២៥៣]។ ដើម្បីអនុវត្តបែបនេះ ជាលទ្ធផលនៃការរកឃើញរបស់អង្គបុរេជំនុំជម្រះដែលទាក់ទិនទៅនឹងភាពអាចអនុវត្តបាននៃ JCE III នៅចំពោះមុខ អ.វ.ត.ក អង្គបុរេជំនុំជម្រះនឹងកំណត់ការពិនិត្យឡើងវិញរបស់ខ្លួនទៅលើមូលហេតុនៃបណ្តឹងឧទ្ធរណ៍ ត្រឹមវិសាលភាពដែលវាពាក់ព័ន្ធទៅនឹងវិធីដែល JCE I ត្រូវបានជជែកការពារ។

## ខ. <u>បញ្ហាថាតើ JCE I ត្រូវបានជជែកការពារបានត្រឹមត្រូវដែរឬទេ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ</u>

៩០. ដើមបណ្តឹងឧទ្ធរណ៍ចោទថា ដីកាដែលត្រូវបានជំទាស់ខកខានមិនបានលើកទឡ្ហីករណ៍ នៅក្នុងសេចក្តីសន្និដ្ឋានរបស់លោកស្រី អៀង ធីរិទ្ធ ទេថា "JCE ត្រូវបានជជែកការពារដោយមិនត្រឹមត្រូវទេនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ"[២៥៤]។ ដោយផ្អែកលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿងលេខ ០០១ ដែលថា "ការបញ្ញត្តិអំពីទម្រង់ JCE នៃមន្ទីរ ស-២១ [...គឺមាន] លក្ខណៈស្រពិចស្រពិល ជាពិសេសនៅពេលដែលវាពាក់ព័ន្ធនឹងសារណាស្តីពីទម្រង់នៃ JCE ទាំងបីយ៉ាងដែលខុសគ្នានោះ" និងការសង្កត់ធ្ងន់អំពីសារៈសំខាន់នៃភាពច្បាស់លាស់ក្នុងបញ្ហានេះ[២៥៥] ដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងថា វិធីដែល "JCE ត្រូវបានជជែកការពារនៅក្នុងដីកាសន្និដ្ឋាន

---

[២៥២] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៩។

[២៥៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៨។

[២៥៤] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៨។

[២៥៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៣៥។

បញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងសំណុំរឿងលេខ០០២ ក៏មានលក្ខណៈស្រពិចស្រពិល និងមិនច្បាស់លាស់ដូចគ្នាដែរ"[២៥៦]។

៩១. នៅក្នុងចម្លើយតបរបស់ខ្លួន ក.ស.ព បានលើកឡើងថា ដើមបណ្ដឹងឧទ្ធរណ៍បានស្នើដោយមិនត្រឹមត្រូវសុំឲ្យ ក.ស.ច.ស ធ្វើការវាយតម្លៃអំពីភាពគ្រប់គ្រាន់នៃសារណានានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយការវិភាគនេះគួរតែត្រូវបានរក្សាទុកសិន លុះត្រាតែដល់ដំណាក់កាល "ក្រោយពេលចេញដីកាដំណោះស្រាយ" នៃកិច្ចដំណើរការនីតិវិធី[២៥៧]។ ក.ស.ព ក៏បានលើកឡើងផងដែរថា ដោយសារតែ "ពុំមានដើមបណ្ដឹងឧទ្ធរណ៍ណាម្នាក់ត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋណាមួយនៅឡើយផ្អែកតាម JCE ដែលជាទម្រង់នៃការទទួលខុសត្រូវមួយនោះ" ការជជែកតតាំងមិនទាន់ដល់ពេល"ត្រូវធ្វើការកំណត់សម្រេចនោះទេ"[២៥៨]។ ពាក់ព័ន្ធនឹងខ្លឹមសារនៃសារណាទាំងឡាយ ក.ស.ព លើកឡើងថា ខ្លួនបានធ្វើការជជែកការពារយ៉ាងត្រឹមត្រូវហើយអំពី JCE នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដូច្នេះហើយជនត្រូវចោទបានទទួលនូវការជូនដំណឹងគ្រប់គ្រាន់អំពីការចោទប្រកាន់នានាដែលបានធ្វើឡើងប្រឆាំងនឹងពួកគាត់[២៥៩]។

៩២. អង្គបុរេជំនុំជម្រះរំលឹកថា សិទ្ធិក្នុងការទទួលបាននូវការជូនដំណឹងអំពីការចោទប្រកាន់នានា គឺជាសិទ្ធិជាមូលដ្ឋានមួយរបស់ជនត្រូវចោទ[២៦០]។ សិទ្ធិក្នុងការទទួលបានការជូនដំណឹងកើតមានឡើងនៅពេលមានការចាប់ខ្លួន[២៦១] និងផ្នែកខ្លះមានន័យថាដើម្បីធានាដល់លទ្ធភាពរបស់ជនត្រូវចោទ ក្នុងការចូលរួមយ៉ាងពេញលេញនៅក្នុងកិច្ចស៊ើបសួរ[២៦២]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការប្រៀបធៀបគ្នារវាងលក្ខខណ្ឌដែលពាក់ព័ន្ធនៃវិធាន៥៣(១)(ក)(ខ) និង៦៧(២) នៃវិធានផ្ទៃក្នុង

[២៥៦] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣១។

[២៥៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៩-៨០។

[២៥៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥។

[២៥៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨១។

[២៦០] វិធាន ២១(១)(ឃ) ICCPR, មាត្រា ៩(២)

[២៦១] វិធាន ២១ (១)(ឃ), សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤០។

[២៦២] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៣៨។

បង្ហាញថា នៅពេលដែលមានតែសេចក្ដីសង្ខេបនៃអង្គហេតុ និងប្រភេទនៃបទល្មើសត្រូវបានកំណត់លក្ខខណ្ឌនៅដំណាក់កាលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ “ការពិពណ៌នាអំពីអង្គហេតុសត្យានុម័ត” ឲ្យបានពេញលេញជាងនេះ និងការកំណត់លក្ខណៈគតិយុត្តិរបស់វា ត្រូវបានកំណត់លក្ខខណ្ឌនៅក្នុងដីកាដំណោះស្រាយ។ វិធាន៥៥(២) និង(៣) នៃវិធានផ្ទៃក្នុងចែងថា “សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតតែលើអង្គហេតុទាំងឡាយ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ” និងមិនត្រូវធ្វើការស៊ើបអង្កេតលើអង្គហេតុថ្មីដែលលេចចេញនៅក្នុងពេលស៊ើបអង្កេតឡើយ លើកលែងតែអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសនៃអង្គហេតុ ដែលមានកំនត់នៅក្នុងដីកាសន្និដ្ឋានដែលមានស្រាប់ ឬ លុះត្រាតែខ្លួនទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា[២៦៣]។ នៅ ពេលពិចារណាអំពីសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទ ដែលត្រូវបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះធ្វើការសន្និដ្ឋានថា លក្ខណៈពិសេសនៃអង្គហេតុនានាដែលត្រូវបានសង្ខេបនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អាចប្រើការយកទៅជជែកការពារ និងពិតណាស់ត្រូវតែយកទៅជជែកការពារនៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការជូនដំណឹងឲ្យបានគ្រប់គ្រាន់ដល់ក្រុមមេធាវីការពារក្ដីអំពីការចោទប្រកាន់ទាំងឡាយ ដែលផ្អែកតាមចំណុចនេះ ការជំនុំជម្រះក្ដីត្រូវតែដំណើរការ។

៩៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា យុត្តិសាស្ត្ររបស់តុលាការ ICTY បានគូសបញ្ជាក់អំពីអង្គហេតុសត្យានុម័តអ្វីខ្លះដែលត្រូវធ្វើការជជែកការពារនៅក្នុងការចោទប្រកាន់មួយ នៅពេលជនជាប់ចោទត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានលើកឡើងតាមរយៈការចូលរួម នៅក្នុងទម្រង់ JCE។ យុត្តិសាស្ត្រដែលបានលើកឡើង មានការពាក់ព័ន្ធនៅក្នុងបរិបទរបស់ អ.វ.ត.ក ពីព្រោះយុត្តិសាស្ត្រនេះត្រូវបានបង្កើតឡើងនៅក្នុងបរិបទនៃក្របខណ្ឌច្បាប់ ដែលលក្ខខណ្ឌកំណត់របស់វាសម្រាប់ការជូនដំណឹង អាចធ្វើការប្រៀបធៀបទៅនឹងក្របខណ្ឌច្បាប់ដែលអាចអនុវត្តនៅ

---

[២៦៣] លើកលែងតែអង្គហេតុថ្មីត្រូវបានកំណត់ត្រឹមតែស្ថានទម្ងន់ទោស ដែលទាក់ទិននឹងសេចក្ដីសន្និដ្ឋានដែលមានស្រាប់ ក.ស.ច.ស ត្រូវជម្រាប ក.ស.ព អំពីអង្គហេតុថ្មីនោះ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

អ.វ.ត.ក បាន ទោះបីជានៅឯតុលាការ ICTY ពុំបានប្រើប្រាស់ចៅក្រមស៊ើបអង្កេតក៏ដោយ[២៦៤]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះនៅតែត្រូវធ្វើការសម្រេចលើបញ្ហាថា តើលក្ខខណ្ឌកំណត់ទាំងអស់នេះ អាចអនុវត្តនៅដំណាក់កាលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរឬទេ ឬក៏អាចអនុវត្តបានតែនៅដំណាក់កាលដីកាដំណោះស្រាយប៉ុណ្ណោះ។ ជាដំបូង រឿងក្តីរបស់តុលាការ ICTY ពិចារណាឃើញថា អត្ថិភាពនៃ JCE គឺជាអង្គហេតុសត្យានុម័តដែលត្រូវធ្វើការជជែកការពារ។ បន្ថែមពីលើនេះ ដីកាចោទប្រកាន់ត្រូវគូសបញ្ជាក់អំពីបញ្ហាមួយចំនួន ដែលត្រូវបានកំណត់បង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី *Krnojelac* តាមលក្ខខណ្ឌដូចខាងក្រោម:

> ដើម្បីដឹងអំពីលក្ខណៈនៃរឿងក្តី គាត់ត្រូវតែបំពេញ ជនជាប់ចោទត្រូវទទួលបានការជូនដំណឹងតាមរយៈការចោទប្រកាន់អំពី:
>
> (ក) លក្ខណៈ ឬគោលបំណង[២៦៥] នៃសហឧក្រិដ្ឋកម្មរួម (ឬក៏ "សារៈសំខាន់" របស់វា នៅពេលដែលជនជាប់ចោទនៅទីនេះបានស្នើសុំ)
>
> (ខ) ពេលវេលាដែល ឬរយៈពេលដែលសហកម្មត្រូវបានលើកឡើងថាមាន
>
> (គ) អត្តសញ្ញាណរបស់អ្នកទាំងឡាយដែលបានពាក់ព័ន្ធនៅក្នុងសហកម្ម - តាមដែលអត្តសញ្ញាណរបស់ពួកគេត្រូវបានដឹង ប៉ុន្តែយ៉ាងហោចណាស់តាមរយៈការយោងលើប្រភេទជាក្រុមរបស់ពួកគេ និង

---

[២៦៤] ជាការពិត អនុលោមតាមវិធាន ១៨(៤) នៃលក្ខន្តិកៈតុលាការ ICTY សេចក្តីសន្និដ្ឋានចោទប្រកាន់ត្រូវរៀបរាប់នូវ "កំណត់ហេតុពិតប្រាកដនៃអង្គហេតុ និងឧក្រិដ្ឋកម្ម ដែលជនត្រូវចោទត្រូវបានចោទប្រកាន់"។ ដូចគ្នានេះ វិធាន ៤៧(គ) នៃវិធានទីតិវិធី និង ភស្តុតាងនៃតុលាការ ICTY ចែងថាដីកាសន្និដ្ឋានចោទប្រកាន់ ត្រូវរៀបរាប់ពុំត្រឹមតែឈ្មោះ និងព័ត៌មានជាក់លាក់អំពីជនសង្ស័យប៉ុណ្ណោះ ប៉ុន្តែថែមទាំងត្រូវរៀបរាប់នូវ "កំណត់ហេតុជាក់លាក់អំពីអង្គហេតុនៃរឿងក្តី"។ បើទោះបីជាបែបណាដូចជានៅ អ.វ.ត.ក លក្ខខណ្ឌតម្រូវអប្បបរមា សម្រាប់ភាគីព្រះរាជអាជ្ញាក្នុងការរៀបរាប់កំណត់ហេតុជាក់លាក់អំពីអង្គហេតុនានានៃរឿងក្តី នៅក្នុងសេចក្តីសន្និដ្ឋានចោទប្រកាន់ ត្រូវយកទៅបកស្រាយដោយគិតទៅដល់បញ្ញត្តិនៃវិធាន ២១(២),២១(៤)(ក) និង២១(៤)(ខ) នៃលក្ខន្តិកៈតុលាការ ICTY ដែលចែងថា "ក្នុងការកំណត់បទចោទប្រឆាំងនឹងជនត្រូវចោទត្រូវមានសិទ្ធិទទួលបានសវនាការប្រកបដោយយុត្តិធម៌" និងជាពិសេស ទទួលបានការជូនដំណឹង "អំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងមកលើខ្លួន" និង "មានពេលវេលា និងសម្ភារៈគ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំការការពារខ្លួន"។

[២៦៥] អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY នៅក្នុងរឿងក្តីដដែលនេះ បញ្ជាក់ថា ដោយមិនទាក់ទិននឹងប្រភេទនៃ JCE ដែលបានលើកឡើង "ការប្រើប្រាស់ទស្សនាទាននៃសហឧក្រិដ្ឋកម្មរួម ក្នុងការកំណត់ទំនួលខុសត្រូវជាលក្ខណៈបុគ្គល សម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានមនុស្សផ្សេងៗ ប្រព្រឹត្តដោយផ្ទាល់ដៃ តម្រូវឲ្យមានការកំណត់ជាក់ហិតអំពីគោលបំណងរួម" សាលដីកាបណ្តឹងឧទ្ធរណ៍ *Krnojelac* កថាខណ្ឌ ១១៦។

(ឃ) លក្ខណៈនៃការចូលរួមពីជនជាប់ចោទនៅក្នុងសហកម្មនោះ។

ត្រង់ចំណុចដែលបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងនេះ ត្រូវបានលើកឡើងតាមរយៈការពិចារណានោះ អយ្យការត្រូវធ្វើការកំណត់បង្ហាញអំពីអង្គហេតុ និងកាលៈទេសៈនានានៅក្នុងដីកាចោទប្រកាន់ដែលការពិចារណាត្រូវបានស្នើសុំឱ្យធ្វើឡើងផ្តើមចេញពីការកំណត់បង្ហាញនេះ[២៦៦]។

៩៤. លក្ខណៈនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុង JCE ត្រូវមានលក្ខណៈច្បាស់លាស់ ហើយនៅពេលដែលលក្ខណៈនៃការចូលរួមត្រូវបានធ្វើឡើងតាមការពិចារណា អយ្យការត្រូវបង្ហាញអត្តសញ្ញាណអំពីអង្គហេតុ និងកាលៈទេសៈនានានៅក្នុងការចោទប្រកាន់ ដែលការពិចារណាត្រូវបានស្នើឱ្យធ្វើឡើងផ្តើមចេញពីការបង្ហាញអត្តសញ្ញាណនេះ[២៦៧]។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅពេលដែលយុត្តិសាស្ត្ររបស់តុលាការ ICTY ហាក់ដូចជាទុកឱ្យអយ្យការនូវលទ្ធភាពក្នុងការធ្វើសារណាស្តីពីលក្ខខណ្ឌនៃ *ចេតនាឧក្រិដ្ឋ* ដែលតម្រូវឱ្យមាន ឬក៏តាមរយៈការធ្វើសារណាស្តីពីអង្គហេតុជាក់លាក់នានាដែល *ចេតនាឧក្រិដ្ឋ* នឹងត្រូវបានពិចារណាផ្តើមចេញពីការធ្វើសារណានេះ[២៦៨] នៅក្នុងករណីដែលអយ្យការមានចេតនាសំអាងលើ "ការប្រព្រឹត្តិរបស់ជនជាប់ចោទ" ជាក់ស្តែង ដើម្បីលើកឡើងថា ជនជាប់ចោទមាន *ចេតនាឧក្រិដ្ឋ* ដែលតម្រូវឱ្យមាននៅពេលនោះ ការប្រព្រឹត្តិនេះនឹងត្រូវបានការពារថា ជាអង្គហេតុសត្យានុម័តនៅក្នុងការចោទ

---

[២៦៦] *រដ្ឋអាជ្ញា ទល់នឹង* *Krnojelac* សំណុំរឿងលេខ IT-97-25-PT, សេចក្តីសម្រេចលើទម្រង់នៃការចោទប្រកាន់ដែលបានធ្វើវិសោធនកម្មលើកទី ២, អង្គជំនុំជម្រះសាលាដំបូង II, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០០ ("សេចក្តីសម្រេចលើទម្រង់នៃការចោទប្រកាន់*Krnojelac*"), កថាខណ្ឌ ១៦។ *សូមមើលផងដែរ* សាលដីកាបណ្តឹងឧទ្ធរណ៍ *Kvočka* កថាខណ្ឌ ៤២។

[២៦៧] *រដ្ឋអាជ្ញា ទល់នឹង* *Milutinović, et al.*, សេចក្តីសម្រេចស្តីពីការចោទប្រកាន់ *Lazarević* កថាខណ្ឌ ៧។

[២៦៨] *មើល*ជាពិសេស សាលដីកាបណ្តឹងឧទ្ធរណ៍ *Blaškić* កថាខណ្ឌ ២១៩ ដែលឯកភាពនឹងកំណត់ហេតុនៅក្នុងរឿងក្តីរដ្ឋអាជ្ញាទល់នឹង *Brđanin and Talić* សំណុំរឿងលេខ IT-99-36-PT, សេចក្តីសម្រេចស្តីពីទម្រង់នៃសេចក្តីសន្និដ្ឋានចោទប្រកាន់បន្ថែមដែលបានធ្វើវិសោធនកម្ម និងសំណើសុំការចោទប្រកាន់ដែលត្រូវធ្វើវិសោធនកម្ម អង្គជំនុំជម្រះសាលាដំបូង II, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៣៣ ដែលទាក់ទិននឹង *ចេតនាឧក្រិដ្ឋ* "គេអាចលើកឡើងអំពីភាវចិត្តពាក់ព័ន្ធ តាមវិធី២យ៉ាង៖ (១) តាមរយៈការលើកឡើងនូវអង្គហេតុភស្តុតាង ដែលភាវចិត្តនឹងត្រូវសន្និដ្ឋានតាមរយៈភស្តុតាងនោះ។ ឬ (ii) តាមរយៈការលើកឡើងនូវភាវចិត្តពាក់ព័ន្ធ ក្នុងលក្ខណៈជាអង្គហេតុសំខាន់"។

ប្រកាន់[២៦៩]។ ដូចដែលបានកត់សម្គាល់ឃើញយ៉ាងត្រឹមត្រូវ ដោយអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY នៅក្នុងរឿងក្តី Milutinovic et al "ដោយសារតែ *ចេតនាឧក្រិដ្ឋ* ជានិច្ចកាលស្ទើរតែជាបញ្ហាសម្រាប់ធ្វើការពិចារណាចេញពីអង្គហេតុ និងកាលៈទេសៈនានាដែលបង្កើតឡើងដោយភស្តុតាងការផ្ទុះបញ្ចាំងពីសារណាស្តីពីអង្គហេតុដែលអយ្យការនឹងយោងទៅលើ ដើម្បីបង្កើត

---

[២៦៩] ជាឧទាហរណ៍ នៅក្នុងរឿងក្តី *Kordić and Čerkez* អង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញថាកិច្ចប្រជុំដែល Kordić ត្រូវបានចោទប្រកាន់នៅឯសវនាការថាខ្លួនបានចូលរួម និងដែលអង្គជំនុំជម្រះតុលាការកំពូលបានរកឃើញ គឺផ្នែកសំខាន់មួយនៃរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Kordić, បានបង្កើតបានជាអង្គហេតុមួយដែលគួរបានត្រូវលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Kordić and Čerkez*, IT-95-14/2-A,សាលដីកា អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១៤៤ និង ១៤៧។ *សូមមើលផងដែរ* សាលដីកាតុលាការឧទ្ធរណ៍ *Kvočka* កថាខណ្ឌ ២៩។ ជាមួយគ្នានេះ នៅក្នុងរឿងក្តី ICTR *Ntakirutimana* ភាគីអយ្យការបានលើកឡើងនូវទង្វើមួយចំនួនរបស់ជនត្រូវចោទ ក្នុងលក្ខខណ្ឌទូទៅនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយពុំបានរៀបរាប់អំពីផ្នែកផ្សេងៗនៃអំពើ និងទង្វើរបស់ជនត្រូវចោទដែលខ្លួនមានតួនាទីត្រូវនិយាយយោងទៅដល់។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTR បានបដិសេធចោលនូវសំអាងហេតុមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងអំពើ និងការប្រព្រឹត្តិមួយចំនួន ដូចជាការផ្តល់សំអាងហេតុដែលថា Gérard Ntakirutimana "បានសម្លាប់មនុស្សម្នាក់ឈ្មោះ 'Esdras' ក្នុងអំឡុងពេលវាយប្រហារ" នៅឯ Mutiti Hill, ដែលអង្គជំនុំជម្រះសាលាដំបូងបានលើកយកមកសំអាងក្នុងការបញ្ជាក់អំពី *អំពើពិរុទ្ធ* និង/ឬ *ចេតនាឧក្រិដ្ឋ* ដែលចាំបាច់សម្រាប់ការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ដោយឈរលើមូលដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានវិការៈ ដោយសារការខកខានរបស់ភាគីអយ្យការក្នុងការដាក់ការចោទប្រកាន់តាមអង្គហេតុពាក់ព័ន្ធ បញ្ចូលទៅក្នុងដីកានោះ (រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Ntakirutimana និងអ្នកផ្សេងទៀត,* ICTR-96-10-A & ICTR-96-17-A, សាលដីកា, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤។ ("សាលដីកាបណ្តឹងឧទ្ធរណ៍ *Ntakirutimana*"), កថាខណ្ឌ៨៦,៩៩ និង៥០៤។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង* Ntakirutimana *និងអ្នកផ្សេងទៀត* ICTR-96-10-T & ICTR-96-17-T, សាលដីកា និងការផ្តន្ទាទោស, អង្គជំនុំជម្រះសាលាដំបូង,ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៨៣២ និង ៨៣៤។ នៅក្នុងរឿងក្តីដដែលអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ បានរកឃើញថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងក្នុងការផ្អែកការផ្តន្ទាទោស Elizaphan Ntakirutimana ចំពោះការជួយ និងជម្រុញអំពើប្រល័យពូជសាសន៍ ទៅលើអង្គហេតុសំខាន់ដែលពុំត្រូវបានលើកឡើង។ ដូច្នេះ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានបដិសេធមិនទទួលស្គាល់ការផ្តន្ទាទោស Elizaphan Ntakirutimana តាមរយៈសេចក្តីសន្និដ្ឋានចោទប្រកាន់ Mugonero ចំពោះការបញ្ជូនខ្លួនអ្នកវាយប្រហារទៅកាន់តំបន់ Mugonero ព្រមទាំងការផ្តន្ទាទោសរបស់គាត់តាមសេចក្តីសន្និដ្ឋានចោទប្រកាន់ Bisesero ចំពោះការចូលរួមរបស់គាត់នៅក្នុងក្បួនយានយន្តដឹកពួកអ្នកវាយប្រហារទៅកាន់ Kabatwa Hill ដែលគាត់បាននាំជនភៀសខ្លួន Tutis នៅឯ Gitwa Hill ទៅកាន់ទីនោះ និងចំពោះការដឹកជញ្ជូនអ្នកវាយប្រហារទៅទីនោះ និងចំពោះការមានវត្តមានក្នុងការវាយប្រហារនៅឯសាលាបឋមសិក្សា Mubuga នៅក្នុងពាក់កណ្តាលខែមេសា។ មើលសាលដីកាបណ្តឹងឧទ្ធរណ៍ *Ntakirutimana* ។

បានជា *ចេតនាឧក្រិដ្ឋ* ដែលតម្រូវឱ្យមាននោះ បង្ហាញពីសារៈសំខាន់ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានចាត់ទុកដើម្បីធានាថា ការចោទប្រកាន់ជូនដំណឹងដល់ជនជាប់ចោទយ៉ាងច្បាស់លាស់អំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់នានាប្រឆាំងនឹងរូបគាត់”[២៧០]។

៩៥. ពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា ខ្លួនមិនត្រូវបានកំណត់លក្ខខណ្ឌឱ្យធ្វើសារណាតាមវិធីមួយដែលថាការបែងចែកគ្នារវាងទម្រង់នៃ JCE ទាំងបីយ៉ាង និងដែលហេតុនេះហើយបានជាជនត្រូវចោទត្រូវបានជូនដំណឹងយ៉ាងគ្រប់គ្រាន់ថា ពួកគេកំពុងស្ថិតក្រោមការស៊ើបអង្កេតសម្រាប់ការចូលរួមដែលអាចមានរបស់ពួកគេនៅក្នុងទម្រង់ JCE នោះ[២៧១] អង្គបុរេជំនុំជម្រះយល់ឃើញថា ជាថ្មីម្តងទៀត គោលការណ៍ណែនាំមួយចំនួនអាចទទួលបានពីតុលាការអន្តរជាតិនានា ឬពីតុលាការដែលបានធ្វើអន្តរតួបនីយកម្មដទៃៗទៀត។ នៅក្នុងរឿងក្តី Krnojelac អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានពិចារណាឃើញថា វាជាការប្រសើរសម្រាប់ការចោទប្រកាន់មួយដែលបានចោទអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ក្នុងនាមជាអ្នកចូលរួមនៅក្នុងទម្រង់ JCE ដើម្បីសំដៅទៅលើទម្រង់ពិសេសមួយ (ឬច្រើន) (ទម្រង់មូលដ្ឋាន ឬ ទម្រង់ទូលាយ) នៃ JCE ដែលត្រូវបានយល់ឃើញផងដែរ[២៧២]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY យល់ឃើញថា “ជាគោលការណ៍ ចំណុចនេះមិនរារាំងអយ្យការមិនឱ្យធ្វើសារណា នៅក្នុងឯកសារផ្សេងពីដីកាចោទប្រកាន់ឡើយ-ឧបមាដូចជានៅក្នុងសារណាមុនពេលជំនុំជម្រះក្តីជាដើម - ទ្រឹស្តីច្បាប់ដែលអយ្យការជឿជាក់ បង្ហាញឱ្យឃើញយ៉ាងច្បាស់បំផុតថា បទឧក្រិដ្ឋចំនួនមួយ ឬច្រើនដែលត្រូវបានចោទប្រកាន់ អាចធ្វើការចោទប្រកាន់លើជនជាប់ចោទបានតាមច្បាប់ស្របជាមួយនឹងអង្គហេតុនានាដែលបានលើកឡើង។ ទោះបីជាយ៉ាងណាក៏

---

[២៧០] សេចក្តីសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ *Lazarević* កថាខណ្ឌ ៨។

[២៧១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨១។

[២៧២] សាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Krnojelac*, កថាខណ្ឌ ១៣៨។ *សូមមើលផងដែរ* នៅក្នុង បរិបទនៃ SCSL *រដ្ឋអាជ្ញាទល់នឹង Kanu* SCSL-2003-13-PT, សេចក្តីសម្រេច និងដីកា លើសំណើរបស់មេធាវីការពារក្តីសម្រាប់វិការៈ នៅក្នុងទម្រង់នៃដីកាចោទប្រកាន់, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៣ កថាខណ្ឌ ១៤។ នៅក្នុងរឿងក្តី *Kanu* បញ្ហាគឺថាតើភាគីអយ្យការត្រូវជ្រើសរើសរវាងទម្រង់មូលដ្ឋាននៃ JCE និងទម្រង់ទូលាយ។ អង្គជំនុំជម្រះពុំបានផ្តល់សំអាងហេតុណាមួយចំពោះការពន្យល់អំពីភាពខុសគ្នារវាង JCE I & JCE II ឡើយ។

00519485



ដោយជម្រើសនេះ ត្រូវបានកំណត់ដោយសេចក្តីត្រូវការក្នុងការធានាដល់ជនជាប់ចោទនូវការជំនុំជម្រះក្តីដោយយុត្តិធម៌”[២៧៣]។ បន្ទាប់ពីកែប្រែបរិបទរបស់ អ.វ.ត.ក អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីឱ្យជនត្រូវចោទអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការចូលរួមនៅក្នុងកិច្ចស៊ើបសួរ លក្ខខណ្ឌកំណត់ស្តីពីការជូនដំណឹងត្រូវអនុវត្តចំពោះដីកាបញ្ជូនរឿងឱ្យស៊ើបសួរក្នុងកំរិតខ្លះ[២៧៤]។ ទោះបីជាយ៉ាងណាក៏ដោយ កម្រិតនៃលក្ខណៈពិសេសដែលបានទាមទារនៅក្នុងដីកាចោទប្រកាន់មិនអាចត្រូវបានទទួលស្គាល់ដោយផ្ទាល់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ពីព្រោះ ក.ស.ព ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយមិនមានប្រយោជន៍ពីកិច្ចស៊ើបសួរទាំងមូលនោះទេ។ ដូចនេះ តាមការយល់ឃើញរបស់អង្គបុរេជំនុំជម្រះជាការប្រសើរ នៅពេលដែលវាគឺសម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមួយ ដែលបានចោទអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងនាមជាអ្នកចូលរួមនៅក្នុងទម្រង់ JCE ដែលត្រូវយោងលើទម្រង់ពិសេសមួយ (ឬ ច្រើន) (ទម្រង់មូលដ្ឋាន ឬ ទម្រង់ជាប្រព័ន្ធ)[២៧៥] នៃ JCE ដែលត្រូវបានយល់ឃើញផងដែរនោះ ក.ស.ព មិនត្រូវបានរារាំងមិនឱ្យធ្វើដូច្នេះឡើយនៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន។ នៅទីបំផុត សហចៅក្រមស៊ើបអង្កេតអាចយោងលើទម្រង់ពិសេសមួយ (ឬច្រើន) នៃការចូលរួមនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន[២៧៦]។

---

[២៧៣] សាលដីកាបណ្តឹងឧទ្ធរណ៍ *Krnojelac,* កថាខណ្ឌ ១៣៨។

[២៧៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤០(“វិធាន ២១(១)(ឃ) ត្រូវបានគេចាត់ទុកថាបានយកមកអនុវត្តចាប់តាំងពីពេលចាប់ខ្លួន”)។

[២៧៥] ដោយហេតុថាទម្រង់ទូលាយនៃ JEC គឺពុំអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ការញែកអំពីភាពខុសគ្នានៃ JCE III គឺពុំទាក់ទងនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នឡើយ។

[២៧៦] តាម *Krnojelac,* យ៉ាងហោចណាស់ រដ្ឋអាជ្ញាត្រូវជជែកអំពីអង្គហេតុដែលនាំឱ្យមានការសន្និដ្ឋានអំពីលក្ខខណ្ឌតម្រូវ *ចេតនាឧក្រិដ្ឋ* ដើម្បីលើកឡើងអំពី “លក្ខណៈនៃការចូលរួមរបស់ [ជនត្រូវចោទ]” ក្នុង JCE ដែលត្រូវបានចោទប្រកាន់។ សាលដីកា *Krnojelac* ស្តីពីទម្រង់នៃការចោទប្រកាន់, កថាខណ្ឌ ១៦។ *សូមមើលផងដែរ* Lazarević, សាលដីកាចោទប្រកាន់ កថាខណ្ឌ ៧-៩។ *ចេតនាឧក្រិដ្ឋ* ចាំបាច់សម្រាប់ JCE 1 គឺ “ចេតនាប្រព្រឹត្ត” ឧក្រិដ្ឋកម្មនានាដែលជាកម្មវត្ថុនៃ JCE រីឯសម្រាប់ JCE 2 វិញ គឺ “ការដឹងអំពីលក្ខណៈនៃ [ប្រព័ន្ធរួមគ្នានៃការធ្វើបាប]” និង “ចេតនាជម្រុញប្រព័ន្ធ[នោះ]”។ សូមមើល ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៥។ ដូច្នេះ ដើម្បីលើកឡើងអំពី JCE I និង JCE II សហព្រះរាជអាជ្ញាត្រូវលើកឡើងអង្គហេតុនានា ដែលតាមរយៈអង្គហេតុនោះ គេអាចបង្ហាញនូវការសន្និដ្ឋានអំពី *ចេតនាឧក្រិដ្ឋ* ចំនួន២ផ្សេងគ្នាដែលគេយកមកអនុវត្តបាន។

៩៦. ពាក់ព័ន្ធនឹងភាពជឿជាក់របស់ដើមបណ្តឹងឧទ្ធរណ៍លើសំអាងហេតុ ដែលលើកឡើងដោយអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿងលេខ០០១ ដែលថាការបញ្ញត្តិអំពីទម្រង់ JCE មានភាពស្រពិចស្រពិល នៅពេលដែលវាពាក់ព័ន្ធនឹងសារណាស្តីពីទម្រង់នៃ JCE ទាំងបីយ៉ាងនោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វាពាក់ព័ន្ធនឹងសារណាស្តីពី "ទម្រង់ JCE មន្ទីរ ស-២១" ដែលបានលើកឡើង នៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿងនោះ បន្ទាប់ពីមានដីកាបែងចែកគ្នា និងដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា "សហឧក្រិដ្ឋកម្មរួមដែលក្នុងនោះ [ឌុច និងជនត្រូវចោទទាំងឡាយនៅក្នុងសំណុំរឿងលេខ០០២] ត្រូវបានលើកឡើងថាមានការពាក់ព័ន្ធ គឺស្ថិតនៅក្នុង [សំណុំរឿងលេខ ០០២] ដែលត្រូវបានបែងចែក"[២៧៧]។ ហេតុដូច្នេះ សំអាងហេតុរបស់អង្គបុរេជំនុំជម្រះស្តីពីការអនុវត្តទម្រង់ JCE នៅក្នុងសំណុំរឿងលេខ ០០១ មិនមានការជាប់ទាក់ទងនឹងការអនុវត្តទម្រង់ JCE នៅក្នុងសំណុំរឿងលេខ ០០២ ឡើយ។

៩៧. បន្ទាប់ពីបានពិនិត្យមើលផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលពាក់ព័ន្ធ[២៧៨] អង្គបុរេជំនុំជម្រះយល់ឃើញថា ក.ស.ព បានផ្តល់ដល់ជនត្រូវចោទនូវសេចក្តីលម្អិតគ្រប់គ្រាន់នៃអង្គហេតុ

---

[២៧៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១២៣។

[២៧៨] "ផែនការឧក្រិដ្ឋរួម ឬ សហឧក្រិដ្ឋកម្មរួម (JCE) មានអត្ថិភាពនៅ ឬមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តរហូតមកដល់យ៉ាងហោចណាស់មកទល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" (កថាខណ្ឌ៥)។ "គោលបំណងនៃផែនការឧក្រិដ្ឋរួមគឺការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធ ទៅលើក្រុមមួយចំនួនក្នុងចំណោមប្រជាជនកម្ពុជា [...] ដោយលុបបំបាត់ភាពខុសគ្នាខាងវប្បធម៌ និងឋានៈរវាងក្រុមជាតិពន្ធុ ក្រុមសញ្ជាតិ ក្រុមសាសនា ក្រុមជាតិសាសន៍ តាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលអាចផ្តន្ទាទោសបានតាម [...] ច្បាប់ អ.វ.ត.ក" (កថាខណ្ឌ៦)។ "គោលបំណងនៃផែនការឧក្រិដ្ឋរួមក៏បានរាប់បញ្ចូលនូវការបដិសេធសិទ្ធិជាមូលដ្ឋាន ដូចជាសិទ្ធិទទួលបានសេរីភាព សន្តិសុខរបស់មនុស្ស និងទ្រព្យសម្បត្តិ។ សិទ្ធិមានសេរីភាពបញ្ចេញមតិ ការសម្តែងទស្សនៈ គំនិត មនសិការ និងសាសនា និងសិទ្ធិមានគ្រួសារ និងជីវិតផ្ទាល់ខ្លួន [...]" (កថាខណ្ឌ៧)។ "មនុស្សម្នាក់ៗដែលបានចូលរួមដោយចេតនា និងតាមការស្ម័គ្រចិត្តនៅក្នុង JCE នៅគ្រប់រយៈកាលរបស់វា ឬក៏នៅក្នុងពេលខុសគ្នាក្នុងរយៈកាលនៃ JCE រួមមានប៉ុន្តែពុំកំណត់ត្រឹមតែនួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងកាំង ហ្កេកអ៊ាវ [sic.] (ឌុច) [...]។ មនុស្សទាំងនេះបានចូលរួមនៅក្នុង JCE ក្នុងឋានៈជាសហចារីដោយផ្ទាល់ ឬប្រយោល។ ពួកគាត់មានចេតនាចង់ឲ្យមានលទ្ធផលឧក្រិដ្ឋ បើទោះបីពួកគាត់ពុំបានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះដោយផ្ទាល់ដៃក្តី [ដែលត្រូវបានប្រព្រឹត្តដើម្បីសម្រេចតាមផែនការនោះ]" (កថាខណ្ឌ៨)។ អៀង សារី ក្នុងនាមជាសមាជិកមួយរូបនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេស គាត់បានជម្រុញញុះញង់ សម្របសម្រួល និងលើកទឹកចិត្តនិង/ឬលើកលែងទោស នូវការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះដែលបានរៀបរាប់នៅក្នុង

នានា ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ ដែលជនជាប់ចោទបានចូលរួមក្នុង JCE ដោយអនុញ្ញាតឱ្យពួកគេអាចចូលរួមយ៉ាងពេញលេញនៅក្នុងកិច្ចស៊ើបសួរ និងត្រូវបានទទួលនូវការជូនដំណឹងគ្រប់គ្រាន់នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី។ ចំណុចនេះមានភាពច្បាស់លាស់ណាស់ពាក់ព័ន្ធនឹងលក្ខណៈ ឬគោលបំណងនៃទម្រង់ JCE ដែលបានលើកឡើង ព្រមទាំងការកំណត់ពេលវេលារបស់វា។ ពាក់ព័ន្ធនឹងបញ្ហាថាតើជនត្រូវចោទត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីចេតនារបស់

---

[ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ...]។ អៀង សារី ក៏បានដឹងអំពីលក្ខខណ្ឌខុសច្បាប់នៅក្នុងប្រទេស តាមរយៈការចុះពិនិត្យផ្ទាល់តាមក្រសួង និងអង្គភាពតូចៗ នៅក្នុង និងនៅជុំវិញទីក្រុងភ្នំពេញ [...]។ ការដែលគាត់បានដឹងអំពីស្ថានភាពទាំងនេះគឺមានភាពច្បាស់លាស់ តាមរយៈចម្លើយជា សាធារណៈរបស់គាត់។ [...] អៀង សារី បានដឹង និងបានសម្របសម្រួលការធ្វើការងារពលកម្មដោយបង្ខំជាទ្រង់ទ្រាយធំ ការឃុំខ្លួនដោយខុសច្បាប់ ការធ្វើបាប ការធ្វើទារុណកម្ម និងការប្រហារជីវិតក្រៅប្រព័ន្ធតុលាការទៅលើបុគ្គលិកក្រសួងការបរទេស [...]"។ (កថាខណ្ឌ៨៨)។ "តាមរយៈមុខតំណែងដឹកនាំជាច្រើនរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា គាត់បានជម្រុញ ញុះញង់ ជួយសម្រួល លើកទឹកចិត្ត និង/ឬ បណ្តែតបណ្តោយឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ ដូចមានរៀបរាប់ក្នុងដីកា [សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ]។ [...] ខៀវ សំផន បានជម្រុញ និងសម្របសម្រួលការជម្លៀសមនុស្សដោយបង្ខំចេញពីក្រុងភ្នំពេញ និងទីក្រុងធំៗផ្សេងទៀត បន្ទាប់ពីជ័យជំនះរបស់បក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ [...] គាត់បានចូលរួមក្នុងការរៀបចំការងារពលកម្មដោយបង្ខំទូទាំងប្រទេស។ គាត់បានធ្វើការត្រួតពិនិត្យជាទៀងទាត់លើហេដ្ឋារចនាសម្ព័ន្ធរដ្ឋ ការដ្ឋានរោងចក្រ និងការដ្ឋានស្រែចំការ (កថាខណ្ឌ៩៧)។ "អៀង ធីរិទ្ធ ក្នុងឋានៈជារដ្ឋមន្ត្រីសង្គមកិច្ច បានជំរុញ ញុះញង់ ជួយសំរួល លើកទឹកចិត្ត និង/ឬ បណ្តែតបណ្តោយឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដូចមានរៀបរាប់ក្នុង [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ]។ [...] អៀង ធីរិទ្ធ បានរៀបចំផែនការ ណែនាំ សម្របសម្រួល ប្រើឥទ្ធិពល និងបញ្ជាដល់ការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងក្រសួងសង្គមកិច្ចតាមមធ្យោបាយមួយចំនួនដូចជា ១) ការជ្រើសរើសយុវជនមិនចេះអក្សរនិងគ្មានសមត្ថភាពមកជំនួសបុគ្គលិកពេទ្យដែលមានការបណ្តុះបណ្តាល [...និង] ការធ្វើទស្សនកិច្ចទូទាំងប្រទេស ដើម្បីធ្វើការវាយតម្លៃ និងរាយការណ៍ផ្ទាល់ជូន ប៉ុល ពត អំពីបញ្ហាសុខាភិបាល របបអាហារ និងស្ថានភាពរស់នៅ [...]។ ទោះបីជាគាត់បានដឹងពីស្ថានភាពគាំពារសុខភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ អៀង ធីរិទ្ធ បានជួយ និងចូលរួមក្នុងការអនុវត្តគោលនយោបាយទាំងនេះ ដែលបង្កើតនិងធ្វើឱ្យមានស្ថានភាពរស់នៅបែបអមនុស្សធម៌ និងបណ្តាលឱ្យប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យស្លាប់យ៉ាងច្រើន" (កថាខណ្ឌ១០៣)។ ជនសង្ស័យទាំងនេះបានរៀបចំផែនការញុះញង់ បញ្ជា ជួយជម្រុញ ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មអស់ទាំងនេះ។ ជនសង្ស័យទាំងនេះបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលពួកគេបានចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមជាមួយសហចារីដទៃទៀត។ ឧក្រិដ្ឋកម្មអស់ទាំងនេះគឺជាកម្មវត្ថុនៃសហកម្មឧក្រិដ្ឋកម្មរួម[...]។ សមាជិកដទៃទៀតរបស់សហកម្មឧក្រិដ្ឋកម្មរួមនេះ បានធ្វើសកម្មភាពដោយឈរលើមូលដ្ឋាននៃកម្មវត្ថុរួមគ្នានេះ ដោយមានចេតនារួមគ្នា" (កថាខណ្ឌ១១៦)។ សូមមើល ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, D3, ទំព័រ ៥៦-៨៤ សម្រាប់ការពិពណ៌នាលម្អិតអំពីលក្ខណៈនៃការចូលរួមរបស់ជនត្រូវចោទម្នាក់ៗ។

00519488

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៥, អបជ៣៧ , អបជ៣៨ និង**អបជ ៣៩**)

**លេខ/No: D97/16/10**

ក.ស.ព ក្នុងការចោទប្រកាន់អំពីទម្រង់ទាំងអស់នៃ JCE នោះដែរឬទេ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍យល់ថា កថាខណ្ឌទី ៥ ដល់ទី១៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជជែកការពារអំពី JCE II និងអះអាងថា ទម្រង់ទីមួយ និងទម្រង់ទីបី នៃ JCE គ្រាន់តែត្រូវបានជជែកការពារ នៅក្នុងផ្នែកសន្និដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ និងគ្មានមូលដ្ឋានជាក់ស្តែងពិតប្រាកដនៅក្នុងឯកសារចោទប្រកាន់ឡើយ ដូច្នេះការជជែកការពារអំពីទម្រង់ទាំងនេះ ខ្វះភាពច្បាស់លាស់ដែលអង្គបុរេជំនុំជម្រះបានកំណត់លក្ខខណ្ឌ[២៧៩]។ ប៉ុន្តែ តាមការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ ការអះអាងនេះមិនត្រូវបានគាំទ្រពីការបកស្រាយដ៏ត្រឹមត្រូវនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ៖ អង្គហេតុដែលថា ក.ស.ព មានចេតនាចោទប្រកាន់ទម្រង់នៃ JCE ទាំងបីយ៉ាងនោះ មិនមានភាពស្រពិចស្រពិលឡើយ។ តាមពិត ជនត្រូវចោទបានកត់សម្គាល់យ៉ាងច្បាស់អំពីទម្រង់ទាំងបីនៃ JCE ថាមានខ្វះនៅក្នុងសេចក្តីសន្និដ្ឋាននោះ។ ពាក់ព័ន្ធនឹងសមាជិកនៃ JCE ដែលបានចោទប្រកាន់ នៅពេលដែល ក.ស.ព ខកខានមិនបានកំណត់ឈ្មោះសមាជិកផ្សេងទៀតក្រៅពីជនត្រូវចោទនោះ អង្គបុរេជំនុំជម្រះនឹងសង្ឃឹមថា សហចៅក្រមស៊ើបអង្កេតផ្តល់នូវឈ្មោះជាក់លាក់នៃសមាជិក JCE ដែលបានចោទប្រកាន់ផ្សេងៗទៀតដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងដំណើរការស៊ើបសួរនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ប្រសិនបើអាចធ្វើបាន។ ពាក់ព័ន្ធនឹងលក្ខណៈនៃការចូលរួមរបស់ជនត្រូវចោទដែលត្រូវបានចោទប្រកាន់ អង្គបុរេជំនុំជម្រះយល់ឃើញថា ក.ស.ព បានផ្តល់នូវលក្ខណៈពិសេសច្រើនជាង ទាក់ទិនទៅនឹងលក្ខណៈនៃការចូលរួមរបស់ដើមបណ្តឹងឧទ្ធរណ៍ម្នាក់ៗ នៅក្នុងទម្រង់ JCE ដែលត្រូវបានចោទប្រកាន់។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចនេះមិនរាប់ថា ជាការខ្វះការជូនដំណឹងនៅដំណាក់

---

[២៧៩] សេចក្តីសន្និដ្ឋានរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ១៨-២៣។ ភាគីព្រះរាជអាជ្ញាឆ្លើយតបថាក.ស.ច.ស ពុំចាំបាច់ត្រូវពិចារណាអំពីដំណោះស្រាយដែលបានស្នើឡើងដោយ អៀង ធីរិទ្ធ ឡើយ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺជាដំណាក់កាលសមស្របតែមួយគត់សម្រាប់វិភាគថាតើឧក្រិដ្ឋកម្មនានា និងទម្រង់នៃការទទួលខុសត្រូវ ត្រូវបានបញ្ជាក់ត្រឹមត្រូវដែរឬទេ ហើយទោះក្នុងកាលៈទេសៈណាក្តី ក.ស.ច.ស គ្រាន់តែត្រូវស៊ើបសួរអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ និងពុំត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយការកំណត់បទល្មើស ដែលពួកគាត់អាចកែប្រែបានក្នុងពេលវិភាគអំពីភស្តុតាងដែលបានទទួលអំឡុងកិច្ចស៊ើបសួរ ហើយដីកាសម្រេចដែលម្ចាស់បណ្តឹងឧទ្ធរណ៍លើកយកមកសំអាងសមស្របទៅនឹងដំណាក់កាលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទើបបានជាពុំអាចជួយជាប្រយោជន៍បាន។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ជាពិសេសត្រង់កថាខណ្ឌ ៧៨-៨០។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C.

កាលនៃកិច្ចដំណើរការនីតិវិធីនេះឡើយ ដរាបណាដីកាដំណោះស្រាយដែលចោទប្រកាន់ដើមបណ្តឹងឧទ្ធរណ៍ណាម្នាក់ និងអះអាងការចូលរួមរបស់ពួកគេនៅក្នុងទម្រង់ JCE ថាជាទម្រង់នៃការប្រព្រឹត្តិនោះ មានចំណុចជាក់លាក់ទាំងឡាយនៃការប្រព្រឹត្តិរបស់ជនជាប់ចោទដែលផ្តើមចេញពីចំណុចទាំងនេះ ក.ស.ច.ស ពិចារណាឃើញថា ការចូលរួមរៀងៗ ខ្លួនរបស់ពួកគេនៅក្នុងទម្រង់ JCE និង/ឬ *ចេតនាទុច្ចរិត* ដែលតម្រូវឱ្យមានរបស់ពួកគេ គឺត្រូវបានយកទៅពិចារណា។

## គ. <u>បញ្ហាថាតើទម្រង់ JCE **អនុវត្តចំពោះបទល្មើសជាតិ ក៏ដូចជាចំពោះបទឧក្រិដ្ឋអន្តរជាតិដែរឬទេ?**</u>

៩៨. ជាការគាំទ្រដល់បណ្តឹងឧទ្ធរណ៍របស់ពួកគេ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថាទម្រង់ JCE ក៏អនុវត្តចំពោះបទឧក្រិដ្ឋទាំងឡាយដែលស្ថិតក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ផងដែរ ពីព្រោះ "ការទទួលខុសត្រូវ JCE កើតមានស្របតាមច្បាប់កម្ពុជាឆ្នាំ១៩៥៦ ត្រង់ចំណុចដែល JCE ត្រូវបានយោងជា "*សកម្មភាពរួមគ្នា និងការសមគំនិតគ្នា*" [ការរួមប្រព្រឹត្ត និងការសមគំនិត] និងយ៉ាងហោចណាស់ បានរួមបញ្ចូលនូវទម្រង់នៃ JCE ពីរយ៉ាងដំបូង"[២៨០]។ ពួកគេលើកទឡ្ហីករណ៍ថា យោងតាមច្បាប់កម្ពុជា ពុំមានរបបគតិយុត្តិពិសេសសម្រាប់បទឧក្រិដ្ឋអន្តរជាតិនានានោះទេ [ហើយដូច្នេះ] គ្មានតម្រូវការបង្កើតឡើងនូវគម្រោងការបកស្រាយសម្រាប់ប្រភេទជាក់លាក់នានា ផ្អែកលើប្រពៃណីច្បាប់បារាំងនោះឡើយ[២៨១]។ ដើមបណ្តឹងឧទ្ធរណ៍ក៏បានលើកឡើងផង

---

[២៨០] បណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១០។

[២៨១] បណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១១។ បើទោះបីហាក់ដូចជាផ្ទុយទៅនឹងស្មារតីនៃបណ្តឹងឧទ្ធរណ៍នេះក្តី ក៏សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីពុំព្យាយាមស្នើសុំការបដិសេធទៅលើដីកាដែលត្រូវជំទាស់ ក្នុងវិសាលភាពដែលបណ្តឹងឧទ្ធរណ៍នេះសម្រេចថា JCE គឺពុំអាចយកមកអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ។ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ក៏បានលើកទឡ្ហីករណ៍ថាដីកាដែលត្រូវបានជំទាស់បង្កើតឡើងនូវ "ប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្ម២ប្រភេទ" និងជំទាស់តវ៉ាទៅលើការយោងរបស់ ក.ស.ច.ស ទៅលើច្បាប់បារាំងដែលជាមូលដ្ឋានសម្រាប់"ប្រព័ន្ធយុត្តាធិការស្វយ័ត សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ" ដោយហេតុថាសៀវភៅច្បាប់ដែលដីកាត្រូវបានជំទាស់យកមកសំអាងនោះ ត្រូវបានបោះពុម្ពផ្សាយតែនៅក្នុងឆ្នាំ២០០២ ប៉ុណ្ណោះ ហើយប្រព័ន្ធយុត្តាធិការស្វយ័តសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានលើកយកមកសំអាងនោះ ពុំបង្កើតបានជាផ្នែកមួយនៃច្បាប់បារាំងដែលកើតចេញពីក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ គាត់បានបន្ថែមថា "ប្រព័ន្ធយុត្តាធិការស្វយ័តដែលត្រូវបានបង្កើតឡើងសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមតែច្បាប់បារាំងឆ្នាំ ២០០២ មួយប៉ុណ្ណោះនោះ ពុំមានវិធានជាក់លាក់ណាមួយចែងអំពីទំនួលខុសត្រូវជាលក្ខណៈបុគ្គលឡើយ" បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន កថាខណ្ឌ ៦០-៧១។

ដែរថា បទឧក្រិដ្ឋទាំងអស់នេះដែលមានលក្ខណៈអន្តរជាតិ គឺជាឧក្រិដ្ឋកម្មដំបូងៗ ហើយក៏ជាឧក្រិដ្ឋកម្មក្នុងស្រុកផងដែរ និងត្រូវបានចោទប្រកាន់យោងតាមច្បាប់ជាតិដែលពាក់ព័ន្ធ ដែលចែងអំពីពហុភាពនៃចារីទាំងឡាយ (ការរួមប្រព្រឹត្ត) និងការជួយជ្រោមជ្រែង និងការញុះញង់ (ការសមគំនិត)[២៨២]។ ផ្ទុយទៅនឹងអ្វីដែលអយ្យការអះអាងនៅក្នុងចម្លើយតបរបស់ពួកគាត់[២៨៣] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យមានការប្រែត្រឡប់នូវដីកាដែលចេញដោយ ក.ស.ច.ស ស្តីពីបញ្ហា JCE យោងតាមច្បាប់ជាតិកម្ពុជា។

៩៩. នៅក្នុងចម្លើយតប ក.ស.ព ឯកភាពថា គ្មានការបែកចេញជាពីរនេះផ្អែកតាមអត្ថិភាពនៃរបបពិសេសនានាដែលគ្រប់គ្រងឧក្រិដ្ឋកម្មជាតិ និងអន្តជាតិដែលមាននៅ អ.វ.ត.ក ឡើយ ដោយពុំគិតដល់អត្ថិភាពរបស់វានៅក្នុងច្បាប់បារាំង ឬច្បាប់កម្ពុជាឡើយ។ នេះក៏ដោយសារតែ អ.វ.ត.ក មានយុត្តាធិការ *ពិសេសតែមួយគត់ sui generis* ផ្អែកតាមច្បាប់ អ.វ.ត.ក និងបណ្តុំវិធានទីតិវិធីរបស់ អ.វ.ត.ក ដែលក្នុងនោះមិនមានការយល់ឃើញអំពីការបែកចេញជាពីរដូចនេះទេ[២៨៤]។

១០០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក.ស.ច.ស បានសម្រេចថា ទម្រង់នៃការទទួលខុសត្រូវឧទាហរណ៍ដូចជាទម្រង់ JCE មិនអាចអនុវត្តហួសពីវិស័យនៃឧក្រិដ្ឋកម្មអន្តរជាតិបានទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សំអាងហេតុរបស់ ក.ស.ច.ស បានផ្អែកលើអង្គហេតុដែលថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ត្រូវបានបង្កើតចេញពីច្បាប់បារាំង។ ក.ស.ច.ស អះអាងថា "ឧក្រិដ្ឋកម្មអន្តរជាតិនានា [...] មាន[ប្រភេទជាក់លាក់] នៃបទឧក្រិដ្ឋ យោងតាម "*របប*" គតិយុត្តិពិសេស និងថា ជាលទ្ធផល ទម្រង់នៃការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិមិនអាចអនុវត្តចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតក្រោមច្បាប់ក្នុងស្រុកបានឡើយ[២៨៥]។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

---

[២៨២] បណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១១។

[២៨៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៣។

[២៨៤] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៥។

[២៨៥] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២២ ដែលយោងតាមនោះ របបទាំងនេះគឺ "ខុសផ្សេងពីច្បាប់ឧក្រិដ្ឋកម្មជាតិ និងត្រូវបានកំណត់ដោយបណ្តុំនៃវិធាននៃនីតិវិធី និងខ្លឹមសារ"។ *សូមមើលផងដែរ* ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២២, n.44,

១០១. ទឡ្ហីករណ៍ដែលបានលើកឡើងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ការទទួលខុសត្រូវ JCE ដែលមានក្រោមច្បាប់កម្ពុជាឆ្នាំ១៩៥៦ ត្រង់ចំណុចដែលថា JCE ត្រូវបានយោងជា "*សកម្មភាពរួមគ្នា និងការសមគំនិតគ្នា*" [ការរួមប្រព្រឹត្ត និងការសមគំនិត]នោះ មិនត្រឹមត្រូវទាំងស្រុងទេ។ ដូចដែលបានលើកឡើងកាលពីមុន[២៨៦] JCE យ៉ាងហោចណាស់នៅក្នុងទម្រង់មូលដ្ឋាន និងទម្រង់ប្រព័ន្ធ ប្រហាក់ប្រហែលគ្នានឹងទម្រង់នៃការរួមប្រព្រឹត្តយោងតាមច្បាប់កម្ពុជាជាធរមាន ក៏ប៉ុន្តែមិនដូចគ្នានោះទេ។ ទម្រង់ទាំងពីរប្រព្រឹត្តជាសហចារី មិនត្រឹមតែអ្នកទាំងឡាយណាដែលប្រព្រឹត្តជាក់ស្តែងនូវ*អំពើពិរុទ្ធ* *actus reus* នៃបទឧក្រិដ្ឋប៉ុណ្ណោះទេ ថែមទាំងអ្នកទាំងឡាយណាដែលមាន *ចេតនាឧក្រិដ្ឋ* សម្រាប់ប្រព្រឹត្តបទឧក្រិដ្ឋ និងរួមចំណែក ឬចូលរួមដឹងឮអំពីបទឧក្រិដ្ឋនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ទោះបីជាការចូលរួមនេះត្រូវតែមានលក្ខណៈសំខាន់ខ្លាំង និងមិនមែនគ្មានខ្លឹមសារពិតប្រាកដក៏ដោយ ការចូលរួមក្នុងទម្រង់ JCE ប្រកាន់យកនូវស្ថានភាពដែលជនជាប់ចោទអាចនឹងមានលក្ខណៈដាច់ឆ្ងាយចេញពីការរួមប្រព្រឹត្តជាក់ស្តែងនៃ *អំពើពិរុទ្ធ* នៃបទឧក្រិដ្ឋ ជាជាងស្ថានភាពទាំងឡាយដែលត្រូវបានដឹងមុនតាមរយៈការចូលរួមផ្ទាល់ ដែលត្រូវបានកំណត់លក្ខខណ្ឌ យោងតាមច្បាប់ក្នុងស្រុក។ ហេតុដូច្នេះ ទឡ្ហីករណ៍ដែលបានលើកឡើងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនគាំទ្រការលើកឡើងថា ដីកាដែលត្រូវបានជំទាស់មានវិការៈឡើយ ក្នុងការសម្រេចថា អ.វ.ត.ក អាចអនុវត្តទម្រង់ JCE បានតែចំពោះឧក្រិដ្ឋកម្មអន្តរជាតិតែប៉ុណ្ណោះ។

១០២. ព្រះរាជអាជ្ញាមានភាពត្រឹមត្រូវដែលថា មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ដែលបានចែងនូវទម្រង់នៃការទទួលខុសត្រូវផ្ទាល់ខ្លួនដែលអាចអនុវត្តនៅចំពោះមុខអ.វ.ត.ក មិនញែកឲ្យឃើញពីភាពខុសគ្នា រវាងឧក្រិដ្ឋកម្មជាតិដែលត្រូវបានកំណត់ន័យត្រង់មាត្រា ៣(ថ្មី) និងឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានកំណត់ន័យត្រង់មាត្រា ៤ ដល់៧ នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចនេះមិនផុតកំណត់នៃការសម្រេចចុងក្រោយលើបញ្ហាដែលបានលើកឡើងទេ។ ដូចមាត្រា ១ នៃច្បាប់ដដែលដែរ

---

ដែលយោងទៅដល់ F. Desportes និង F. Le Gunehec, *Droit Pénal Général,* Ed. ECONOMICA, CorpusDroitPrivé, (2002), ទំព័រ ១៧៧, កថាខណ្ឌ ១៧៤។

[២៨៦] សូមមើល កថាខណ្ឌ ៤១ ខាងលើ។

គោលបំណងនៃមាត្រា ២៩ គឺដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់នេះ និង ឧក្រិដ្ឋកម្មទាំងឡាយក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជាដែលបានកំណត់ត្រង់មាត្រា ៣(ថ្មី) ដែលបាន ប្រព្រឹត្តនៅក្នុងចន្លោះរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទាំងទម្រង់ក្នុងស្រុកនៃការរួមប្រព្រឹត្ត ទាំងការចូលរួមនៅក្នុង ទម្រង់ JCE គឺជាទម្រង់នៃការទទួលខុសត្រូវដែលស្ថិតក្រោមគោលបំណងនៃមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក និងជាទម្រង់នៃការប្រព្រឹត្ត។ ដោយមិនគិតដល់បញ្ហាថាតើការពិចារណាដែលធ្វើឡើង ដោយដីកាដែលត្រូវបានជំទាស់លើទស្សនៈទានបារាំងស្តីពី *របបគតិយុត្តពិសេស* មានការភាន់ច្រឡំ ដែរឬទេនោះ តាមការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ គ្មានទឡ្ហីករណ៍ណាមួយក្នុងចំណោម ទឡ្ហីករណ៍ដែលបានលើកឡើងដោយភាគីនានានៅក្នុងបណ្តឹងឧទ្ធរណ៍នេះបង្ហាញថា ដីកាដែលត្រូវ បានជំទាស់ ភាន់ច្រឡំក្នុងការពិចារណាថា ទម្រង់ JCE ដែលជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ទាំងឡាយ ជាជាងអនុវត្តចំពោះបទល្មើសជាតិនោះទេ។ ដូចនេះ មូលហេតុនៃបណ្តឹងឧទ្ធរណ៍នេះ មិនមានមូលដ្ឋានគ្រប់គ្រាន់។

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៥, អបជ៣៧ , អបជ៣៨ និងអបជ៣៩)

លេខ/No: D97/16/10

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច ÷**

១. **ទទួលយក** បណ្តឹងឧទ្ធរណ៍ដែលបានធ្វើឡើងក្នុងនាមជនត្រូវចោទ អៀង សារី ជនត្រូវចោទ អៀង ធីរិទ្ធ និងជនត្រូវចោទ ខៀវ សំផន ពាក់ព័ន្ធនឹងការជជែកតតាំងនៃសំអាងហេតុរបស់ ក.ស.ច.ស ស្តីពីភាពអាចអនុវត្តបាននៃទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (JCE III) នៅចំពោះមុខ អ.វ.ត.ក។ និង

២. **បដិសេធ** ផ្នែកដែលនៅសល់ផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍។

**ភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០**

**អង្គបុរេជំនុំជម្រះ**

**Rowan DOWNING ន័យ ថុល Catherine MARCHI-UHEL ប៉ែន ព្រេជសាលី ហ្វ្រាក់ គីមសាន**